សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economic

# សារណាបញ្ចប់ការសិក្សា

# សិទ្ធិឃាត់ទុក

ស្រាវជ្រាវ ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


រៀបរៀងដោយ

និស្សិតឈ្មោះ **ខុន លីមឡេង**

**ហេង ប្រិយនាថ**

សាស្ត្រាចារ្យណែនាំ

លោក **ហ៊ីង គីមឡេង**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Royal University of Law and Economic

# សារណាបញ្ចប់ការសិក្សា

# សិទ្ធិឃាត់ទុក

ស្រាវជ្រាវ ពីថ្ងៃ២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

រៀបរៀងដោយ

និស្សិតឈ្មោះ **ខុន លឹមឡេង**

**ហេង ប្រិយនាថ**

សាស្ត្រាចារ្យណែនាំ

លោក **ហ៊ីង គឹមឡេង**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ខុន លីមឡេង** និង **ហេង ច្រិយនាថ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២២ ឆ្នាំសិក្សា២០២១-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

យើងខ្ញុំសូមលំឱនកាយសំដែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅ និងខ្ពង់ខ្ពស់ជាទីបំផុតចំពោះលោកឪពុកអ្នកម្ដាយ ដែលបានផ្ដល់កំណើត ចិញ្ចឹម បីបាច់ថែរក្សា អប់រំប្រៀនប្រដៅ ប្រកបដោយព្រហ្មវិហារធម៌ទាំង៤ និងបានលះបង់អស់ពីកម្លាំងកាយចិត្ត ដើម្បីធ្វើយ៉ាងណាឱ្យយើងខ្ញុំមានឱកាសបានសិក្សារៀនសូត្ររហូតដល់ថ្នាក់បរិញ្ញាបត្រ។ យើងខ្ញុំនៅតែចងចាំជាប់ជានិច្ច មិនអាចបំភ្លេចបានពីគុណនូបការៈរបស់អ្នកមានគុណទាំងទ្វេ ព្រមទាំងលោកគ្រូ និងអ្នកគ្រូ ដែលបានបង្ហាត់បង្រៀនផ្ដល់នូវពុទ្ធិទាំងចរិយាមាយាទតាំងពីថ្នាក់បឋមរហូតមកដល់វិទ្យាល័យ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក-លោកស្រីសាស្ត្រាចារ្យ បណ្ណារក្ស និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំអស់ពីសមត្ថភាពដើម្បីគ្រប់គ្រង និងពង្រឹងនូវការអប់រំនៅថ្នាក់ឧត្តមសិក្សានេះ ព្រមទាំងបានចែករំលែកចំណេះដឹងនិងបទពិសោធន៍ល្អៗដល់រូបយើងខ្ញុំ។
- ជាពិសេសសូមគោរព និងថ្លែងអំណរគុណជាទីបំផុតចំពោះ លោកសាស្ត្រាចារ្យ **ហ៊ីង គឹមឡេង** ជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារនេះឡើង ដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំ និងផ្ដល់យោបល់ទាក់ទងនឹងខ្លឹមសារនៃប្រធានបទសារណានេះ។

ជាទីបញ្ចប់ យើងខ្ញុំសូមបួងសួងដល់ អស់វត្ថុស័ក្តិសិទ្ធិ និងទេពតារក្សាជម្ពូទ្វីបនេះ សូមប្រសិទ្ធិពរជ័យដល់អ្នកមានគុណទាំងអស់ ឱ្យជួបប្រទះតែសេចក្ដីសុខសុភមង្គល និងប្រកបដោយពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

## អារម្ភកថា

ជាការពិតណាស់ អ្វីៗទាំងអស់អាចសម្រេចទៅបាន អាស្រ័យលើការខិតខំ ប្រឹងប្រែង និងព្យាយាមកសាងឡើង។ ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំពិតជាមានអារម្មណ៍ត្រេកអរណាស់ ដែលយើងខ្ញុំមានឱកាសបានសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ តាមការកំណត់របស់ការិយាល័យស្រាវជ្រាវនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលនេះគឺជាស្នាដៃសមិទ្ធផលនៃការខិតខំប្រឹងប្រែងរៀនសូត្រ នៃថ្នាក់ឧត្តមសិក្សា តាំងពីថ្នាក់សិក្សាឆ្នាំមូលដ្ឋានរហូតមកដល់ថ្នាក់បញ្ចប់បរិញ្ញាបត្រនេះ។

ដើម្បីចូលរួមចំណែកក្នុងការជួយសង្គម យើងខ្ញុំជាសិស្សនិស្សិត ក៏បានស្រាវជ្រាវសារណាមួយដែលមានប្រធានបទស្តីពី "**សិទ្ធិឃាត់ទុក**" មកធ្វើជាកម្មវត្ថុនៃការស្រាវជ្រាវក្នុងការបញ្ចប់ឆ្នាំសិស្សានេះ។ ម៉្យាងវិញទៀត គឺមានបំណងជួយឱ្យប្រជាជនខ្មែរបានយល់ដឹងកាន់តែច្បាស់ អំពីសិទ្ធិរបស់ខ្លួនចំពោះការឃាត់ទុកវត្ថុរបស់កូនបំណុល និងការអនុវត្តសិទ្ធិឃាត់ទុកនេះឱ្យបានត្រឹមត្រូវជាស់រៀងខូចខាតដល់ប្រយោជន៍ខ្លួនឯង។ ក្នុងសារណាមួយច្បាប់នេះ យើងខ្ញុំទាំងពីរនាក់ បានស្រាវជ្រាវ និងដកស្រង់ចេញពីបណ្តាឯកសារមួយចំនួនដែលពាក់ព័ន្ធនៅក្នុងបណ្ណាល័យ ព្រមទាំងប្រភពឯកសារផ្សេងៗទៀត ដែលអាចជាគំនិត និងប្រាប់ពីចំណុចសំខាន់ៗដែលទាក់ទងនឹងប្រធានបទនេះ។ ជាពិសេសយើងខ្ញុំក៏បានទទួលនូវការណែនាំយ៉ាងយកចិត្តទុកដាក់ពីសំណាក់លោកសាស្ត្រាចារ្យ **ហ៊ុខ គីមឡេខ** ដែលលោកជាអ្នកដឹកនាំក្នុងការស្វែងរកនូវឯកសារ ក៏ដូចជាផ្តល់ជាគំនិតយោបល់ ចំពោះប្រធានបទខាងលើ។

យ៉ាងណាមិញ ចំពោះសារណាដែលពួកយើងបានធ្វើ យើងខ្ញុំជឿជាក់ថា វានឹងក្លាយជាឯកសារមួយដែលអាចជំនួយដល់មិត្តអ្នកអាន ក្នុងការយល់ដឹងបន្ថែមពីសិទ្ធិដែលខ្លួនមានចំពោះកូនបំណុល ជាពិសេសគឺសិទ្ធិឃាត់ទុក។ ម៉្យាងវិញទៀតក្រោយពីបានសិក្សាស្រាវជ្រាវ និង ចងក្រងអត្ថបទនេះរួច យើងខ្ញុំក៏បានយល់ដឹងថែមមួយកម្រិតទៀតនូវចំណុចសំខាន់ៗ និងករណីសិក្សានៃសិទ្ធិឃាត់ទុក ដែលអាចជួយឱ្យយើងខ្ញុំបានដើរទៅតាមអ្វីដែរច្បាប់បានចង្អុលបង្ហាញ និងបានស្វែងយល់ពីវាផង។

ទោះជាយ៉ាងណាក៏ដោយ ការសរសេរសារណាមួយនេះរមែងមានកំហុសត្រង់ប្រការណាមួយដោយជៀសពុំផុតឡើយ លើអត្ថន័យខ្លឹមសារ និងអក្ខរាវិរុទ្ធ ហេតុដូច្នេះយើងខ្ញុំសូមអភ័យទោសទុកជាមុន ហើយរង់ចាំទទួលយកនូវការរិះគុណដើម្បីស្ថាបនា ក៏ដូចជាការណែនាំបំពេញបន្ថែមពីសំណាក់សាស្ត្រាចារ្យ សិស្សនិស្សិត និងអ្នកសិក្សាទាំងអស់ដោយក្តីសោមនស្សរីករាយ។

ធ្វើនៅថ្ងៃពុធ ១៣កើត ខែស្រាពណ៍ ឆ្នាំខាល ព.ស ២៥៦៦

ត្រូវនឹងថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ..................................................... ១

**ជំពូកទី១៖**

**ការបង្កើត និងអានុភាពនៃសិទ្ធិឃាត់ទុក**

**ផ្នែកទី១៖ សញ្ញាណទូរទៅនៃសិទ្ធិឃាត់ទុក** ..................................................... ៤

**កថាខណ្ឌទី១៖ និយមន័យ** ..................................................... ៤

**កថាខណ្ឌទី២៖ លក្ខខណ្ឌនៃសិទ្ធិឃាត់ទុក** ..................................................... ៥

ក. វត្ថុដែលអាចជាកម្មវត្ថុនៃសិទ្ធិឃាត់ទុក ..................................................... ៥

ក.១. ចលនវត្ថុ ..................................................... ៥

ក.២. អចលនវត្ថុ ..................................................... ៦

ក.៣. វត្ថុដែលមិនអាចធ្វើអនុប្បទានបាន ..................................................... ៦

ខ. សិទ្ធិលើបំណុល ..................................................... ៦

គ. ទំនាក់ទំនងរវាងសិទ្ធិលើបំណុលនឹងវត្ថុ ..................................................... ៧

ឃ. ការកាន់កាប់ ..................................................... ៨

ឃ.១. ការទទួលការកាន់កាប់មកវិញ ..................................................... ៩

ឃ.២. ការកាន់កាប់ដោយអំពើអានីត្យានុគោល ..................................................... ១០

**ផ្នែកទី២៖ អានុភាពនៃសិទ្ធិឃាត់ទុក** ..................................................... ១០

**កថាខណ្ឌទី១៖ សិទ្ធិរបស់ម្ចាស់បំណុលតាមរយៈសិទ្ធិឃាត់ទុក** ..................................................... ១០

ក. សិទ្ធិទទួលបានការសង ..................................................... ១០

ខ. សិទ្ធិទទួលសំណង់ពីផលដោយអទិភាព ..................................................... ១២

គ. សិទ្ធិទាមទារឱ្យសងសោហ៊ុយ ..................................................... ១៣

ឃ. ការអនុវត្តដោយបង្ខំដោយសិទ្ធិឃាត់ទុក ..................................................... ១៤

ឃ.១. វត្ថុឃាត់ទុកជាកម្មសិទ្ធិរបស់កូនបំណុល ..................................................... ១៥

ឃ.២. វត្ថុឃាត់ទុកមិនមែនជាកម្មសិទ្ធិកូនបំណុល ..................................................... ១៥

**កថាខណ្ឌទី២៖ ករណីកិច្ចរបស់ម្ចាស់សិទ្ធិឃាត់ទុក**......១៧
ក. ករណីកិច្ចក្នុងការកាន់កាប់វត្ថុឃាត់ទុក......១៧
ក.១. ការធ្វើបណ្តឹងចំពោះម្ចាស់សិទ្ធិឃាត់ទុក......១៧
ក.២. យន្តការនៃការការពារតតិយជនដែលសុចរិត......១៨
ខ. ករណីកិច្ចប្រគល់វត្ថុឃាត់ទុក......១៩
**កថាខណ្ឌទី៣៖ ការធ្វើលទ្ធកម្មនូវកម្មសិទ្ធិចំពោះចលនវត្ថុ**......១៩
ក. លទ្ធិកម្មនូវកម្មសិទ្ធិចំពោះចលនវត្ថុតាមរយៈសិទ្ធិឃាត់ទុក......១៩
ខ. អាជ្ញាយុកាលនៃការធ្វើលទ្ធកម្មនូវកម្មសិទ្ធិចំពោះចលនវត្ថុ......២០
**កថាខណ្ឌទី៤៖ ការបន្តអានុភាពនៃសិទ្ធិឃាត់ទុក**......២០
ក. ការបន្តសិទ្ធិឃត់ទុកតាមរយៈអនុប្បទានសិទ្ធិលើបំណុល......២០
ខ. ការបន្តសិទ្ធិឃាត់ទុកតាមរយៈសន្តតិកម្ម......២២

## ជំពូកទី២៖

## ការរំលត់សិទ្ធិឃាត់ទុក

**ផ្នែកទី១៖ ការរំលត់សិទ្ធិឃាត់ទុកដោយមូលហេតុទាក់ទងនឹងវត្ថុ**......២៤
**កថាខណ្ឌទី១៖ ការបាត់បង់ការកាន់កាប់លើវត្ថុឃាត់ទុក**......២៤
ក. ការអនុញ្ញាតឱ្យកូនបំណុលយកវត្ថុឃាត់ទុកទៅវិញ......២៥
ខ. ការបាត់បង់ការកាន់កាប់ដោយសារទីតាំងវត្ថុ......២៥
**កថាខណ្ឌទី២៖ ការទូទាត់សិទ្ធិលើបំណុល**......២៦
ក. ការសងដោយទូរទាត់ជាប្រាក់......២៦
ខ. ការសងដោយវត្ថុ......២៧
គ. ការសងដោយការទូរទាត់សិទ្ធិ......២៧
**កថាខណ្ឌទី៣៖ ការរំលត់សិទ្ធិឃាត់ទុកដោយកំហុសម្ចាស់បំណុល**......២៧
ក. ការប្រើប្រាស់វត្ថុឃាត់ទុកដោយបំពាន......២៨
ខ. ការមិនបំពេញករណីកិច្ចមើលថែវត្ថុបានល្អ......២៨
**កថាខណ្ឌទី៤៖ ការរំលត់សិទ្ធិឃាត់ទុកដោយការផ្តល់ប្រាតិភោគសមរម្យ**......២៩

ក. ការផ្តល់ប្រាតិភោគសមរម្យ ........ ២៩
ខ. ការប្រព្រឹត្តទៅនៃការដាក់ប្រាតិភោគ ........ ៣០
**ផ្នែកទី២៖ ការរំលត់សិទ្ធិឃាត់ទុកដោយមូលហេតុភាពចាំបាច់** ........ ៣០
**កថាខណ្ឌទី១៖ ការរំលត់សិទ្ធិឃាត់ទុកដោយការអនុវត្តដោយបង្ខំ** ........ ៣០
ក. ករណីកូនបំណុលមិនព្រមសង ........ ៣១
ខ. ករណីពិបាកក្នុងការមើលថែរក្សាវត្ថុឃាត់ទុក ........ ៣១
**ផ្នែកទី៣៖ ការរំលត់សិទ្ធិឃាត់ទុកដោយអាជ្ញាយុកាល** ........ ៣២
**កថាខណ្ឌទី១៖ ការផុតអាជ្ញាយុកាលនៃសិទ្ធិលើបំណុល** ........ ៣២
ក. អាជ្ញាយុការនៃការរំលត់សិទ្ធិលើបំណុលទូទៅ ........ ៣៣
ខ. អាជ្ញាយុការនៃការរំលត់សិទ្ធិលើបំណុលមានអំឡុងពេលខ្លី ........ ៣៣
គ. អាជ្ញាយុការនៃការរំលត់សិទ្ធិលើបំណុលដែលចូលជាស្ថាពរ ........ ៣៤
**កថាខណ្ឌទី២៖ ការផ្អាក់អាជ្ញាយុកាលនៃសិទ្ធិលើបំណុល** ........ ៣៤
ក. ការផ្អាក់អាជ្ញាយុកាលតាមផ្លូវតុលាការ ........ ៣៥
ខ. ការផ្អាក់ដោយសកម្មភាពចាត់ចែងរក្សាការពារ. ........ ៣៥
គ. ការផ្អាក់ដោយការទទួលស្គាល់កាតព្វកិច្ច ........ ៣៧
**កថាខណ្ឌទី៣៖ ការបង្អង់អាជ្ញាយុកាលនៃសិទ្ធិលើបំណុល** ........ ៣៧
ក. ការបង្អង់អាជ្ញាយុកាលដោយការដាស់តឿន ........ ៣៨
ខ. ការបង្អង់អាជ្ញាយុកាលដោយសារគ្រោះមហន្តរាយធម្មជាតិ ........ ៣៩
**សេចក្តីសន្និដ្ឋាន** ........ ៤១
**អនុសាសន៍** ........ ៤៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

ជាតថភាពជាក់ស្ដែងនៃជីវភាពប្រចាំថ្ងៃក្នុងសង្គមមនុស្ស យើងសង្កេតឃើញថា មនុស្សតែងតែមានទំនាង់ទំនងនឹងគ្នា ក្នុងនោះយើងឃើញថាមានទំនាក់ទំនងម្យ៉ាងដែលមិនអាចខ្វះបាន នោះគឺទំនាក់ទំនងរកស៊ី និងពាណិជ្ជកម្មផ្សេងៗ។ សកម្មភាពទាំងអស់នេះហើយធ្វើឱ្យមនុស្សទទួលបានផលប្រយោជន៍ពីគ្នាទៅវិញទៅមក ក៏ប៉ុន្តែនៅពេលខ្លះការទទួលផលវាមិនបានរលូនដូចការរំពឹងទុកនោះទេ ពោលគឺនៅពេលខ្លះបញ្ហាអាចកើតមានឡើងក្នុងពេលធ្វើសកម្មភាពរកស៊ី និងការដោះដូរ ជាពិសេសគឺការផ្ដល់សេវាកម្មតែម្ដង ដែលញ៉ាំងឱ្យភាគីទាំងពីរត្រូវអនុវត្តសិទ្ធិដែលមានរៀងៗខ្លួនដើម្បីការពារផលប្រយោជន៍ ឬទទួលបានការធានាលើផលប្រយោជន៍ទាំងនោះ។ ដើម្បីការពារ ឬទទួលបានការធានាលើផលប្រយោជន៍មិនឱ្យបាត់បង់ និងខូចខាត គឺត្រូវមានការធានាកាតព្វកិច្ចជាមុនសិនរវាងភាគីម្ខាងដែលជាម្ចាស់បំណុល និងភាគីម្ខាងជាកូនបំណុល។ ម្យ៉ាងវិញទៀត ការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាខ្លះ ភាគច្រើនកើតពីប្រភេទកិច្ចសន្យាឥតសរសេរ ដោយកិច្ចសន្យាបែបនេះមិនបានកើតឡើងដោយមានការសន្យាដាក់វត្ថុធានាការអនុវត្តកាតព្វកិច្ចអ្វីនោះឡើយ ដែលទម្រង់បែបនេះហើយគឺអាចជាបញ្ហា ក៏ប៉ុន្តែមិនមែនមានន័យថាគ្មានមធ្យោបាយដើម្បីបង្កើតឱ្យមានការធានាកាតព្វកិច្ចវិញនោះទេ ពោលគឺវាគ្រាន់តែនៅពេលដែលកិច្ចសន្យានោះកើតមានឡើង ភាគីមិនបានចរចារគ្នាពីរឿងដាក់ការធានាកាតព្វកិច្ចឡើយ តែការធានាកាតព្វកិច្ចនឹងអាចកើតមាននៅពេលក្រោយ នៅពេលដែលកាតព្វកិច្ចណាមួយ ឬទាំងស្រុងមិនត្រូវបានអនុវត្តដោយភាគីកូនបំណុល។

បើយើងពិនិត្យមកមើលក្នុងក្រមរដ្ឋប្បវេណីកម្ពុជា (២០០៧) គន្ថីទី៦ ចែងអំពី "ការធានាកាតព្វកិច្ច" ពីមាត្រា ៧៦៦ រហូតដល់មាត្រា ៧៧៣ ដែលបទបញ្ញត្តិទាំងនេះច្បាប់អនុម័តឡើងដើម្បីការពារផលប្រយោជន៍របស់ភាគីក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចខ្លួន នោះភាគីម្ចាស់បំណុលអាចប្រើប្រាស់សិទ្ធិដែលច្បាប់កំណត់និយមន័យថាជាសិទ្ធិប្រាតិភោគប្រត្យក្ស។ ក្នុងនោះផងដែរ សិទ្ធិឃាត់ទុកក៏ជាប្រភេទមួយនៃសិទ្ធិប្រាតិភោគប្រត្យក្សដែលភាគីខាតបង់ប្រយោជន៍អាចយកមកអនុវត្តបាន ដោយធ្វើការឃាត់ទុកវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុកក្នុងកិច្ចសន្យា។ ហេតុដូច្នេះហើយ បើភាគីបានបង្កើតកិច្ចសន្យាសរសេរក្ដី ឬឥតសរសេរក្ដី ទោះបីជាភាគីទាំងពីរមិនបានចែង ឬមិនបានចរចារគ្នាអំពីការដាក់វត្ថុ ឬដាក់ការធានាកាតព្វកិច្ចដោយអ្វីមួយនោះទេ ក្នុងដំណាក់កាលនៃការអនុវត្តកិច្ចសន្យាមានសុពលភាពរួច ប៉ុន្តែភាគីណាមួយមិនព្រមអនុវត្តកាតព្វកិច្ចខ្លួន នោះភាគីម្ខាងទៀតដើម្បីបង្ខំឱ្យភាគីមិនអនុវត្តកាតព្វកិច្ចនោះធានាឱ្យបាននូវផលប្រយោជន៍ខ្លួនមិនឱ្យបាត់បង់ គឺមានតែអនុវត្តសិទ្ធិឃាត់ទុកនេះឯង ដើម្បីទទួលបាននូវការទូទាត់សំណង។

ដោយមើលឃើញថា ការធ្វើពាណិជ្ជកម្ម ឬសេវាកម្មនានាគឺជាចរន្តនៃលំហូសេដ្ឋកិច្ច ដែលនឹងនាំផលប្រយោជន៍ជាច្រើនដល់អាជីវករ និងពាណិជ្ជករទាំងនោះ មិនតែប៉ុណ្ណោះរដ្ឋក៏នឹងក្លាយជានីតិបុគ្គលដែលទទួល

បានផលប្រយោជន៍តាមរយៈការទទួលបានប្រាក់ចំណូលពីពន្ធ ហើយពន្ធទាំងនោះនឹងក្លាយជាថវិការរបស់ជាតិ ដើម្បីយកទៅកសាង និងអភិវឌ្ឍន៍ប្រទេស។ ប្រសិនបើសកម្មភាពទាំងនោះមានបញ្ហាកើតឡើង ឬក្ស័ធ ប្រាកដណាស់វានឹងប្រឈមនឹងភាពខាតបង់ ហើយបើសកម្មភាពរកស៊ីរបស់ពាណិជ្ជករ ឬអាជីវករខាតបង់ នោះរដ្ឋក៏ប្រឈមនឹងការបាត់បង់ប្រាក់ចំណូលជាមួយគ្នានេះដែរ។ ម៉្យាងវិញទៀត វាមិនមែនជាគម្រូល្អនោះឡើយនៅពេលដែលភាគីម្ខាងសន្យាអ្វីមួយទៅកាន់ភាគីម្ខាងទៀតរួចមិនព្រមអនុវត្តតាមការសន្យារបស់ខ្លួន ដោយសកម្មភាពបែបនេះវានឹងបង្កើតទៅជាគម្រូមិនល្អ នៅពេលដែលគម្រូមិនល្អនេះច្រើនពេកវានឹងបង្កើតជាទម្លាប់អាក្រក់ដែលធ្វើឱ្យមនុស្សមិនចេះគោរពពាក្យសម្ដីខ្លួនឯង នាំឱ្យខាតបង់ប្រយោជន៍ទាំងប្រជាពលរដ្ឋ និងរដ្ឋផងដែរ។ ហេតុដូច្នេះ ច្បាប់បានបញ្ញត្តិវិធានគតិយុត្តជាច្រើន ក្នុងនោះរួមមានបញ្ញត្តិស្ដីពីសិទ្ធិឃាត់ទុកផងដែរ ដើម្បីទប់ស្កាត់ផលវិបាកដែលលិចចេញពីការធ្វើអាជីវកម្ម សេវាកម្ម និងពាណិជ្ជកម្មនានា ឬដើម្បីធានាឱ្យបាននូវទំនុកចិត្តរវាងភាគីទាំងសងខាង។

តាមរយៈការអនុវត្តរបបនយោបាយបែបប្រជាធិបតេយ្យ និងការជ្រើសរើសប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីគឺបានជំរុញឱ្យវិស័យអាជីវកម្ម ពាណិជ្ជកម្ម សេវាកម្ម ការផ្ទេរ ការប្រើប្រាស់ទំនិញដែលជាសិទ្ធិឯកជនត្រូវមានសេរីភាពយ៉ាងបរិបូរណ៍ ហើយវានឹងធ្វើឱ្យសេដ្ឋកិច្ចរបស់ប្រទេសជាតិមានភាពរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ។ ភាពរីកចម្រើននេះចាំបាច់ណាស់ត្រូវឱ្យមានសមត្ថភាពក្នុងការទប់ស្កាត់រាល់អំពើគេងចំណេញ ឬអំពើណាមួយដែលបណ្ដាលឱ្យខូចប្រយោជន៍ដល់អ្នកដទៃ។ អ្នកដែលមានបំណងរកស៊ី ឬវិនិយោគទាំងឡាយគួរគប្បីយល់អំពីច្បាប់ គឺដើម្បីយល់ដឹងអំពីសិទ្ធិដែលខ្លួនមាន និងអ្វីទៅជាការធានាកាតព្វកិច្ចរបស់ភាគី ដែលញ៉ាំងឱ្យទំនាក់ទំនងរកស៊ីប្រកបដោយការទទួលខុសត្រូវខ្ពស់ និងការធានាបាននូវផលប្រយោជន៍នានានៃការវិនិយោគរបស់ខ្លួន។ ហេតុដូច្នេះហើយ ទើបការសិក្សាអំពីសិទ្ធិឃាត់ទុក គឺមានប្រយោជន៍ខ្លាំងណាស់សម្រាប់មនុស្សគ្រប់គ្នាដើម្បីយកទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ ព្រោះថាការធានាឱ្យបាននូវកាតព្វកិច្ចគឺជាផ្នែកដ៏សំខាន់មួយដែលមិនអាចខ្វះបានក្នុងការបង្កើតភាពទុកចិត្តគ្នារវាងភាគី ដើម្បីឱ្យសកម្មភាពជីវភាពប្រចាំថ្ងៃរបស់ពួកគេអាចឈានទៅមុខបានប្រកបដោយការទទួលខុសត្រូវ និងទំនុកចិត្តខ្ពស់។ តើសិទ្ធិឃាត់ទុកនេះអាចនឹងកើតឡើងយ៉ាងរបៀបណា? តើការធានាកាតព្វកិច្ចតាមរយៈការអនុវត្តសិទ្ធិឃាត់ទុកមានអានុភាពគតិយុត្តយ៉ាងដូចម្ដេច? ម៉្យាងវិញទៀត តើសិទ្ធិឃាត់ទុកនេះអាចបាត់បង់ទៅវិញនៅពេលណាខ្លះ?

ដើម្បីឱ្យប្រទេសជាតិទទួលបានការអភិវឌ្ឍន៍ ប្រកបដោយស្ថេរភាព និងនិរន្តភាព នោះយើងទាំងអស់គ្នាគប្បីចូលរួមចំណែកក្នុងសង្គម ដើម្បីជួយផ្សព្វផ្សាយចំណេះដឹងដល់ប្រជាពលរដ្ឋទូរទៅឱ្យបានយល់ដឹងអំពីសិទ្ធិ និងករណីយរបស់ខ្លួនផងដែរ បើមិនដូច្នេះទេ ភាពអសកម្ម និងវិវាទនៅក្នុងសង្គមនឹងកើនមានកាន់តែច្រើន។ ហេតុនេះ សារណាយើងខ្ញុំគឺមានគោលបំណងចង់ចូលរួមចំណែងក្នុងការបកស្រាយបំភ្លឺ និងបង្ហាញនូវបទបញ្ញត្តិទាំង

អស់ដែលទាក់ទងនឹងសិទ្ធិឃាត់ទុកឱ្យប្រជាពលរដ្ឋទូទៅយល់ដឹងអំពី សិទ្ធិឃាត់ទុក ឱ្យកាន់តែច្បាស់ថាត្រូវអនុវត្តនៅពេលណា ហើយប្រើវាយ៉ាងដូចម្ដេច ដើម្បីជៀសវាងកុំឱ្យមានការខាតបង់ផលប្រយោជន៍ និងជៀសវាងវិវាទដែលអាចកើតមាន។

ដូចដែលបានរៀបរាប់ខាងលើរួចមកហើយថា សារណានេះគឺជាគំនិតដក់ស្រង់ចេញពីប្រភពច្បាប់ និងបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងសិទ្ធិឃាត់ទុក ជាពិសេសគឺយើងសិក្សាដោយផ្អែកលើវិធាន និងបទបញ្ញត្តិដែល មានចែងក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ជាមូលដ្ឋានសំខាន់បំផុត ក្នុងការបកស្រាយ និងបង្ហាញលើប្រធានបទ ស្ដីពីសិទ្ធិឃាត់ទុកនេះ។ ការចងក្រងឡើងស្នាដៃជាសារណានេះ ក្នុងគោលបំណងមួយចែងរំលែកចំណេះដឹងដល់សង្គម ហើយមួយផ្អែកទៀតគឺដើម្បីការពារយកសញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រផ្នែកនីតិសាស្ត្រ និងជាចំណែកមួយក្នុងការចូលរួមចំណែកកិច្ចការស្រាវជ្រាវ ប្រមូលផ្ដុំ និងចងក្រងឯកសារបន្សល់ទុកជាស្នាដៃសម្រាប់សិស្ស និស្សិត និងអ្នកសិក្សាដែលមានបំណងចង់យល់បន្ថែមឱ្យកាន់តែច្បាស់ពីសិទ្ធិឃាត់ទុក ដែលអាចនាំឱ្យប្រទេសជាតិមានធុនធានមនុស្សក្នុងការអភិវឌ្ឍន៍ប្រទេសប្រកបដោយសណ្ដាប់ធ្នាប់ សន្តិភាព និងនិរន្តភាព។

ដើម្បីឱ្យមានភាពងាយស្រួល និងជាស្ពានឈានទៅរកដំណោះស្រាយនូវបញ្ហាផ្សេងៗទាក់ទងនឹងអ្វីទៅគឺជាសិទ្ធិឃាត់ទុក ដែលក្រុមយើងខ្ញុំបានចងក្រង និងលើកយកមកបង្ហាញខាងលើពួកយើងបានចែកប្រធានបទជាពីរជំពូកធំៗ នៅក្នុងនោះផងដែរ ជំពូកទី១ ពួកយើងនឹងបកស្រាយអំពី **ការបង្កើត និងអានុភាពនៃសិទ្ធិឃាត់ទុក** និង ជំពូកទី២ ពួកយើងនឹងបកស្រាយអំពី **ការរំលត់សិទ្ធិឃាត់ទុក** ។

# ជំពូកទី១
# ការបង្កើត និងអានុភាព
# នៃសិទ្ធិឃាត់ទុក

# ជំពូកទី១៖ ការបង្កើត និងអានុភាពនៃសិទ្ធិឃាត់ទុក

នៅក្នុងជំពូកនេះ យើងនឹងធ្វើការបកស្រាយអំពីអត្ថន័យនៃសិទ្ធិឃាត់ទុក និងលក្ខខណ្ឌដែលបង្កើតឱ្យមានសិទ្ធិឃាត់ទុកឡើងដើម្បីឱ្យសិទ្ធិឃាត់ទុកនោះមានអានុភាព។ ការបកស្រាយនេះយើងនឹងលើកយកបញ្ញត្តិស្តីអំពីសិទ្ធិឃាត់ទុក ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីកម្ពុជា (២០០៧) ហើយក៏យោងតាមបទបញ្ញត្តិទូទៅនៃសិទ្ធិប្រាតិភោគប្រត្យក្ស ដែលជាគោលការណ៍ទូទៅអនុវត្តចំពោះប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្សទាំងប្រាំ ក្នុងនោះសិទ្ធិឃាត់ទុកក៏ជាប្រភេទនៃសិទ្ធិមួយក្នុងចំណោមសិទ្ធិប្រាតិភោគប្រត្យក្សផងដែរ។

លក្ខខណ្ឌចម្បងនៃសិទ្ធិប្រាតិភោគប្រត្យក្ស គឺជា (១) ជនដែលមានសិទ្ធិប្រាតិភោគប្រត្យក្សមានអាទិភាពក្នុងការទទួលការសង ជាងម្ចាស់បំណុលផ្សេងទៀត (អានុភាពនៃការទទួលការសងដោយមានអាទិភាព) និង (២) ម្ចាស់សិទ្ធិប្រាតិភោគប្រត្យក្សអាចឃាត់ទុកនូវវត្ថុជាកម្មវត្ថុ រហូតដល់ពេលដែលទទួលការសងនៃកាតព្វកិច្ចនោះ (អានុភាពនៃការឃាត់ទុក)។

## ផ្នែកទី១៖ សញ្ញាណទូទៅនៃសិទ្ធិឃាត់ទុក

ប្រាតិភោគប្រត្យក្ស គឺជាមធ្យោបាយធានាកាតព្វកិច្ចដោយវត្ថុ។ ដោយផ្អែកតាមក្រមរដ្ឋប្បវេណី ប្រាតិភោគប្រត្យក្សមាន ២ប្រភេទ សិទ្ធិប្រាតិភោគប្រត្យក្សបែងចែកដោយច្បាប់ (សិទ្ធិឃាត់ទុក,ឯកសិទ្ធិ) និង សិទ្ធិប្រាតិភោគប្រត្យក្សតាមការព្រមព្រៀង (សិទ្ធិលើការបញ្ចាំ, ហ៊ីប៉ូតែក,ប្រាតិភោគដោយអនុប្បទាន)។ សិទ្ធិឃាត់ទុកពុំបានបង្កើតឡើងដោយការព្រមព្រៀងពីភាគីណាមួយ ថានឹងយកវត្ថុមកដាក់ធានាកាតព្វកិច្ចបំណុលអ្វីនោះឡើយ ពោលគឺ ម្ចាស់បំណុលអនុវត្តសិទ្ធិឃាត់ទុកចំពោះវត្ថុតែម្តង ដែលយើងអាចហៅម្ចាស់បំណុលប្រភេទនេះថា ជាម្ចាស់សិទ្ធិឃាត់ទុក ហើយសកម្មភាពឃាត់ទុកនេះអាចមានអានុភាពគតិយុត្តតាមច្បាប់កំណត់ កាលណាបើម្ចាស់សិទ្ធិឃាត់ទុកបំពេញតាមលក្ខខណ្ឌនៃសិទ្ធិឃាត់ទុកបានត្រឹមត្រូវ។ សិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់បំណុលចំពោះវត្ថុឃាត់ទុកនឹងត្រូវបង្កើត នៅពេលកើតមានសិទ្ធិឃាត់ទុក។ ហេតុដូច្នេះ ម្ចាស់សិទ្ធិឃាត់ទុកត្រូវតែកាន់កាប់វត្ថុដោយប្រុងប្រយ័ត្ន និងអនុវត្តសិទ្ធិនេះឱ្យស្របតាមការកំណត់ដោយច្បាប់ បើមិនដូច្នេះទេ កូនបំណុល ឬតតិយអាចនឹងអះអាងអំពីសិទ្ធិកម្មសិទ្ធិ រួចទាមទារឱ្យប្រគល់វត្ថុ (អាចធ្វើតាមតុលាការ) មកវិញជាមិនខាន។ ក៏ប៉ុន្តែ អានុភាពនៃសិទ្ធិឃាត់ទុកលើវត្ថុត្រូវបានបន្តទៅមុខទៀត ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកទទួលបានការកាន់កាប់ចំពោះវត្ថុនោះវិញ ។

### កថាខណ្ឌទី១៖ និយមន័យ

សិទ្ធិឃាត់ទុកសំដៅលើស្ថានភាពដែល អ្នកកាន់កាប់វត្ថុរបស់អ្នកដទៃ មានសិទ្ធិលើបំណុលដែលបានកើតឡើងដោយទាក់ទងនឹងវត្ថុនោះ អ្នកនោះអាចឃាត់ទុកនូវវត្ថុនោះបាន រហូតដល់ពេលដែលខ្លួនទទួលការសងចំពោះសិទ្ធិលើបំណុលនោះ។ ប៉ុន្តែសិទ្ធិឃាត់ទុកមិនត្រូវកើតមានឡើង ប្រសិនបើសិទ្ធិលើបំណុលនោះមិន

ទាន់ដល់ពេលកំណត់ត្រូវសង។[1] សិទ្ធិឃាត់ទុក គឺជាប្រភេទនៃសិទ្ធិមួយក្នុងចំណោមសិទ្ធិប្រាតិភោគប្រត្យក្ស។[2] ចំពោះពាក្យថា ប្រាតិភោគ គឺជាការធានាដល់ម្ចាស់បំណុលក្នុងការប្រមូលឥណទេយ្យរបស់ខ្លួនត្រឡប់មកវិញ ឬជាមធ្យោបាយដើម្បីធានាការសងកាតព្វកិច្ច។[3] ក្នុងន័យនេះ មធ្យោបាយដើម្បីធានាកាតព្វកិច្ចសងបំណុល គឺការឃាត់ទុកវត្ថុរបស់កូនបំណុល ដែលមានទំនាក់ទំនងជាមួយសិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិឃាត់ទុក ការធ្វើបែបនេះ គឺបង្ហាញអំពីទម្រង់នៃការធានាកាព្វកិច្ចដោយវត្ថុ។

## កថាខណ្ឌទី២៖ លក្ខខណ្ឌនៃសិទ្ធិឃាត់ទុក

ដើម្បីឱ្យសិទ្ធិឃាត់ទុកបង្កើតអានុភាពបាន យើងសង្កេតឃើញថា មានធាតុផ្សំ ៤ យ៉ាង ដែលត្រូវលើកយកមកអះអាង។ ធាតុផ្សំទាំង ៤ នេះនឹងត្រូវបកស្រាយនៅចំណុច (ក) វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុក (ខ) សិទ្ធិលើបំណុល (គ )ទំនាក់ទំនងរវាងសិទ្ធិលើបំណុលនឹងវត្ថុ និង (ឃ )ការកាន់កាប់។

### ក. វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុក

វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុក អាចជាចលនវត្ថុ ឬអចលនវត្ថុ។ ដោយលែក សិទ្ធិប្រាតិភោគប្រត្យក្ស មិនអាចយកវត្ថុដែលមិនអាចធ្វើអនុប្បទានបានមកធ្វើជាកម្មវត្ថុបានទេ។[4] ក៏ប៉ុន្តែច្បាប់បានកំណត់យ៉ាងពិសេសចំពោះ សិទ្ធិឃាត់ទុក ដែលសិទ្ធិនេះ មិនរារាំងការបង្កើតសិទ្ធិឃាត់ទុកលើវត្ថុដែលមិនអាចធ្វើអនុប្បទានបានឡើយ។[5]

#### ក.១. ចលនវត្ថុ

ចលនវត្ថុ គឺសំដៅទៅលើវត្ថុដែលអាចផ្លាស់ទីបានមានដូចជា តុ ទូរ កៅអី ទោចក្រយានយន្ត ត្រីចក្រយានយន្តជាដើម។ ចំពោះវត្ថុដែលគ្មានរូបរាងវិញ ប៉ុន្តែអាចប្រើ និងគ្រប់គ្រងបានក៏ត្រូវបានចាត់ជាចលនវត្ថុផងដែរ[6] (ចរន្តអគ្គិសនី , ឧស្ម័នហ្គាស...)។

ឧទាហរណ៍៖ លោក A បានយករថយន្តទៅពិនិត្យនៅយានដ្ឋានជុះជុលឡានរបស់លោក B។ ក្រោយពីលោក B បានពិនិត្យរួចឃើញថាមានបញ្ហា ក៏ជួសជុលឡាននោះ ក្រោយពីជួសជុលហើយលោក A មិនព្រមបងប្រាក់ថ្លៃសេវាជួសជុលឡានឱ្យលោក B ដោយអះអាងថាឡានរបស់ខ្លួនមិនបានខូចគ្រាន់តែយកមកពិនិត្យ។ ដោយហេតុថា រថយន្តជាចលនវត្ថុ ហើយមិនមែនជារបស់លោក B និងម៉្យាងទៀត លោក B កើតមានសិទ្ធិលើបំណុលចំពោះលោក A ។ ដូចនេះ លោក B អាចឃាត់ទុករថយន្តរបស់លោក A ។

[1] មាត្រា ៧៧៤ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[2] មាត្រា ៧៦៧ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[3] សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ បោះពុម្ពដោយទិស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧ ទំព័រទី១៤

[4] មាត្រា ៧៦៨ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[5] មាត្រា ៧៦៨ វាក្យខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[6] មាត្រា១២០ កថាខណ្ឌទី៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ក.២. អចលនវត្ថុ

អចលនវត្ថុ គឺសំដៅលើដីធ្លី និងវត្ថុដែលជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជា អាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍។[7]

ឧទាហរណ៍៖ លោក A បានជួលដីមួយកន្លែងពីលោក B ដោយកំណត់រយៈពេល២ឆ្នាំក្នុងគោលបំណងធ្វើអាជីវកម្ម។ អំឡុងពេលនៃកិច្ចសន្យាកំពុងអនុវត្ត ស្រាប់តែដីនោះមានការបាក់ស្រុត ហើយលោក B មិនព្រមចេញថ្លៃចាក់ដីបំពេញកន្លែងបាក់ស្រុតទេ ដូចនេះលោក A ក៏ចេញប្រាក់ផ្ទាល់ខ្លួនដើម្បីចាក់ដីបំពេញ និងបន្តការធ្វើអាជីវកម្ម។ ក្រោយពេលចប់កិច្ចសន្យា លោក A មានសិទ្ធិទាមទារប្រាក់ដែលខ្លួនបានចេញក្នុងការចាក់ដីបំពេញនោះ ពីលោក B។ ដោយហេតុថា ដីជាអចលនវត្ថុ ហើយមិនមែនជាកម្មសិទ្ធិរបស់ A ហើយ A មានសិទ្ធិលើបំណុល។ ដូចនេះ លោក A អាចឃាត់ទុកដីនោះ។

### ក.៣. វត្ថុដែលមិនអាចធ្វើអនុប្បទានបាន

វត្ថុ សំដៅទៅលើរបស់ដែលមានរូបរាង ជាសារធាតុឧស្ម័ន សារធាតុរាវ និងជាសារធាតុរឹង។[8]

អនុប្បទាន គឺជាការផ្ទេរសិទ្ធិ ឬទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ ដែលជាអនុប្បទានយីទៅឱ្យបុគ្គលម្នាក់ទៀតដែលជា អនុប្បទានិក។[9]

សរុបមកវត្ថុដែលមិនអាចធ្វើអនុប្បទានបាន គឺជារបស់ដែលមានរូបរាងតែមិនអាចធ្វើការផ្ទេរកម្មសិទ្ធិ ឬអំណោយឱ្យអ្នកដទៃបាន។ វត្ថុដែលមិនអាចធ្វើអនុប្បទានបានគឺសំដៅលើចលនវត្ថុ ដូចជា អត្តសញ្ញាណប័ណ្ណ ប័ណ្ណបើកបរ លិខិតឆ្លងដែន និងសញ្ញាបត្រជាដើម។

ឧទាហរណ៍៖ A បានជួលម៉ូតូដើម្បីជិះកំសាន្តនៅហាងរបស់ B ដោយបានយកអត្តសញ្ញាណប័ណ្ណខ្លួនមកដាក់ធានា។ ក្រោយដល់រយៈពេលកំណត់សង A បានយកម៉ូតូទៅសង B វិញតែ A មិនបានយកកាបូបលុយមក ។ ដោយហេតុថា អត្តសញ្ញាណប័ណ្ណជាវត្ថុដែលមិនអាចធ្វើអនុប្បទានបាន នឹងម្យ៉ាងទៀត B កើតមានសិទ្ធិលើបំណុលចំពោះ A ហេតុនេះ B អាចធ្វើការឃាត់ទុកអត្តសញ្ញាណប័ណ្ណរបស់ A បាន។

## ខ. សិទ្ធិលើបំណុល

សិទ្ធិលើបំណុល គឺជាសិទ្ធិទាមទាររបស់បុគ្គលម្នាក់ (ម្ចាស់បំណុល) ចំពោះបុគ្គលម្នាក់ទៀត (កូនបំណុល) ឱ្យផ្តល់នូវតាវកាលិកអ្វីមួយ។[10] ជាធម្មតាបើសិទ្ធិលើបំណុលមិនអាចទាន់យកមកអនុវត្តបាននោះទេ

[7] មាត្រា ១២០ កដាខណ្ឌ ២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[8] មាត្រា ១១៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[9] វចនានុក្រមច្បាប់ ដោយ ហ៊ីង ធីរឫទ្ធិ បោះពុម្ពលើកទី៣ ឆ្នាំ ២០១០ ទំព័រ ៤៤៨

[10] វចនានុក្រមច្បាប់ ដោយ ហ៊ីង ធីរឫទ្ធិ បោះពុម្ពលើកទី៣ ឆ្នាំ២០១០ ទំព័រ៤០៦

ប្រសិនបើពេលវេលានៃការកំណត់សងមិនទាន់ដល់។[11] សិទ្ធិឃាត់ទុក ជាប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្ស។[12] សិទ្ធិប្រាតិភោគប្រត្យក្សត្រូវបានបង្កើតឡើង ដើម្បីធានាកាតព្វកិច្ចដែលមានអត្ថិភាពហើយ ទោះបីជាកាតព្វកិច្ចដែលនឹងកើតឡើងនាពេលអានាគតក៏ដោយក្នុងករណីដែលអាចកំណត់កាតព្វកិច្ចបាន ក៏សិទ្ធិប្រាតិភោគប្រត្យក្សអាចបង្កើតបានដែល...។[13] បានន័យថា កិច្ចសន្យារបស់ភាគីត្រូវតែមានសុពលភាពជាមុនសិន បើមានសុពលភាពគឺមានការអនុវត្តកាតព្វកិច្ចដោយភាគីណាម្ខាង ហើយបើកាតព្វកិច្ចណាមួយមិនបានអនុវត្តតបស្នងដោយភាគីម្ខាងទៀតនោះទេ គឺភាគីដែលបានអនុវត្តកាតព្វកិច្ចរួចនោះនឹងកើតមានសិទ្ធិលើបំណុល (កាតព្វកិច្ចចម្បង[14]) ឯសិទ្ធិលើបំណុលនេះនឹងធ្វើឱ្យសិទ្ធិឃាត់ទុកកើតមានឡើងប្រសិនបើដល់ថ្ងៃកំណត់សង់។

ឧទាហរណ៍៖ ករណី A ជាម្ចាស់រថយន្ត បានយករថយន្តមកឱ្យ B ជួសជុល ដោយសន្យាគ្នាថាល្ងាចនេះរថយន្តជួសជុលរួច ហើយ A អាចមកយករថយន្តវិញបាន។ ហេតុនេះបើ B អនុវត្តកាតព្វកិច្ចជួសជុលរួច ហើយដល់ពេលល្ងាចតាមការកំណត់ទើប B មានសិទ្ធិទាមទារថ្លៃជួសជុល (សិទ្ធិលើបំណុល) ពី A តែបើ A មិនអនុវត្តកាតព្វកិច្ចបង់ថ្លៃជួសជុលទើប B មានសិទ្ធិឃាត់ទុករថយន្តនោះ។

ឧទាហរណ៍៖ ករណី A ជាម្ចាស់រថយន្តបានយករថយន្តទៅឱ្យ B ជួសជុល ដោយសន្យាគ្នាថា ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២២ រថយន្តនឹងជួសជុលរួច ប៉ុន្តែការបង់ប្រាក់ A សុំបង់នៅចុងខែមេសាវិញ។

ក្នុងករណីនេះ ទោះបីជា B បានជួសជុលរថយន្តរួចហើយតាមថ្ងៃកំណត់ក្តី ហើយ A មិនទាន់មកបង់ប្រាក់ ក៏ B មិនអាចអះអាងពីសិទ្ធិឃាត់ទុកចំពោះរថយន្តបានដែរ ព្រោះថាសិទ្ធិលើបំណុលខាងលើមិនទាន់ដល់ថ្ងៃកំណត់សង (ថ្ងៃ៣0 ខែមេសា ឆ្នាំ២០២២) ហេតុនេះសិទ្ធិឃាត់ទុកមិនទាន់កើតឡើងទេ ។

### គ. ទំនាក់ទំនងរវាងសិទ្ធិលើបំណុលនឹងវត្ថុ

ប្រសិនបើអ្នកកាន់កាប់វត្ថុរបស់អ្នកដទៃ មានសិទ្ធិលើបំណុលដែលបានកើតឡើងដោយទាក់ទងនឹងវត្ថុនោះ អ្នកនោះអាចឃាត់ទុកនូវវត្ថុនោះបាន រហូតដល់ពេលដែលខ្លួនទទួលបានការសងចំពោះសិទ្ធិលើបំណុលនោះ។[15] បានន័យថា បន្ទាប់ពីម្ចាស់បំណុលមានសិទ្ធិលើបំណុលរួច ខ្លួនអាចអះអាងអំពីសិទ្ធិឃាត់ទុកលើវត្ថុបាន ក៏ប៉ុន្តែសិទ្ធិឃាត់ទុកដែលម្ចាស់បំណុលកំពុងមានត្រូវតែកើតឡើងដោយទាក់ទងទៅនឹងវត្ថុនោះ។ ហេតុដូច្នេះ ម្ចាស់សិទ្ធិឃាត់ទុកមិនអាចទៅឃាត់វត្ថុដទៃបានទេ ព្រោះថាការឃាត់វត្ថុដទៃដែលមិនបានបង្កើតដោយសិទ្ធិលើបំណុលទេនោះ នាំឱ្យកើតជាការបំពាន់ទៅលើទ្រព្យ ឬកម្មសិទ្ធិរបស់កូនបំណុល។

[11] មាត្រា ៧៧៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[12] មាត្រា ៧៦៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[13] មាត្រា ៧៦៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[14] កាតព្វកិច្ចចម្បង គឺជាកាតព្វកិច្ចដើមនៃកិច្ចសន្យា ដែលបង្កើតដោយម្ចាស់បំណុលនិងកូនបំណុល

[15] មាត្រា ៧៧៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ឧទាហរណ៍៖ A បានយករថយន្តទៅផ្ញើរនៅនឹង B ដោយសន្យាថានឹងបង់ថ្លៃផ្ញើ។ A មិនបានបង់ថ្លៃផ្ញើឱ្យទៅ B តាមការសន្យានោះទេ ហេតុនេះ B មានសិទ្ធិលើបំណុលចំពោះ A ហើយសិទ្ធិលើបំណុលនេះកើតចេញពីការផ្ញើរថយន្ត។

ក្នុងករណីនេះ ថ្លៃផ្ញើរគឺជាសិទ្ធិលើបំណុលដែលកើតឡើងដោយទាក់ទងនឹងវត្ថុ (ឡាន)។ ដូច្នេះ B អាចឃាត់ទុកឡាននោះបាន។

ឧទាហរណ៍៖ A ជាភតិបតី បានជួលផ្ទះឱ្យ B។ ក្នុងអំឡុងពេលនៃកិច្ចសន្យា ជញ្ជាំងផ្ទះមានការប្រេះស្រាំ ហើយ B បានជូនដំណឹងទៅ A ឱ្យធ្វើការជួសជុល ប៉ុន្តែ A មិនព្រមធ្វើការជួសជុលនោះទេ។ B បានធ្វើការជួសជុលជញ្ជាំងនោះ ហើយ A មិនបានបង់ប្រាក់ថ្លៃជួសជុលទេ ហេតុនេះ B មានសិទ្ធិលើបំណុលចំពោះ A ហើយសិទ្ធិលើបំណុលនេះកើតចេញពីការជួសជុលផ្ទះ។

ក្នុងករណីនេះ ថ្លៃជួសជុលផ្ទះ គឺជាសិទ្ធិលើបំណុល កើតឡើងដោយទាក់ទងនឹងវត្ថុ (ផ្ទះ)។ ដូច្នេះ B អាចឃាត់ទុកផ្ទះនោះបាន។

ឧទាហរណ៍៖ A និងមិត្តភក្តិមួយក្រុមបានជិះរថយន្តមកកំសាន្តនៅខារ៉ាអូខេមួយកន្លែង បន្ទាប់ពីផឹកស៊ីរួចរាល់ ពួកគេមិនបានបង់ថ្លៃសេវាកម្មកំសាន្តនោះទេពីព្រោះ A មិនបានយកកាបូបលុយមកពីផ្ទះ។

ក្នុងករណីបែបនេះ វាខុសពីឧទាហរណ៍ទាំងពីរខាងលើ រថយន្តពុំមានទំនាក់ទំនងនឹងសិទ្ធិលើបំណុលទេ (ថ្លៃកំសាន្ត) មានន័យថា សិទ្ធិលើបំណុលថ្លៃកំសាន្តមិនបានកើតឡើងដោយទាក់ទងនឹងរថយន្តទេ។ ហេតុដូច្នេះ ម្ចាស់ហាងមិនអាចអះអាងសិទ្ធិឃាត់ទុកចំពោះរថយន្តរបស់ A បានឡើយ។

ដោយឡែកទាក់ទងទៅនឹងមនុស្សវិញ គឺមិនអាចក្លាយទៅជាកម្មវត្ថុនៃសិទ្ធិឃាត់ទុកបាននោះដែរពីព្រោះកម្មវត្ថុ នៃសិទ្ធិឃាត់ទុក គឺជាវត្ថុ ដូចដែលបានបកស្រាយក្នុងផ្នែកទី១ កថាខណ្ឌទី២ ចំណុច **ក. វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុក** ខាងលើ។ ចំពោះមនុស្ស ច្បាប់មិនបានកំណត់ថាជាវត្ថុឡើយ។ ហេតុដូច្នេះ ម្ចាស់ហាងមិនអាចឃាត់ខ្លួន A ឬមិត្តភក្តិរបស់ A ទុកបានទេ។

### ឃ. ការកាន់កាប់

ការកានកាប់ សំដៅទៅលើការក្តាប់ទុកវត្ថុ។[16] ការក្តាប់ទុកសំដៅទៅលើការគ្រប់គ្រងលើរូបវត្ថុតាមការជាក់ស្តែង ទោះដោយចំពោះក្តី ឬដោយប្រយោលក្តី។[17] សិទ្ធិឃាត់ទុកត្រូវរំលត់ ពេលណាម្ចាស់សិទ្ធិឃាត់ទុកបានបាត់បង់នូវការកាន់កាប់វត្ថុឃាត់ទុកនោះ។[18] ដូចនេះម្ចាស់សិទ្ធិឃាត់ទុកត្រូវតែធានាឱ្យបាននូវការកាន់កាប់

[16] មាត្រា ២២៧ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[17] មាត្រា ២២៧ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[18] មាត្រា ៧៨០ កថាខណ្ឌទី១ វាក្យខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ទៅលើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុក បើមិនដូច្នេះទេសិទ្ធិឃាត់ទុកនឹងត្រូវរំលត់ ព្រោះវត្ថុមិនស្ថិតក្រោមការគ្រប់គ្រងរបស់ម្ចាស់សិទ្ធិឃាត់ទុកទៀតឡើយ។

ឧទាហរណ៍៖ លោក A បានយករថយន្តទៅផ្ញើនៅកន្លែងរបស់លោក B ដោយសន្យាថា នៅថ្ងៃអាទិត្យក្រោយខ្លួននឹងមកយកវិញ ហើយខ្លួននឹងបង់ប្រាក់ ៥០$ ជូនលោក B។ លុះដល់ថ្ងៃកំណត់លោក A បានមកយករថយន្តវិញ ហើយបង់ប្រាក់ឱ្យលោក B តែ ១០$ ប៉ុណ្ណោះ។ លោក B មិនសុខចិត្តក៏ឃាត់រថយន្តទុកមិនឱ្យលោក A យកវិញបានទេ លុះត្រាតែលោក A បង់ប្រាក់គ្រប់ចំនួនតាមការសន្យាខាងលើ។

ក្នុងករណីនេះ លោក B បានកាន់កាប់ដោយផ្ទាល់ទៅលើរថយន្ត។ ក៏ប៉ុន្តែ ប្រសិនបើលោក B មានមូលហេតុណាមួយ ហើយក៏ប្រគល់ការកាន់កាប់ចំពោះរថយន្តនោះទៅតតិយជន នាំឱ្យយើងអាចនិយាយថា លោក B កាន់កាប់ដោយប្រយោល។ ហេតុដូច្នេះ តាមរយៈករណីទាំងពីរខាងលើនេះ លោក B នៅតែអាចបន្តអះអាងអំពីសិទ្ធិឃាត់ទុកចំពោះ A ដដែល។

### ឃ.១ ការទទួលបានការកាន់កាប់មកវិញ

យ៉ាងណាមិញ បើម្ចាស់សិទ្ធិឃាត់ទុក បានបាត់បង់នូវការកាន់កាប់វត្ថុឃាត់ទុកក៏ដោយ ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកនោះ ទទួលបានការកាន់កាប់មកវិញ តាមបញ្ញត្តិនៃមាត្រា ២៣៧ (សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ) នៃក្រមរដ្ឋប្បវេណី ការកាន់កាប់នោះត្រូវបានចាត់ទុកថា បានបន្តរហូតមក។[19] ហេតុដូច្នេះ ដើម្បីទទួលបានការកាន់កាប់មកវិញ ម្ចាស់សិទ្ធិឃាត់ទុកអាចធ្វើបណ្ដឹងទាមទារទៅតុលាការដោយផ្អែកលើសិទ្ធិកាន់កាប់បាន។

ឧទាហរណ៍៖ លោក A បានខ្ចីម៉ូតូពីលោក C ស្រាប់តែមានបញ្ហានៅពេលកំពុងធ្វើដំណើរ រួចគាត់ក៏បណ្ដើរម៉ូតូចូលការ៉ាសជួសជុលរបស់លោក B។ ដោយលោក A មិនមានប្រាក់គ្រប់ចំនួនដើម្បីបង់ថ្លៃសេវាជួសជុល នាំឱ្យលោក B ធ្វើការឃាត់ទុកម៉ូតូនោះសិន។ ដំណឹងនេះបានដឹងទៅដល់លោក C ដែលជាម្ចាស់វត្ថុផ្ទាល់ រួចលោក C ក៏ប្រញាប់ចេញទៅជួបលោក B ហើយក៏បានប្រកែកមិនព្រមឱ្យលោក B ឃាត់ទុកវត្ថុនោះតទៅទៀតបានទេ ដោយបានអះអាងពីភស្តុតាងបញ្ជាក់ថាខ្លួនជាម្ចាស់កម្មសិទ្ធិចំពោះវត្ថុ បន្ទាប់មកលោក C បានប្រាប់លោក B ថា "ខ្ញុំមិនមែនជាកូនបំណុលអ្នកឯងទេ ម៉ូតូនេះជាកម្មសិទ្ធិរបស់ខ្ញុំ អ្នកណាជាអ្នកជំពាក់បំណុលសូមទៅទារពីអ្នកហ្នឹងទៅ អ្នកឯកគ្មានសិទ្ធិមកឃាត់ទុកម៉ូតូខ្ញុំទេ" រួចលោក C ក៏ឡើងម៉ូតូ ហើយបើកចាក់ចេញទៅ។

ក្នុងករណីនេះ លោក B ត្រូវបានគេដក់ហូតការកាន់កាប់ចំពោះវត្ថុឃាត់ទុក នាំឱ្យសិទ្ធិឃាត់ទុកត្រូវបាត់បង់។ ទោះជាយ៉ាងដូច្នេះក្តី ប្រសិនបើលោក B ដាក់ពាក្យបណ្ដឹងទាមទារវត្ថុឃាត់ទុកនោះមកវិញ ហើយតុលាការសម្រេចតាមការទាមទាររបស់ B នោះអានុភាពនៃសិទ្ធិឃាត់ទុកត្រូវបានបន្ត។

[19] មាត្រា ៧៨០ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ឃ.២. ការកាន់កាប់ដោយអំពីអនីត្យានុគោល

ចំពោះការកាន់កាប់ដែលកើតពីអំពើអនីត្យានុគោលវិញ គឺមិនអាចអះអាចអំពីសិទ្ធិឃាត់ទុកបានឡើយ។[20] អំពើអនីត្យានុគោល គឺជាអំពើដែលបំពាន់ដោយខុសច្បាប់លើសិទ្ធិ ឬផលប្រយោជន៍អ្នកដទៃដោយកំហុសចេតនា ឬអចេតនា។[21] ការបំពាន់ដោយខុសច្បាប់លើសិទ្ធិ ឬផលប្រយោជន៍អ្នកដទៃ សំដៅទៅលើអំពើដូចជា ការលួច ឆក់ប្លន់ ការបន្លំ ការធ្វើឱ្យខូចខាត់ ឬអំពើខុសច្បាប់ផ្សេងៗទៀតដែលបង្ករព្យសនកម្មទៅលើទ្រព្យសម្បត្តិរបស់នណាម្នាក់។ ដូចនេះ ប្រសិនបើសិទ្ធិឃាត់ទុកត្រូវបានអះអាងតាមរយៈការកាន់កាប់ដោយខុសច្បាប់ដូចបានរៀបរាប់ខាងលើ នាំឱ្យការអះអាងពីសិទ្ធិឃាត់ទុកនេះមិនត្រូវបានទទួលស្គាល់ដោយច្បាប់ឡើយ។

ឧទាហរណ៍៖ លោក A បានលួចរថយន្តរបស់លោក B ហើយក៏បានយកទៅជួសជុល កែរច្នៃ និងបំពាក់ដោយប្រព័ន្ធទំនើបផ្សេងៗ នៅឯយានដ្ឋានរបស់លោក C។ លោក C បានបំពេញកាតព្វកិច្ចជួសជុល កែរច្នៃ និងបំពាក់ប្រព័ន្ធទំនើបចំពោះរថយន្តនោះរួច ស្រាប់តែលោក B បានចូលមកយានដ្ឋានរបស់គាត់ ហើយក៏អះអាងអំពីសិទ្ធិកម្មសិទ្ធិចំពោះរថយន្តនោះ ហើយទាមទារឱ្យ C ប្រគល់រថយន្តមកវិញ។

ក្នុងករណីនេះ លោក C បានទទួលផលចោរកម្មពី A ដែរផលនេះទៀតសោកកើតចេញពីអំពើអនីត្យានុគោល។ បើទោះបីជាលោក C បានអនុវត្តកាតព្វកិច្ចចំពោះវត្ថុនោះ ឬធ្វើឱ្យវត្ថុកើនតម្លៃក្តីក៏លោក C មិនអាចអះអាងអំពីសិទ្ធិឃាត់ទុក ហើយក៏មិនអាចទាមទារសំណង់អ្វីទាំងអស់ពីលោក B បានដែរ ព្រោះការកាន់កាប់របស់លោក C គឺជាការកាន់កាប់ដោយខុសច្បាប់។

## ផ្នែកទី២៖ អានុភាពនៃសិទ្ធិឃាត់ទុក

អានុភាពនៃសិទ្ធិឃាត់ទុកនឹងត្រូវកើតមានឡើងដល់ម្ចាស់បំណុល កាលណាលក្ខខណ្ឌនៃសិទ្ធិឃាត់ទុកត្រូវបានបំពេញ ហើយសិទ្ធិឃាត់ទុកនឹងបង្កើតអានុភាពនៃសិទ្ធិ ករណីកិច្ច និងចំណង់គិតិយុត្តរវាងភាគីទាំងពីរ គឺម្ចាស់សិទ្ធិឃាត់ទុក និង កូនបំណុលនៃសិទ្ធិឃាត់ទុក។ តាមរយៈអានុភាពនេះ ប្រសិនបើម្ចាស់បំណុលផ្ទេរសិទ្ធិរបស់ខ្លួន តើសិទ្ធិឃាត់ទុកនឹងត្រូវបន្តទៅឱ្យអ្នកទទួលដែលឬទេ?

### កថាខណ្ឌទី១៖ សិទ្ធិរបស់ម្ចាស់បំណុលតាមរយៈសិទ្ធិឃាត់ទុក

#### ក. សិទ្ធិទទួលបានការសង

សិទ្ធិទទួលបានការសង គឺជាសិទ្ធិដែលកំណត់ដោយច្បាប់ ថាតើម្ចាស់សិទ្ធិលើបំណុលណាមួយត្រូវទទួលបានការទូរទាត់សិទ្ធិលើបំណុលដោយអត្តិភាព ក្នុងករណីដែលម្ចាស់បំណុលអនុវត្តសិទ្ធិចំពោះកូនបំណុលរួមគ្នា។

[20] មាត្រា ៧៧៤ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[21] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ បោះពុម្ពដោយទិស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧ ទំព័រទី២៩

នៅពេលខ្លះយើងសង្កេតឃើញថា ម្ចាស់បំណុលអាចមានច្រើននាក់ ហើយមានកូនបំណុលមានតែម្នាក់រួមគ្នា ហេតុនេះ ប្រាកដជាអាចមានការដណ្តើមយកវត្ថុដែលជាទ្រព្យរបស់កូនបំណុល។ ដើម្បីកំណត់អាទិភាព ឬលំដាប់នៃម្ចាស់បំណុលដែលត្រូវទទួលបានការសងមុន ទើបច្បាប់ចែងអំពីម្ចាស់បំណុលនៃសិទ្ធិប្រាតិភោគប្រត្យក្ស (សិទ្ធិឃាត់ទុក ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក និងសិទ្ធិប្រាតិភោគដោយអនុប្បទាន) និង ម្ចាស់បំណុលធម្មតា (ការទិញលក់ ការខ្ចីបរិភោគ ភតិសន្យា ការខ្ចីប្រើ កិច្ចសន្យាបញ្ញើ កិច្ចសន្យាម៉ៅការ កិច្ចសន្យាការងារ សេចក្តីចម្រើនឥតហេតុ និងអំពើអនិត្យានុគោល ជាដើម) ។

អានុភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សត្រូវមានលើវត្ថុ ឬសិទ្ធិដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្សទាំងអស់ រហូតដល់ពេលដែលម្ចាស់សិទ្ធិប្រាតិភោគបានទទួលសំណងនៃសិទ្ធិលើបំណុលទាំងអស់។[22] ប្រសិនបើម្ចាស់សិទ្ធិប្រាតិភោគមិនបានទទួលសំណងនៃសិទ្ធិលើបំណុលទេ អ្នកនោះអាចអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្សនេះតាមនីតិវិធីដែលច្បាបប់បានកំណត់បាន (មាត្រា ៧៧៣ ក្រមរដ្ឋប្បវេណី ២០០៧)។[23] ហេតុដូច្នេះ ម្ចាស់បំណុល នៃសិទ្ធិប្រាតិភោគប្រត្យក្សត្រូវមានអានុភាពទទួលបានការសងមុនម្ចាស់បំណុលធម្មតា។

ក្នុងករណីដែលវត្ថុដែកជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្សបានធ្វើអនុប្បទានទៅតតិយជន ម្ចាស់សិទ្ធិប្រាតិភោគនោះ អាចយកអានុភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សមកតតាំងចំពោះតតិយជននោះបាន លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា៨០៧ (អានុភាពតាមចំពោះតតិយជនដែលបានធ្វើលទ្ធកម្ម) ស្តីពីឯកសិទ្ធិ និងមាត្រា ៨៩៤ (ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកបង្កើត) ស្តីពីប្រាតិភោគដោយអនុប្បទាន នៃក្រមរដ្ឋប្បវេណី។ ប៉ុន្តែតម្រូវឱ្យម្ចាស់សិទ្ធិប្រាតោភោគនោះមានគ្រប់គ្រាន់នូវល័ក្ខខ័ណ្ឌតតាំង។[24]

ចំពោះសិទ្ធិឃាត់ទុកវិញច្បាប់ក៏បានបញ្ញត្តិថា អាចមានអានុភាពកាន់កាប់វត្ថុដែលបានឃាត់ទុកនោះរហូតដល់ពេលដែលខ្លួនអាចទទួលបានការសងសំណង់។[25] បានន័យថា ម្ចាស់សិទ្ធិឃាត់ទុកអាចអះអាងអំពីសិទ្ធិឃាត់ទុក ចំពោះកូនបំណុល ឬកម្មសិទ្ធិករ ឬតតិយជនផ្សេងទៀតបានថាខ្លួននឹងមិនប្រគល់វត្ថុឃាត់ទុកឱ្យនោះទេ រហូតដល់ខ្លួនទទួលបានការសង។ ហេតុនេះ ទោះបីជាម្ចាស់បំណុលផ្សេងទៀត បានទទួលសិទ្ធិជាអាទិភាពក៏ដោយ ក៏មិនអាចអនុវត្តសិទ្ធិចំពោះវត្ថុដែលជាប់សិទ្ធិឃាត់ទុកបានឡើយ។[26]

[22] មាត្រា ៧៧១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[23] នីតិវិធីដែលច្បាប់កំណត់ត្រូវអនុវត្តតាមជំពូកទី៣ (បញ្ញត្តិស្តីពីការអនុវត្តសិទ្ធិប្រាតិភោគ) ពីមាត្រា ៤៩៦ ដល់ ៥២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[24] មាត្រា ៧៧៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[25] មាត្រា ៧៧៤ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[26] សៀវភៅ កម្រងមេរៀន ចងក្រងដោយ កម្មវិធីវិភាគទានច្បាប់ បោះពុម្ពលើកទី៤ ឆ្នាំ២០១៨ ទំព័រទី៩

ឧទាហរណ៍៖ B ជាម្ចាស់សិទ្ធិឃាត់ទុកចំពោះរថយន្តរបស់ A ចំណែកឯ C វិញជាម្ចាស់បំណុលធម្មតា។ ម្ចាស់បំណុលទាំងពីរបានធ្វើការអនុវត្តសិទ្ធិរៀងៗខ្លួនដើម្បីអនុវត្តដោយបង្ខំចំពោះរថយន្តរបស់ A (កូនបំណុលរួម)។

ក្នុងករណីបែបនេះ B គឺជាម្ចាស់សិទ្ធិឃាត់ទុក ហើយ C វិញគឺជាម្ចាស់បំណុលធម្មតាតែប៉ុណ្ណោះ បើយោងតាមការបកស្រាយខាងលើ នាំឱ្យ B ត្រូវទទួលបានការសងមុនចំពោះការអនុវត្តដោយបង្ខំចំពោះទ្រព្យរបស់កូនបំណុល ព្រោះថា សិទ្ធិឃាត់ទុកជាប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្ស ហើយ B ក៏ជាអ្នកកាន់កាប់វត្ថុរបស់កូនបំណុលថែមទៀតផង។

**ខ.សិទ្ធិទទួលសំណាច់ពីផលដោយអទិភាព**

ម្ចាស់សិទ្ធិឃាត់ទុក អាចទទួលផលពីវត្ថុដែលឃាត់ទុក និងអាចយកផលនោះមកកាត់សិទ្ធិលើបំណុលដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន។[27] ពាក្យថា "ផល" ត្រូវបានបែងចែងជាពីរដោយផ្អែកតាមក្រមរដ្ឋប្បវេណីកម្ពុជា គឺផលធម្មជាតិ និងផលស៊ីវិល។ បានន័យថា ម្ចាស់សិទ្ធិឃាត់ទុក នៅពេលដែលខ្លួនឃាត់វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុករួច ខ្លួនមានសិទ្ធិយកផលដែលបានកើតមានឡើងពីវត្ថុឃាត់ទុក (ផលធម្មជាតិ) មកកាត់សិទ្ធិលើបំណុល ឬយកវត្ថុឃាត់ទុកនោះទៅបង្កើតឱ្យចេញជាផល (ផលស៊ីវិល) ដើម្បីទូទាត់ជាមួយសិទ្ធិលើបំណុលដែលខ្លួនមានដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងៗទៀត។ ម៉្យាងវិញទៀត ផលដែលទទួលបានដូចខាងលើនេះ ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ហើយប្រសិនបើមានសំណល់ត្រូវយកមកកាត់ប្រាក់ដើម។[28] ដូចនេះ ក្នុងករណីដែលបំណុលមិនមានផ្ជាប់ការប្រាក់ទេនោះ ម្ចាស់សិទ្ធិឃាត់ទុកអាចយកផលដែលខ្លួនទទួលបានពីវត្ថុមកកាត់សិទ្ធិលើបំណុលជាមួយប្រាក់ដើមតែម្តង។

ឧទាហរណ៍៖ ធីតាបានយកសត្វឆ្មាចិញ្ចឹមរបស់ខ្លួនទៅឱ្យអ្នកគ្រូពេទ្យសត្វព្យាបាលជម្ងឺ។ បន្ទាប់ពីព្យាបាលរួចធីតាមិនមានលទ្ធភាពបង់ប្រាក់ចំនួន ៣០០$ ឱ្យទៅអ្នកគ្រូពេទ្យទេ ដោយធីតាសន្យាថានឹងយកប្រាក់មកសងឱ្យគ្រប់ចំនួននៅរយៈពេល ១០ថ្ងៃក្រោយ។ ដូចនេះអ្នកគ្រូពេទ្យក៏ឃាត់ឆ្មាទុកសិនដើម្បីធានាបំណុលខ្លួន។ លុះផុតរយៈពេល១០ថ្ងៃមិនឃើញធីតាមកទូទាត់បំណុលឡើយ ហើយខណៈពេលនោះដែរចំពេលដែលសត្វឆ្មាកើតកូនតែម្តងបានចំនួន ៨ក្បាល់ ដោយកូនឆ្មា ៨ក្បាល់មានតម្លៃ ២០០$ ហើយអ្នកគ្រូពេទ្យក៏មានបំណង់ចងទិញកូនឆ្មាមកចិញ្ចឹមផងដែរ។

ហេតុដូច្នេះ អ្នកគ្រូពេទ្យអាចយកកូនឆ្មា ៨ក្បាល់ មកកាត់សិទ្ធិលើបំណុលដែលខ្លួនមាន នាំឱ្យសិទ្ធិលើបំណុលដែលនៅសល់គឺចំនួន ១០០$ ទៀត។

[27] មាត្រា ៧៧៥ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[28] មាត្រា ៧៧៥ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ឧទាហរណ៍៖ ពូសុខបានយករថយន្តទៅការ៉ាសពូសំ ដើម្បីឱ្យគាត់ជួសជុល។ តម្លៃជួសជុលអស់ ១០០០$ តែពូសុខមានតែ ៨០០$ ទេក៏យកបង់ឱ្យពូសំសិន ហើយសន្យាថា ៧ថ្ងៃក្រោយខ្លួននឹងសង ២០០$ ទៀត។ នាំឱ្យសិទ្ធិលើបំណុលនៅសល់គឺ ២០០$ តែពូសំសូមឃាត់ទុករថយន្តសិនដើម្បីធានាបំណុលដែលនៅសល់។ លុះរយៈពេល ៧ថ្ងៃក្រោយពូសុខប្រាប់ថាខ្លួននៅតែមិនទាន់មានលទ្ធិភាពសងនៅឡើយទេ ហើយពូសំក៏ស្នើសុំឱ្យពូសុខយល់ព្រមឱ្យខ្លួនយករថយន្តនោះទៅជួលឱ្យផលិតករកុន ពេលនោះពូសុខក៏អនុញ្ញាត។

ក្នុងករណីនេះ ពូសំបានជួលរថយន្ត និងទទួលបានប្រាក់ ១០០$ ហេតុដូច្នេះ សិទ្ធិលើបំណុលដែលនៅសល់គឺ ១០០$ ទៀត។

**គ.សិទ្ធិទាមទារឱ្យសងសោហ៊ុយ**

ចំពោះសោហ៊ុយចាំបាច់សម្រាប់ការគ្រប់គ្រង និងថែរក្សាវត្ថុ ម្ចាស់សិទ្ធិឃាត់ទុកដែលបានចេញចំណាយនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងចំណាយវិញភ្លាមបាន។[29] ទាក់ទងនឹងសោហ៊ុយចាំបាច់សម្រាប់ការគ្រប់គ្រង និងថែរក្សាវត្ថុដែលឃាត់ទុក ហើយប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកបានចេញចំណាយបង្កើនតម្លៃចំពោះវត្ថុ ម្ចាស់សិទ្ធិឃាត់ទុកអាចទាមទារឱ្យកម្មសិទ្ធិករសងចំណាយទាំងអស់ដែលខ្លួនបានចេញ ឬតម្លៃប្រាក់កំណើន ដែលមានអត្ថិភាពតាមការទាមទារជ្រើសរើសរបស់កម្មសិទ្ធិករ ក្នុងករណីកំណើននោះនៅតែមាន។ ប៉ុន្តែតុលាការអាចកំណត់ពេលវេលាសមរម្យដើម្បីសងតាមការទាមទាររបស់កម្មសិទ្ធិករបាន។[30]

ម្ចាស់សិទ្ធិឃាត់ទុកអាចទាមទារនូវសំណងនៃសោហ៊ុយដែលខ្លួនបានចំណាយទៅលើវត្ថុឃាត់ទុកនោះបាន ។ បាននន័យថា ការបែងចែករវាងសោហ៊ុយចាំបាច់សម្រាប់ការគ្រប់គ្រង និងថែរក្សាវត្ថុ និង សោហ៊ុយបង្កើនតម្លៃ ចំពោះសោហ៊ុយចាំបាច់សម្រាប់ការគ្រប់គ្រង និងថែរក្សាវត្ថុ ម្ចាស់សិទ្ធិឃាត់ទុកដែលបានចេញចំណាយនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងចំណាយវិញភ្លាមបាន។ ម៉្យាងវិញទៀត ច្បាប់អនុញ្ញាតឱ្យម្ចាស់សិទ្ធិឃាត់ទុកទាមទារឱ្យកម្មសិទ្ធិករសងសោហ៊ុយបង្កើនតម្លៃវិញ ប៉ុន្តែករណីកិច្ចត្រូវសងរបស់កម្មសិទ្ធិករ ត្រូវបានបន្ធូរ។ ករណីដែលម្ចាស់សិទ្ធិឃាត់ទុកត្រូវបានអនុញ្ញាតឱ្យទាមទារសងសោហ៊ុយបង្កើនតម្លៃ ត្រូវបានកម្រិតតែករណីដែលកំណើនតម្លៃនោះនៅតែមាន។ ចំណែកឯទំហំនៃការទាមទារសំណងកម្មសិទ្ធិករដែលមានករណីយកិច្ចសង អាចជ្រើសរើសចំណាយទាំងអស់ដែលខ្លួនបានចេញ ឬតម្លៃប្រាក់កំណើនដែលមានអត្ថិភាពបាន (ក្នុងចំណោមនេះ កម្មសិទ្ធិករអាចជ្រើសរើសចំនួនទឹកប្រាក់តិចជាងបាន) ។

[29] មាត្រា ៧៧៧ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[30] មាត្រាដដែល កថាខណ្ឌទី២

ឧទាហរណ៍៖ B ជាម្ចាស់សិទ្ធិឃាត់ទុកបានយករថយន្តដែលបានឃាត់ទុកពី A ទៅលាងសំអាត ព្រមទាំងប្តូរប្រេងមាស៊ីន នឹងបានចាក់សាំងផងដែល ព្រោះថាបើគ្រឿងម៉ាស៊ីនមួយគ្រឿងមិនបានបើកដំណើរការយូរថ្ងៃ វាអាចនឹងគាំង។

ក្នុងករណីនេះ B បានចេញសោហ៊ុយផ្ទាល់ខ្លួនក្នុងការគ្រប់គ្រង និងថែរក្សារថយន្តរបស់ A។ ដូចនេះ B អាចទាមទារឱ្យ A សងសោហ៊ុយចំណាយដែលខ្លួនបានចំណាយកន្លងមក។

ឧទាហរណ៍៖ A បានយកគោដែលមានតម្លៃ ២,០០០,០០០៛ ទៅព្យាបាល។ លោក B ជាគ្រូពេទ្យសត្វបានព្យាបាលគោរបស់ A ជាសះស្បើយ ហើយថ្លៃព្យាបាលអស់ចំនួន ៤០០,០០០៛ ដោយលោក A ពុំមានប្រាក់បង់គ្រប់ចំនួន នោះខ្លួនក៏ស្នើសុំសង់ក្នុងរយៈពេល ៣០ថ្ងៃទៀត។ ក្នុងករណីនេះ B កើតមានសិទ្ធិលើបំណុលចំនួន ៤០០,០០០៛ ហើយក៏បានធ្វើការឃាត់ទុកសត្វគោ។ លុះរយៈពេល ៤០ថ្ងៃក្រោយមក មិនឃើញ A មកសង់បំណុលឡើយ ជាហេតុនាំឱ្យ B ទទួលរងបន្ទុកចំណាយអស់ដល់ទៅចំនួន ២០០,០០០៛ ក្នុងការថែរក្សាសត្វគោនោះ។ ទន្ទឹមនឹងការមើលថែរក្សាសត្វគោអស់រយៈពេល៤០ថ្ងៃ សត្វគោនោះមានសុខភាពល្អប្រសើរ និងធំធាត់ជាងមុន ដែលជាហេតុនាំឱ្យតម្លៃរបស់សត្វគោកើនដល់ចំនួន ២,១៥០,០០០៛។

ក្នុងករណីនេះយើងសង្កេតឃើញថា កើតមានសោហ៊ុយបង្កើតតម្លៃចំនួន ១៥០,០០០៛ ហើយចំពោះសោហ៊ុយក្នុងការមើលថែរក្សាសិត្វគោវិញមានដល់ទៅចំនួន ២០០,០០០៛ ដែលជាចំនួនច្រើនជាងសោហ៊ុយបង្កើនតម្លៃដល់ទៅ ៥០,០០០៛។ បើយើងអនុវត្តតាមការបកស្រាយខាងលើ នោះកម្មសិទ្ធិករមានសិទ្ធិក្នុងការជ្រើសរើសសងសោយហ៊ុយណាដែលតិចជាងបាន គឺអាចសង់សោហ៊ុយបង្កើនតម្លៃចំនួន ១៥០,០០០៛។

**ឃ. ការអនុវត្តដោយបង្ខំដោយសិទ្ធិឃាត់ទុក**

សិទ្ធិឃាត់ទុក ជាប្រភេទមួយក្នុងចំណោមសិទ្ធិប្រាតិភោគ ប៉ុន្តែការអនុវត្តសិទ្ធិឃាត់ទុកតាមផ្លូវតុលការគឺមានគោលបំណងតែប្តូរជាប្រាក់តែប៉ុណ្ណោះ។ ម្ចាស់សិទ្ធិឃាត់ទុក អាចរក្សាទុកវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុកដើម្បីដាក់សម្ពាធដល់កូនបំណុលឱ្យអនុវត្តកាតព្វកិច្ចពេលណាមួយបាន ហើយបើកូនបំណុលនៅតែមិនព្រមសង ឬមានការលំបាកក្នុងការថែរក្សាវត្ថុឃាត់ទុកនោះ ម្ចាស់សិទ្ធិឃាត់ទុកអាចធ្វើការអនុវត្តសិទ្ធិឃាត់ទុកបានតាមផ្លូវតុលាការ ហៅថា ការអនុវត្តដោយបង្ខំដោយសិទ្ធិឃាត់ទុក។[31] ការអនុវត្តដោយបង្ខំដោយសិទ្ធិឃាត់ទុកមានគោលបំណង់ឱ្យកូនបំណុលសង ឬអនុវត្តនីតិវិធីប្តូរជាប្រាក់។ ចំពោះការលក់ដោយបង្ខំដោយសិទ្ធិឃាត់ទុកតម្រូវឱ្យមានលិខិតអនុវត្តជាមុនសិន។[32] ដោយឡែក ការអនុវត្តសិទ្ធិឃាត់ទុកចំពោះចលនវត្ថុវិញ ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកបានដាក់ចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុក ឬបានដាក់ឯកសារដែលបញ្ជាក់ថា អ្នក

[31] មាត្រា ៧៧៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងមាត្រា ៤៩៩ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[32] មាត្រា ៣៥០ និង មាត្រា ៤៩៦ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

កាន់កាប់ចលនវត្ថុបានយល់ព្រមចំពោះការរឹបអូស ក៏ការអនុវត្តសិទ្ធិឃាត់ទុកអាចដំណើរការបានដែរ ដោយមិនចាំបាច់មានលិខិតអនុវត្តនោះឡើយ។[33]

**ឃ.១. វត្ថុឃាត់ទុកជាកម្មសិទ្ធិរបស់កូនបំណុល**

វត្ថុឃាត់ទុកជារបស់កូនបំណុល សំដៅទៅលើស្ថានភាពដែលកូនបំណុលមានសិទ្ធិកម្មសិទ្ធិទៅលើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុក។ ស្ថានភាពគតិយុត្តបែបនេះ បានបើកសិទ្ធិឱ្យម្ចាស់សិទ្ធិឃាត់ទុកអនុវត្តសិទ្ធិលក់ដោយបង្ខំតាមផ្លូវតុលាការប្រសិនបើមានមូលហេតុសមស្រប ឬទទួលបានការអនុញ្ញាតពីតុលាការ។ ការអនុវត្តដោយបង្ខំតាមផ្លូវតុលាការនេះ កូនបំណុលមិនអាចអះអាងអំពីសិទ្ធិកម្មសិទ្ធិមកតតាំងជាមួយម្ចាស់សិទ្ធិឃាត់ទុកឱ្យប្រគល់វត្ថុ ឬលុបចោលការអនុវត្តដោយបង្ខំបានឡើយ។

ឧទាហរណ៍៖ លោក A បានយកសត្វគោទៅឱ្យលោក B ព្យាបាល ដោយសន្យាថាក្នុងរយៈពេល១០ថ្ងៃ A នឹងបង់ប្រាក់ថ្លៃព្យាបាលចំនួន ៣០០ដុល្លា ដល់ B។ ដល់រយៈពេលកំណត់សង A មិនមានលទ្ធភាពសងគ្រប់ចំនួននោះទេ សងបានត្រឹមតែ ១០០ដុល្លា ដូចនេះបំណុលដែល A ជំពាក់ B នៅសល់ ២០០ដុល្លា ហើយ A បានសុំ B រយៈពេល៥ថ្ងៃទៀតខ្លួននឹងសងគ្រប់ចំនួន នាំឱ្យលោក B ឃាត់ទុកសត្វគោនោះដើម្បីធានាបំណុល។ លើសរយៈពេល៥ថ្ងៃហើយ មិនឃើញ A មកសងប្រាក់ ព្រមទាំងមានការពិបាកក្នុងការរកចំណីឱ្យសត្វគោនោះស៊ី ហើយថែមទាំងពិបាកក្នុងការថែទាំងវាទៀតនោះ B ក៏បានស្នើរសុំទៅតុលាការក្នុងការអនុវត្តដោយបង្ខំដោយសិទ្ធិឃាត់ទុក ដោយយកសត្វគោនោះទៅលក់។ តុលាការក៏បានអនុញ្ញាត ហើយយកវត្ថុឃាត់ទុកនោះទៅអនុវត្តដោយប្តូរជាប្រាក់។

**ឃ.២. វត្ថុឃាត់ទុកមិនមែនជាកម្មសិទ្ធិរបស់កូនបំណុល**

ការកាន់កាប់វត្ថុឃាត់ទុកដែលកូនបំណុលគ្មានសិទ្ធិកម្មសិទ្ធិ គឺជាស្ថានភាពមួយដែលម្ចាស់សិទ្ធិឃាត់ទុកកំពុងតែកាន់កាប់វត្ថុរបស់តតិយជនដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុកតាមរយៈសិទ្ធិលើបំណុលរបស់ខ្លួនចំពោះកូនបំណុល។ បើទោះជា ម្ចាស់សិទ្ធិឃាត់ទុកមានមូលហេតុសមស្របក្នុងការអនុវត្តសិទ្ធិលក់ដោយបង្ខំក៏ដោយ ម្ចាស់សិទ្ធិឃាត់ទុកនឹង ត្រូវប្រឈមនឹងការអះអាងអំពីសិទ្ធិកម្មសិទ្ធិរបស់ម្ចាស់កម្មសិទ្ធិករនៃវត្ថុឃាត់ទុកនោះ ព្រោះថាកម្មសិទ្ធិករអាចទាមទារឱ្យអ្នកកាន់កាប់ប្រគល់វត្ថុរបស់ខ្លួនមកវិញបាន។[34] ម៉្យាងវិញទៀត កម្មសិទ្ធិករមានសិទ្ធិទាមទារឱ្យបញ្ឈប់ និងបង្ការការរារាំងដោយផ្អែកលើសិទ្ធិកម្មសិទ្ធិ ក្នុងករណីការអនុវត្តសិទ្ធិកម្មសិទ្ធិត្រូវបានរារាំង ឬករណីដែលមានការបារម្ភជាក់ស្តែងថា ការអនុវត្តសិទ្ធិកម្មសិទ្ធិរបស់ខ្លួននឹងទទួលបានការរារាំង។[35]

[33] មាត្រា ៥០០ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[34] មាត្រា ១៥៥ វាក្យខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[35] មាត្រា ១៥៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដូច្នេះ ការអនុវត្តលក់ដោយបង្ខំរបស់ម្ចាស់សិទ្ធិឃាត់ទុកតាមរយៈតុលាការ នឹងត្រូវបានផ្អាក់ ឬលុបចោលវិញជាមិនខាន។ ផ្ទុយមកវិញ វាគឺជាការទទួលខុសត្រូវចំពោះការបាត់បង់ ឬខូចខាតនៃវត្ថុកាន់កាប់ ប្រសិនបើអ្នកកាន់កាប់ដែលគ្មានឆន្ទៈយកជាកម្មសិទ្ធិ[36] ទោះបីក្នុងករណីកាន់កាប់ដោយសុចរិតក៏ដោយ ក៏មានករណីកិច្ចសងនូវការខូចខាត់ទាំងអស់ដែរ។[37] ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកបានអនុវត្តដោយបង្ខំនូវសិទ្ធិឃាត់ទុកទៅលើវត្ថុដែលកូនបំណុលខ្លួនមិនមែនជាម្ចាស់កម្មសិទ្ធិ ហើយលិខិតអនុវត្តក៏ត្រូវបានចូលជាស្ថានពរ ឯវត្ថុក៏ត្រូវបានលក់ និងប្តូរជាប្រាក់ផងដែរ នោះនាំឱ្យវត្ថុរបស់កម្មសិទ្ធិករត្រូវបានបាត់បង់។ ការធ្វើបែបនេះ ម្ចាស់សិទ្ធិឃាត់ទុកមិនទទួលបានផលប្រយោជន៍នោះទេ នៅពេលដែលម្ចាស់សិទ្ធិឃាត់ទុកអនុវត្តដោយបង្ខំនៃសិទ្ធិឃាត់ទុកលើវត្ថុដែលកូនបំណុលមិនមែនជាកម្មសិទ្ធិករ។ ដោយហេតុថា កូនបំណុលអាចប្តឹងទាមទារយកប្រាក់ដែលទទួលនបានពីការលក់មកវិញបាន និងអាចប្តឹងទាមទារសំណងផ្សេងៗតាមភាពជាក់ស្តែង។ ហេតុដូច្នេះ ការដែលម្ចាស់សិទ្ធិអនុវត្តការលក់ដោយបង្ខំក្នុងករណីនេះ គឺជាការនាំទុកដាក់ខ្លួនទៅវិញទេ។ ដោយឡែក ម្ចាស់សិទ្ធិឃាត់ទុកគួរតែបន្តការកាន់កាប់ និងថែរក្សាវត្ថុឃាត់ទុកនោះតទៅទៀតដើម្បីដាក់សម្ពាធដល់កម្មសិទ្ធិករ និងកូនបំណុលឱ្យមកចរចារទើបជាការប្រសើរ។

ឧទាហរណ៍៖ A បានខ្ចីរថយន្តរបស់ C ដើម្បីធ្វើដំណើរទៅខេត្តមួយ។ ក្រោយពេលត្រឡប់មកវិញ A សង្កេតឃើញថារថយន្តនោះមានបញ្ហា A ក៏បានយករថយន្តដែលខ្ចីពី C នោះទៅដាក់ជួសជុលនៅយានដ្ឋានជួសជុលឡានរបស់ B ដោយសន្យាថា ៣ថ្ងៃក្រោយនឹងមកទូទាត់ប្រាក់។ ក្រោយពី B បានជួសជុលហើយរំលងផុត៥ថ្ងៃ មិនឃើញ A មកយកឡាន B ក៏បានទៅជួប A នៅផ្ទះ ដើម្បីឱ្យ A សងប្រាក់ថ្លៃជួសជុលឡាន ប៉ុន្តែ A បានបដិសេដមិនព្រមសងទេព្រោះអះអាងថាឡាននេះមិនមែនជាឡានរបស់ខ្លួន ទើប B សម្រេចឃាត់ទុករថយន្តនោះ។ ដោយសារតែកូនបំណុលមិនព្រមសងប្រាក់ និងមានភាពលំបាកក្នុការទុកដាក់ (យានដ្ឋានមានទីធ្លាតូចចង្អៀត) B ក៏បានដាក់ពាក្យសុំទៅតុលាការដើម្បីស្នើរសុំអនុវត្តដោយបង្ខំដោយសិទ្ធិឃាត់ទុក ដែលមានរថយន្តជាកម្មវត្ថុនៃសិទ្ធិឃាត់ទុក ក្នុងគោលបំណងយកកម្មវត្ថុនៃសិទ្ធិឃាត់ទុកនោះទៅប្តូរជាប្រាក់ រួចទូទាត់សិទ្ធិលើបំណុល។

ក្នុងករណីនេះ កម្មវត្ថុនៃសិទ្ធិឃាត់ទុកមិនមែនជាកម្មសិទ្ធិរបស់ កូនបំណុល A ទេ ហើយ C ក៏មិនមែនជាកូនបំណុលរបស់ B ដែរ។ ហេតុដូចនេះប្រសិនបើ B អនុវត្តដោយបង្ខំនៃសិទ្ធិឃាត់ទុក នាំឱ្យសិទ្ធិឃាត់ទុកត្រូវរំលត់។ ម្យ៉ាងវិញទៀត បើ B បានអនុវត្ត B មិនអាចធ្វើការទូទាត់សិទ្ធិលើបំណុលថ្លៃជួសជុលជាមួយនឹងសិទ្ធិទាមទារថ្លៃលក់រថយន្តរបស់ C បាននោះទេ ហើយ B មានករណីកិច្ចប្រគល់ថ្លៃលក់រថយន្តទៅឱ្យ C វិញ។

[36] ការអនុវត្តសិទ្ធិឃាត់ទុកគឺជាទម្រង់មួយនៃការកាន់កាប់ដែលអ្នកកាន់កាប់នោះគ្មានឆន្ទៈយកជាកម្មសិទ្ធិទេ

[37] មាត្រា ១៥៧ វាក្យខណ្ឌទី១ និង ទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## កថាខណ្ឌទី២៖ ករណីកិច្ចរបស់ម្ចាស់សិទ្ធិឃាត់ទុក

### ក. ករណីកិច្ចក្នុងការកាន់កាប់វត្ថុឃាត់ទុក

ម្ចាស់សិទ្ធិឃាត់ទុកអាច ប្រើប្រាស់ ជួល ឬដាក់ប្រាតិភោគ និងអាស្រ័យផលលើវត្ថុដែលបានឃាត់ទុក បានតែត្រូវមានករណីកិច្ចជូនដំណឹង និងទទួលបានការអនុញ្ញាតពីកូនបំណុល ហើយក៏ត្រូវមានករណីកិច្ចក្នុងការថែរក្សា និងប្រុងប្រយ័ត្នចំពោះវត្ថុក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ដើម្បីជៀសវាងការខូចខាតដល់វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុកនោះ។[38]

ឧទាហរណ៍៖ លោក A និង លោក B បានចុះកិច្ចសន្យាសាងសង់ផ្ទះមួយកន្លែង។ ក្រោយមកដោយមានបញ្ហាខ្វះខាត់លោក A មិនបានទូរទាត់ប្រាក់គ្រប់ចំនួនឱ្យមកលោក B នោះទេ។ លោក A ក៏បានស្នើរសុំ B សងប្រាក់ដែលជំពាក់ក្នុងរយៈពេល ២ឆ្នាំទៀត។ ដោយយោគយល់ពីស្ថានភាពរបស់ A លោក B ក៏បានយល់ព្រមដោយមានលក្ខខណ្ឌគឺ B ត្រូវឃាត់ទុកផ្ទះនោះរហូតដល់ A សងប្រាក់គ្រប់ចំនួន ទើប B ប្រគល់ផ្ទះឱ្យវិញ។ ម៉្យាងវិញទៀត B បានស្នើរសុំ A ក្នុងការដាក់ផ្ទះនោះជួល នៅពេលដែល B បានសាងសង់រួច ហើយ A ក៏បានអនុញ្ញាត។

ក្នុងករណីនេះ B អាចយកវត្ថុដែលឃាត់ទុកទៅដាក់ជួលដើម្បីកាត់សិទ្ធិលើបំណុលដែលខ្លួនមាន។

#### ក.១. ការធ្វើបណ្ដឹងចំពោះម្ចាស់សិទ្ធិឃាត់ទុក

ការធ្វើបណ្ដឹងនេះ គឺជាសិទ្ធិរបស់កូនបំណុល នៅពេលដែលបានដឹងថាម្ចាស់សិទ្ធិឃាត់ទុកបំពាន់កាតព្វកិច្ចក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ហើយនេះក៏ជាមូលហេតុមួយក្នុងការរំលត់សិទ្ធិឃាត់ទុកផងដែរ។ នៅពេលខ្លះម្ចាស់សិទ្ធិឃាត់ទុកអនុវត្តសិទ្ធិប្រើប្រាស់វត្ថុដោយពុំមានការអនុញ្ញាតពីកូនបំណុលឡើយ ដោយយកទៅដាក់បញ្ចាំដើម្បីទទួលបានប្រាក់យកមកជាប្រយោជន៍ផ្ទាល់ខ្លួន។ ការធ្វើដូច្នេះ ជាហេតុនាំឱ្យវត្ថុត្រូវបានដាក់ធានាជាមួយនឹងម្ចាស់បំណុលថ្មីមួយទៀត (ម្ចាស់សិទ្ធិលើការបញ្ចាំ) នោះកូនបំណុលនឹងត្រូវខាត់បង់ប្រយោជន៍យ៉ាងខ្លាំងចំពោះអំពើនេះ។ តើវត្ថុដែលត្រូវបានដាក់ធានាជាមួយម្ចាស់បំណុលថ្មីនោះ អាចធ្វើបដិទានការកាន់កាប់មកឱ្យកូនបំណុលវិញដែរ ឬទេ?

ក្នុងករណីវត្ថុឃាត់ទុកស្ថិតក្រោមការគ្រប់គ្រងរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ ការធ្វើបណ្ដឹងចំពោះម្ចាស់សិទ្ធិឃាត់ទុកពុំមានន័យទេ។ ម៉្យាងវិញទៀត ដោយសារកូនបំណុល ជាកម្មសិទ្ធិករនៃវត្ថុ នាំឱ្យកម្មសិទ្ធិករអាចអះអាងអំពីកម្មសិទ្ធិចំពោះគ្រប់បុគ្គលទាំងអស់។ នាំឱ្យកូនបំណុលអាចធ្វើបណ្ដឹងទាមទាឱ្យម្ចាស់សិទ្ធិលើការបញ្ចាំប្រគល់វត្ថុដោយផ្អែកលើកម្មសិទ្ធិបាន។ ប្រសិនបើ ម្ចាស់សិទ្ធិលើការបញ្ចាំបានអះអាងថា ខ្លួនមានមូលហេតុគតិយុត្តិក្នុងការកាន់កាប់ មិនតែប៉ុណ្ណោះខ្លួនជាអ្នកកាន់កាប់ដោយសុចរិត និង គ្មានកំហុស។

[38] មាត្រា ៧៧៦ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដោយសង្កេតឃើញថា ម្ចាស់សិទ្ធិលើការបញ្ចាំ បានបង្កើតសិទ្ធិលើការបញ្ចាំជាមួយម្ចាស់សិទ្ធិឃាត់ទុកក៏ពិតមែន ប៉ុន្តែសិទ្ធិលើការបញ្ចាំ ត្រូវបានបង្កើតឡើងជាមួយបុគ្គលដែលគ្មានកម្មសិទ្ធិចំពោះកម្មវត្ថុនៃការបញ្ចាំ។ ហេតុដូច្នេះហើយ ម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចអះអាងអំពីសិទ្ធិលើការបញ្ចាំចំពោះកូនបំណុលបានទេ។ កម្មវត្ថុនៃការបញ្ចាំមិនមែនជាកម្មសិទ្ធិរបស់ម្ចាស់សិទ្ធិឃាត់ទុកទេ ហើយម្ចាស់សិទ្ធិឃាត់ទុក មិនបានទទួលការយល់ព្រមពី កូនបំណុលឱ្យបង្កើតសិទ្ធិលើការបញ្ចាំដែរ។ ដូច្នេះ សិទ្ធិលើការបញ្ចាំរវាងម្ចាស់សិទ្ធិឃាត់ទុក និងម្ចាស់សិទ្ធិលើការបញ្ចាំ មិនបង្កើតអានុភាពឡើយ។[39]

**ក.២. យន្តការនៃការការពារតតិយជនដែលសុចរិត**

ក្នុងករណីមួយចំនួនតូច តតិយជនអាចនឹងក្លាយជាជនរងគ្រោះប្រសិនបើតតិយជននោះពិតជាមិនបានដឹងថា ចលនវត្ថុដែលជាកម្មវត្ថុនៃការធ្វើអនុប្បទានមិនមែនជារបស់ម្ចាស់សិទ្ធិឃាត់ទុក។ ចំណែកឯកិច្ចសន្យាអនុប្បទានខាងលើមានសុពលភាពអនុវត្ត និងដោយសុចរិត ថែមទាំងគ្មានកំហុសទៀតផង។ យើងសង្កេតឃើញថា ករណីនេះជាវិវាទរវាងកម្មសិទ្ធិករនៃចលនវត្ថុ និងតតិយជន ពោលគឺមិនមែនជាវិវាទរវាងតតិយជន និងម្ចាស់សិទ្ធិឃាត់ទុកនោះទេ។ តើម្ចាស់តតិយជននឹងត្រូវបានទទួលការការពារពីច្បាប់ដែល ឬទេ?

ចំពោះក្រមរដ្ឋប្បវេណីកម្ពុជា (២០០៧) ត្រង់មាត្រា ១៩៣ បានបញ្ញត្តិអំពីយន្តការនៃការការពារតតិយជនដែលសុចរិត តាមរយៈលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ ដោយបានចែងថា អ្នកដែលបានទទួលការផ្ទេរការកាន់កាប់នូវចលនវត្ថុ ដោយកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាព ហើយដោយសុចរិត និងគ្មានកំហុស ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះ ទោះបីជាអនុប្បទានយីគ្មានកម្មសិទ្ធិលើចលនវត្ថុក៏ដោយ។ ប៉ុន្តែបញ្ហាត្រង់ថា សិទ្ធិលើការបញ្ចាំមិនមែនជាករណីលទ្ធកម្មនូវកម្មសិទ្ធិទេ ហេតុនេះអាចយកមាត្រា ១៩៣ មកអនុវត្តដើម្បីការពារតតិយជនសុចរិតបានដែរឬទេ?

ទោះបីជាការធ្វើអនុប្បទានលើការកាន់កាប់ចលនវត្ថុ មិនមែនជាករណីលទ្ធកម្មកម្មសិទ្ធិក៏ដោយ ចំពោះគោលគំនិតនៃមាត្រា ១៩៣ មិនត្រឹមតែការពារតតិយជនក្នុងករណីលទ្ធកម្មនូវកម្មសិទ្ធិប៉ុណ្ណោះទេ ពោលគឺយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីអនុប្បទានិកជាតតិយជនសុចរិត។

ឧទាហរណ៍៖ A ជាម្ចាស់សិទ្ធិឃាត់ទុកចំពោះរថយន្តរបស់ B ហើយ A បានយករថយន្តនោះទៅដាក់បញ្ចាំជាមួយ C ដោយគ្មានការអនុញ្ញាតពី B ឡើយ ហើយមិនតែប៉ុណ្ណោះ A បានប្រើល្បិចបន្លំធ្វើឱ្យ C យល់ច្រឡំថារថយន្តនោះជាកម្មសិទ្ធិរបស់ A ថែមទៀតផង។

[39] សៀវភៅ កម្រងមេរៀន ចងក្រងដោយ កម្មវិធីវិភាគទានច្បាប់ បោះពុម្ពលើកទី៤ ឆ្នាំ២០១៨ ទំព័រទី៣២

ក្នុងករណីនេះ C គឺជាតតិយជនសុចរិត និងគ្មានកំហុស។ ហេតុដូច្នេះ B មិនអាចប្តឹងទាមទាររថយន្តពី C វិញបានទេ ព្រោះ C មានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងនាមជាម្ចាស់សិទ្ធិលើការបញ្ចាំលើរថយន្តរបស់ B ហើយអាចប្រើសិទ្ធិនេះដើម្បីតតាំងជាមួយសិទ្ធិកម្មសិទ្ធិរបស់ B បាន។

### ខ. ករណីកិច្ចប្រគល់វត្ថុឃាត់ទុក

ទន្ទឹមនឹងការកាន់កាប់វត្ថុឃាត់ទុក ម្ចាស់សិទ្ធិឃាត់ទុកមិនត្រឹមតែមានករណីកិច្ចមើលថែរក្សាវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុកប៉ុណ្ណោះទេ ម្ចាស់សិទ្ធិឃាត់ទុកក៏ត្រូវមានករណីកិច្ចប្រគល់វត្ថុឃាត់ទុកទៅឱ្យកូនបំណុល ឬតតិយជនវិញផងដែរ។ ករណីកិច្ចប្រគល់វត្ថុឃាត់ទុកទៅឱ្យកូនបំណុល ឬតតិយជនវិញ កើតមានឡើងនៅពេលដែលសិទ្ធិឃាត់ទុកត្រូវបានរំលត់ ពោលគឺនៅពេលដែលកូនបំណុល ឬតតិយជន មកបំពេញកាតព្វកិច្ចសងបំណុលគ្រប់ចំនួន ម្ចាស់សិទ្ធិឃាត់ទុកត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុកទៅឱ្យម្ចាស់ដើមវិញ ឬក៏នៅពេលដែលម្ចាស់សិទ្ធិឃាត់ទុកបានបំពានកាតព្វកិច្ចណាមួយដែលនាំឱ្យ កូនបំណុលអាចទាមទារឱ្យរំលត់សិទ្ធិឃាត់ទុក ពេលនោះម្ចាស់សិទ្ធិឃាត់ទុកគឺមានកំហុស ដូចនេះត្រូវប្រគល់វត្ថុឃាត់ទុកត្រឡប់ទៅវិញ។

ឧទាហរណ៍៖ B ជាម្ចាស់សិទ្ធិឃាត់ទុកលើម៉ូតូរបស់ A ហេតុនេះ B ត្រូវមានករណីកិច្ចថែរក្សាម៉ូតូរបស់លោក Aឱ្យបានល្អ ក៏ប៉ុន្តែ លោក B មិនបានថែរក្សារម៉ូតូរបស់លោក A បានល្អនោះទេ គឺទុកចោលឱ្យម៉ូតូហាលថ្ងៃហាលភ្លៀងបណ្តាលឱ្យកើតមានច្រេះចាប់ ព្រមទាំងរបកថ្នាំពណ៌ផងដែរ ដូចនេះ លោក A មានសិទ្ធិទាមទារឱ្យលោក B ប្រគល់វត្ថុឃាត់ទុកមកវិញ ក្នុងករណីនេះ លោក B ត្រូវមានករណីកិច្ចប្រគល់វត្ថុឃាត់ទុកទៅឱ្យលោក A វិញ។

## កថាខណ្ឌទី៣៖ ការធ្វើលទ្ធកម្មនូវកម្មសិទ្ធិចំពោះចលនវត្ថុ

លទ្ធកម្ម គឺជាការទទួលបាន ឬការបានឡើងជាម្ចាស់សិទ្ធិនៃវត្ថុណាមួយ។[40] អ្នកដែលបានទទួលការផ្ទេរការកាន់កាប់នូវចលនវត្ថុ ដោយកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាព ហើយដោយសុចរិក និងគ្មានកំហុស ត្រូវធ្វើលទ្ធកម្មសិទ្ធិលើចលនវត្ថុនោះ ទោះបីជាអនុប្បទាយីគ្មានកម្មសិទ្ធិលើចលនវត្ថុនោះក៏ដោយ។[41] អ្នកធ្វើលទ្ធកម្មនូវកម្មសិទ្ធិអាចដាក់ពាក្យស្នើរសុំធ្វើជាកម្មសិទ្ធិករចំពោះវត្ថុកាន់កាប់ទៅតុលាការបានដោយគោរពទៅតាមអំឡុងពេលនៃអាជ្ញាយុកាលដែលច្បាប់កំណត់។

### ក.លទ្ធកម្មនូវកម្មសិទ្ធិចំពោះចលនវត្ថុតាមរយៈសិទ្ធិឃាត់ទុក

[40] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ បោះពុម្ពដោយទិស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧ ទំព័រទី១៩

[41] មាត្រា ១៩៣ កថាខណ្ឌទី១ វាក្យខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ការបន្តការកាន់កាប់អស់រយៈពេលជាយូរដោយសារតែកូនបំណុលមិនព្រមអនុវត្តកាតព្វកិច្ចសង ឬម្ចាស់សិទ្ធិឃាត់ទុកពុំអាចអនុវត្តសិទ្ធិលក់ដោយបង្ខំបាន យើងសង្កេតឃើញថា អាចមានធាតុផ្សំគ្រប់គ្រាន់ដើម្បីឱ្យម្ចាស់សិទ្ធិឃាត់ទុកនោះ ស្នើរសុំទៅតុលាការក្នុងការធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលខ្លួនបានកាន់កាប់តាមរយៈសិទ្ធិឃាត់ទុក ប្រសិនបើការកាន់កាប់នោះស្រប់តាមអាជ្ញាយុកាលដែលច្បាប់កំណត់ (១០ឆ្នាំ ឬ ៥ឆ្នាំ)។[42] ដោយហេតុថា ម្ចាស់សិទ្ធិឃាត់ទុកទទួលបានការកាន់កាប់ចំពោះវត្ថុដោយសុចរិត និងគ្មានកំហុតទេ តាមរយៈសិទ្ធិលើបំណុលចំពោះកូនបំណុលខ្លួន ហើយបើទោះបីជាកូនបំណុលគ្មានសិទ្ធិកម្មសិទ្ធិលើវត្ថុនោះក៏ដោយក៏ច្បាប់ ទទួលស្គាល់ការធ្វើលទ្ធកម្មនូវកម្មសិទ្ធិរបស់ម្ចាស់សិទ្ធិឃាត់ទុកដែរ។

### ខ.អាជ្ញាយុកាលនៃការធ្វើលទ្ធកម្មនូវកម្មសិទ្ធិចំពោះចលនវត្ថុ

ក្នុងករណី អ្នកការកាន់កាប់នោះទទួលបានការកាន់កាប់ទាំងដែរគ្មានសិទ្ធិចំពោះវត្ថុ នោះត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិក្នុងអំឡុងពេល ១០ឆ្នាំ ឬ ៥ឆ្នាំ បើការកាន់កាប់នោះសុចរិត និងគ្មានកំហុសពីដើមមក ហើយបើអ្នកកាន់កាប់ដែលទទួលបានការកាន់កាប់លើវត្ថុតាមរយៈការអះអាងអំពីសិទ្ធិដែលខ្លួនមានចំពោះវត្ថុវិញ នឹងត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិក្រោយអំឡុងពេល ១០ឆ្នាំ ឬ ៥ឆ្នាំ បើការកាន់កាប់នោះសុចរិត និងគ្មានកំហុងពីដើមមក។ យើងសង្កេតឃើញថា អាជ្ញាយុកាលរបស់អ្នកដែលមានបំណង់ធ្វើលទ្ធកម្មនូវកម្មសិទ្ធិ តាមទម្រង់នៃការកាន់កាប់ទាំងពីរខាងលើនេះ គឺខុសគ្នាត្រង់ពាក្យថា "ក្នុងអំឡុងពេល" និង "ក្រោយអំឡុងពេល" តែប៉ុណ្ណោះ។

## កថាខណ្ឌទី៤៖ ការបន្តអានុភាពនៃសិទ្ធិឃាត់ទុក

ការដែលសិទ្ធិទុកត្រូវបានកើតឡើង គឺត្រូវតែមានសិទ្ធិលើបំណុលអមមកជាមួយ នាំឱ្យម្ចាស់បំណុលមានការអះអាងសិទ្ធិចំនួនពីរ រួមមានសិទ្ធិលើបំណុល និងសិទ្ធិឃាត់ទុក ពោលគឺកម្មវត្ថុនៃសិទ្ធិលើបំណុល គឺជា ប្រាក់ ឬកាតព្វកិច្ចសងបំណុល ឯកម្មវត្ថុនៃសិទ្ធិឃាត់ទុកវិញ គឺជាវត្ថុ។ ប្រសិនបើសិទ្ធិលើបំណុលត្រូវបានផ្ទេរ តើសិទ្ធិឃាត់ទុកនឹងបានបន្តទៅអ្នកទទួលដែរ ឬទេ? ចំពោះក្នុងករណីដែលម្ចាស់សិទ្ធិឃាត់ទុកទទួលមរណៈភាពវិញ តើអានុភាពនៃសិទ្ធិឃាត់ទុកនឹងត្រូវរំលត់ ឬបានបន្តទៅសន្តតិជន?

### ក. ការបន្តសិទ្ធិឃាត់ទុកតាមរយៈអនុប្បទានសិទ្ធិលើបំណុល

សិទ្ធិលើបំណុល ជាទ្រព្យអកម្ម (អរូបី) ដែលសិទ្ធិនេះអាចក្លាយជាកម្មវត្ថុនៃការធ្វើអនុប្បទានបាន ហើយអនុ ប្បទានិកនឹងក្លាយជាម្ចាស់បំណុលថ្មី។[43] ជាការកំណត់ដោយច្បាប់ អនុប្បទានសិទ្ធិលើបំណុលត្រូវមានអានុភាព តែដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុលដែលមានបំណងធ្វើអនុប្បទានសិទ្ធិលើបំណុលនឹង

[42] មាត្រា ១៩៥ និងមាត្រា ១៩៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[43] មាត្រា ៥០១ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អនុប្បទានិកប៉ុណ្ណោះ។[44] ចំពោះលក្ខខណ្ឌតតាំងក្នុងការធ្វើអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ តម្រូវឱ្យអនុប្បទាយី ឬអនុប្បទានិកធ្វើការជូនដំណឹងទៅកូនបំណុលជាមុនសិន ហើយបើកូនបំណុលយល់ព្រម ទើបអាចតតាំងនឹងកូនបំណុល ឬតតិយជនផ្សេងៗបាន ក៏ប៉ុន្តែបើកូនបំណុលមិនបានយល់ព្រមជាមួយ អនុប្បទាយី ឬ អនុប្បទានិតវិញ នោះលក្ខខណ្ឌតតាំងក៏មិនអាចកើតបានដែរ។[45] ចំណែកឯការជូនដំណឹង ឬការ យល់ព្រមនេះ បើមិនបានធ្វើឡើងដោយលិខិតដែលមានការបរិច្ឆេទស្ថាពរទេ នោះមិនអាចតតាំងនឹងតតិយជន ក្រៅពីកូនបំណុលបានឡើយ។[46] ហេតុដូច្នេះ ការព្រមព្រៀងរវាងអនុប្បទានយី និង អនុប្បទានិក អាចបង្កើត អានុភាពនៃការធ្វើអនុប្បទានសិទ្ធិលើបំណុលបាន ហើយអានុភាពនៃការធ្វើអនុប្បទានសិទ្ធិលើបំណុលនេះ គឺ ត្រូវបានទទួលស្គាល់ដោយច្បាប់ ក៏ប៉ុន្តែលក្ខខណ្ឌតតាំងចំពោះកូនបំណុល ឬតតិយជនផ្សេងៗ ពុំទាន់អាច យកមកអះអាងបានឡើយ ពោលគឺអនុប្បទានយី និងអនុប្បទានិកត្រូវគោរពតាមលក្ខខណ្ឌតតាំងខាងលើ។

ក្នុងករណីសិទ្ធិលើបំណុលដែលសិទ្ធិប្រាតិភោគប្រត្យក្សត្រូវបានបង្កើតឡើង ត្រូវបានផ្ទេរ បើគ្មានការ បង្ហាញឆន្ទៈផ្សេងទេ សិទ្ធិប្រាតិភោគប្រត្យក្សនោះក៏ត្រូវបានផ្ទេរទៅឱ្យអ្នកដែលទទួលសិទ្ធិលើបំណុលនេះដែរ។ ប៉ុន្តែក្នុងករណីដែលចាំបាច់តម្រូវឱ្យម្ចាស់សិទ្ធិលើប្រាតិភោគ កាន់កាប់វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគនោះ អ្នកទទួលការផ្ទេរសិទ្ធិលើបំណុលក៏ចាំបាច់ត្រូវទទួលនូវការកាន់កាប់វត្ថុដែលជាកម្មវត្ថុនោះដែរ។[47] បានន័យថា បើសិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវបានធ្វើអនុប្បទាន ហើយបើមិនបានបង្ហាញឆន្ទៈច្បាប់លាស់ថា មិនធ្វើ អនុប្បទានសិទ្ធិប្រាតិភោគប្រត្យក្សដូច្នេះទេ សិទ្ធិប្រាតិភោគប្រត្យក្សនេះក៏ត្រូវផ្ទេរដែរ។ ចំពោះសិទ្ធិឃាត់ទុក និង សិទ្ធិលើការបញ្ចាំចាំបាច់ត្រូវផ្ទេរនូវការកាន់កាប់វត្ថុដែលជាកម្មវត្ថុនោះ (នេះជាការធម្មតាទេ)។[48] ហេតុដូច្នេះ សិទ្ធិ ឃាត់ទុកនឹងត្រូវបានផ្ទេរជាមួយនឹងសិទ្ធិលើបំណុលផងដែរ ទោះបីជាបានបង្ហាញឆន្ទៈព្រមព្រៀង ឬមិនព្រម ព្រៀងក្នុងការផ្ទេរសិទ្ធិឃាត់ទុកក៏ដោយ។

ឧទាហរណ៍៖ B ជាម្ចាស់សិទ្ធិឃាត់ទុកលើរថយន្តរបស់លោក A ។ បន្ទាប់ពីឃាត់ទុកអស់រយៈពេល ៣ខែ លោក B ស្រាប់តែមានការរវល់ទៅប្រទេសក្រៅរយៈពេលយូរ ក៏បានធ្វើអនុប្បទានសិទ្ធិលើបំណុលនោះទៅឱ្យ ប្អូនប្រុសរបស់គាត់គឺលោក C។ ការធ្វើអនុប្បទាននេះ លោក B ក៏បានជូនដំណឹងទៅឱ្យលោក A ព្រមទាំងបាន ធ្វើជាលិខិតដែលមានកាលបរិច្ឆេទត្រឹមត្រូវផងដែរ លោក A ក៏បានយល់ព្រម។

---

[44] មាត្រា ៥០២ កថាខណ្ឌទី១ វាក្យខណ្ឌទី១ ក្រមរដ្ឋប្បវ៉ាណី ឆ្នាំ២០០៧

[45] មាត្រា ៥០៣ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[46] មាត្រា ៥០៣ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[47] មាត្រា ៧៧០ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[48] សេក្តីកំណត់ចំពោះមាត្រានីមួយៗក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ភាគ៤: គន្ថីទី៦ បោះពុម្ពនៅភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ទំព័រ ទី ៤ និងទំព័រទី ៥ (មាត្រា៧៧០)

ក្នុងករណីនេះ សិទ្ធិលើបំណុលត្រូវបានផ្ទេរទៅឱ្យ C នាំឲ C ក្លាយជាម្ចាស់សិទ្ធិលើបំណុលថ្មី។ ចំពោះសិទ្ធិលើបំណុលក្នុងឧទាហរណ៍នេះ វាមានទំនាក់ទំនងនឹងសិទ្ធិលើឃាត់ទុក ព្រោះសិទ្ធិឃាត់ទុក (សិទ្ធិប្រាតិភោគប្រាត្យក្ស) នេះត្រូវបានបង្កើតឡើងដោយសិទ្ធិលើបំណុល។ ដូច្នេះ បើទោះបីជាគ្មានការបង្ហាញឆន្ទៈថាផ្ទេរសិទ្ធិឃាត់ទុកទេ ក៏សិទ្ធិឃាត់ទុកនេះត្រូវបានផ្ទេរទៅឱ្យ C ដែរ (C អាចអះអាងសិទ្ធិឃាត់ទុកចំពោះ A)។

**ខ. ការបន្តសិទ្ធិឃាត់ទុកតាមរយៈសន្តតិកម្ម**

ការបន្តសិទ្ធិឃាត់ទុកតាមរយៈសន្តតិកម្មវាខុសគ្នាពីការបន្តសិទ្ធិឃាត់ទុកតាមរយៈអនុប្បទានសិទ្ធិលើបំណុលខាងលើ ត្រង់ថាមូលហេតុនៃការចាប់ផ្តើមមិនដូចគ្នា ព្រោះថាសន្តតិកម្ម ត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន (មាន ឬគ្មានបណ្តាំ) រីឯអនុប្បទានសិទ្ធិបំណុល ត្រូវចាប់ផ្តើមដោយការបង្ហាញឆន្ទៈរបស់អនុប្បទានិក និងអនុប្បទានយី ដែលមានបំណងធ្វើអនុប្បទានសិទ្ធិលើបំណុល។

ការបន្តសិទ្ធិឃាត់ទុកតាមរយៈសន្តតិកម្ម គឺជាការបន្តនូវសិទ្ធិ និងករណីកិច្ចទាំងអស់ ដែលស្ថិតក្រោមទ្រព្យសម្បត្តិរបស់មតកជនឱ្យទៅសន្តតិជន ចាប់ពីពេលដែលសន្តតិកម្មនោះចាប់ផ្តើម។[49] សន្តតិកម្មនេះត្រូវចាប់ផ្តើមដោយមូលហេតុមរណភាពរបស់មតកជន។ ចំពោះការផ្ទេរតាមរយៈសន្តតិកម្ម អាចត្រូវធ្វើឡើងដោយទម្រង់ពីរយ៉ាង គឺសន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ហៅថា សន្តតិកម្មតាមច្បាប់ និងសន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជនហៅថា សន្តតិកម្មតាមបណ្តាំ។ សន្តតិកម្មទាំងពីរទម្រង់នេះ គឺនឹងត្រូវចោទជាសំនួរថា តើសិទ្ធិលើបំណុលរបស់មតកជននឹងត្រូវបន្តទៅសន្តតិជនដែរ ឬទេ ប្រសិនបើគ្មានលិខិតបណ្តាំ? តើកូនបំណុលអាចរំលត់សិទ្ធិឃាត់ទុកតាមរយៈការដែលម្ចាស់បំណុលខ្លួនទទួលមរណភាពបែបនេះបានដែរ ឬទេ?

ដោយយោងតាមបញ្ញត្តិច្បាប់ខាងលើ សិទ្ធិ និងករណីកិច្ចរបស់មតកជនត្រូវផ្ទេរមកឱ្យសន្តតិជន។[50] ក្នុងករណីនេះសិទ្ធិឃាត់ទុក គឺជាសិទ្ធិរបស់មតកជន នាំឱ្យសន្តតិជនត្រូវទទួលបន្តសិទ្ធិ និងករណីកិច្ចដែលកើតមានពីសិទ្ធិឃាត់ទុកនោះ។ បានសេចក្តីថា ច្បាប់ទទួលស្គាល់សិទ្ធិឃាត់ទុកអាចជាកម្មវត្ថុនៃសន្តតិកម្ម ទោះបីជាសន្តតិកម្មនោះជាទម្រង់នៃសន្តតិកម្មមានបណ្តាំ ឬសន្តតិកម្មគ្មានបណ្តាំក៏ដោយ។ ម៉្យាងវិញទៀត ក៏ពុំមានបញ្ញត្តិនៃមាត្រាណាមួយចែងអំពីការរំលត់សិទ្ធិឃាត់ទុកដោយមូលហេតុមរណភាពរបស់ម្ចាស់សិទ្ធិឃាត់ទុកនោះឡើយ។ ហេតុដូច្នេះ សិទ្ធិឃាត់ទុកអាចត្រូវបន្តតាមរយៈសន្តតិកម្មបាន ហើយកូនបំណុលមិនអាចអះអាងឱ្យរំលត់សិទ្ធិឃាត់ទុក ដោយមូលហេតុនៃការចាប់ផ្តើមសន្តតិកម្មបានទេ។

ឧទាហរណ៍៖ B ជាម្ចាស់សិទ្ធិឃាត់ទុកលើរថយន្តរបស់ A។ ជាអកុសល ក្រោយពីបានឃាត់ទុកវត្ថុនោះមួយរយៈពេលមក លោក B ក៏បានទទួលមរណភាពដោយសារតែជំងឺប្រចាំកាយ។ លោក A បានដឹងអំពី

[49] មាត្រា ១១៤៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[50] ចំពោះអ្នកដែលអាចក្លាយជាសន្តតិជនបានសូមមើលពី មាត្រា ១១៤៩ រហូតដល់ មាត្រា ១១៦២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដំណឹងនេះហើយក៏បានអះអាងអំពីការរំលត់សិទ្ធិឃាត់ទុកដោយមូលហេតុមរណភាពរបស់ B ព្រមទាំងបានទៅទាមទារយករថយន្តពីគ្រួសាររបស់លោក B មកវិញ។

ក្នុងករណីនេះ លោក B មិនបានធ្វើបណ្តាំមរតកអ្វីនោះឡើយ នាំឱ្យបញ្ញត្តិស្តីអំពីសនត្តិកម្មតាមច្បាប់ត្រូវយកមកអនុវត្ត។ សិទ្ធិឃាត់ទុកអាចជាកម្មវត្ថុនៃសន្តតិកម្មតាមច្បាប់ ដែលបណ្តាលឱ្យសិទ្ធិ និងករណីកិច្ចដែលកើតពីសិទ្ធិឃាត់ទុកអាចបន្តទៅឱ្យសន្តតិជនរបស់លោក B បាន។ ហេតុដូច្នេះ សន្តតិជនដែលទទួលបន្តនូវសិទ្ធិឃាត់ទុកនេះនៅតែមានអានុភាពអះអាងពីការកាន់កាប់ចំពោះរថយន្តដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុក ដែលនាំឱ្យ A មិនអាចយករថយន្តទៅវិញបានទេ លុះត្រាតែ A បំពេញកាតព្វកិច្ចសងបំណុលចំពោះអ្នកកាន់កាប់បន្ត(សន្តតិជន)។

# ជំពូកទី២
# ការរំលត់សិទ្ធិឃាត់ទុក

# ជំពូកទី២៖ ការរំលត់សិទ្ធិឃាត់ទុក

ការរំលត់ គឺជាស្ថានភាពដែលច្បាប់បានកំណត់ថាសិទ្ធិរបស់ម្ចាស់បំណុលនឹងអាចបាត់បង់ទៅវិញដោយមូលហេតុណាមួយ។ ម្ចាស់បំណុល អាចកើតមានសិទ្ធិឃាត់ទុក និងអាចអះអាងអំពីអានុភាពនៃសិទ្ធិឃាត់ទុកខ្លួនចំពោះកូនបំណុល និងតតិយជនបាន ក៏ប៉ុន្តែសិទ្ធិឃាត់ទុករបស់ម្ចាស់បំណុលក៏នឹងអាចត្រូវរំលត់ទៅវិញតាមរយៈការទាមទាររបស់កូនបំណុល ឬការកំណត់ដោយច្បាប់ (បណ្ដឹងទៅតុលាការ)។ ចំពោះការរំលត់នៃសិទ្ធិឃាត់ទុកនេះ អាចកើតឡើងដោយមូលហេតុជាច្រើន ឯមូលហេតុខ្លះកើតពីកំហុសរបស់ម្ចាស់សិទ្ធិឃាត់ទុក ចំណែកមូលហេតុខ្លះទៀត គឺកើតដោយសារតែការព្រមព្រៀង និងការលះបង់សិទ្ធិ ហើយនឹងអាចត្រូវរំលត់ផងដែរដោយមូលហេតុគតិយុត្ត និងមូលហេតុដទៃទៀតដែលនឹងត្រូវបកស្រាយក្នុងចំណុចនីមួយៗក្នុងផ្នែកខាងក្រោមនេះ។

## ផ្នែកទី១៖ ការរំលត់សិទ្ធិឃាត់ទុកដោយមូលហេតុទាក់ទងនឹងវត្ថុ

សិទ្ធិឃាត់ទុក នឹងត្រូវរំលត់នៅពេលណាដែលម្ចាស់សិទ្ធិឃាត់ទុកបានបាត់បង់នូវការកាន់កាប់ ចំពោះវត្ថុឃាត់ទុកនោះ។[51] ជាភាពសត្យានុម័ត សិទ្ធិឃាត់ទុកត្រូវតែមានការកាន់កាប់ចំពោះវត្ថុនោះទើបយើងអាចអះអាងអំពីសិទ្ធិឃាត់ទុកបាន ហើយប្រសិនជាគ្មានវត្ថុយកមកអះអាងទេ តើវាអាចកើតមានសិទ្ធិឃាត់ទុកយ៉ាងរបៀបមិច? បានន័យថា លក្ខខណ្ឌសុពលភាពនៃការកានកាប់ចំពោះវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុក គឺជាធាតុផ្សំដែលមិនអាចខ្វះបានឡើយចំពោះម្ចាស់សិទ្ធិឃាត់ទុក។ ម្យ៉ាងវិញទៀត ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកមានការកាន់កាប់លើវត្ថុហើយ និងអាចអះអាងអំពីសិទ្ធិឃាត់ទុកថែមទៀត ក៏ប៉ុន្តែប្រសិនបើកូនបំណុល ឬតតិយជនបានមកសងសិទ្ធិលើបំណុល នោះម្ចាស់សិទ្ធិឃាត់ទុកត្រូវប្រគល់វត្ថុទៅឱ្យម្ចាស់ដើមវិញ ព្រោះវត្ថុត្រូវបានទូទាត់សិទ្ធិលើបំណុលរួចហើយ។ ស្ថានភាពបែបនេះនឹងធ្វើឱ្យម្ចាស់សិទ្ធិឃាត់ទុក ពុំមានវត្ថុកាន់កាប់តទៅទៀតឡើយនាំឱ្យខ្លួនមិនអាច់អះអាងអំពីសិទ្ធិឃាត់ទុកបន្តទៅមុនបាន។

### កថាខណ្ឌទី១៖ ការបាត់បង់ការកាន់កាប់លើវត្ថុឃាត់ទុក

សិទ្ធិឃាត់ទុក គឺជាសិទ្ធិដែលកើតមានចំពោះវត្ថុរបស់កូនបំណុល ហើយវត្ថុនោះត្រូវតែជាវត្ថុដែលមានទំនាក់ទំនងជាមួយសិទ្ធិលើបំណុល។ ចំពោះកាល់ដែលម្ចាស់សិទ្ធិឃាត់ទុកបានបាត់បង់ការកាន់កាប់វត្ថុឃាត់ទុកដោយអំពើ ឬសកម្មភាពណាមួយ ហើយប្រសិនបើកាលៈទេសៈនោះបានធ្វើឱ្យម្ចាស់សិទ្ធិឃាត់ទុកបាត់បង់កម្មវត្ថុនៃសិទ្ធិឃាត់ទុកដោយការប្រគល់ឱ្យទៅកូនបំណុលវិញក្ដី ឬដោយការលះបង់ចោលវត្ថុឃាត់ទុកក្ដី ឬដោយស្ថាន

[51] មាត្រា ៧៨០ កថាខណ្ឌទី១ វាក្យខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ភាពដែលមិនអាចអនុវត្តសិទ្ធិឃាត់ទុកបាន ក្នុងករណីនេះ ម្ចាស់សិទ្ធិឃាត់ទុកនោះ ត្រូវបានចាត់ទុកថា បានរំលត់សុពលភាពនៃសិទ្ធិឃាត់ទុកដែលខ្លួនមាន។

**ក. ការអនុញ្ញាតឱ្យកូនបំណុលយកវត្ថុឃាត់ទុកទៅវិញ**

ការអនុញ្ញាតឱ្យកូនបំណុលយកវត្ថុឃាត់ទុកទៅវិញ វាជាសេរីភាពរបស់ម្ចាស់បំណុល ឬជាសកម្មភាពមួយដែលភាគីទាំងពីរបានចរចាគ្នាដោយធ្វើការស្នើរសុំផ្លាស់ប្តូរវត្ថុឃាត់ទុកជាដើម។ ការធ្វើបែបនេះគឺអាចកើតមានឡើងដោយរូបភាពពីរយ៉ាង គឺដោយសកម្មភាពឯកតោភាគីរបស់ម្ចាស់បំណុល និងអាចកើតដោយការចុះកិច្ចព្រមព្រៀងរួចប្រគល់វត្ថុឃាត់ទុកទៅកូនបំណុលវិញក្នុងលក្ខខណ្ឌណាមួយកំណត់ដោយគូភាគី។

ឧទាហរណ៍៖ លោក A បានបើកឡានពីភ្នំពេញទៅផ្ទះនៅឯខេត្តបាត់ដំបង តែជាអកុសល់ឡាន់របស់គាត់ខូចតាមផ្លូវមិនអាចបើកទៅមុខទៀតបាន គាត់ក៏ទូរស័ព្ទហៅលោក B ដែលជាជាងជួសជុលឡានឱ្យមកសណ្តោងឡានរបស់ A ទៅយានដ្ឋានរបស់លោក B ។ លោក B បានប្រាប់ទៅលោក A ថា ថ្លៃជួសជុលសរុបគឺ ៥០០$ បន្ទាប់មកខ្លួនក៏បានជួសជុលរថយន្តឱ្យ A រួចរាល់ ក៏ប៉ុន្តែលោក A មកតាមផ្លូវដាក់ប្រាក់តាមខ្លួនតែ ២៥០$ ទេ ក៏ហុចទៅឱ្យ B សិនរួចខ្លួននឹងបញ្ជូនប្រាក់ ២៥០$ (តាមរយៈ Wing) ទៀតនៅពេលដែលខ្លួនទៅដល់ផ្ទះ នាំឱ្យ លោក B កើតមានសិទ្ធិលើបំណុលចំនួន ២៥០$ ដែលនៅសល់។ ដោយឃើញថាមេឃជិតងងឹតហើយលោក B ត្រូវប្រញ៉ាប់បិទយានដ្ឋាន និងម្យ៉ាងទៀតក៏អាណិតដល់ A ដែលគ្មានរថយន្តបន្តដំណើរ B ក៏បានប្រគល់រថយន្តទៅឱ្យ A ដើម្បីបន្តដំណើរទៅមុខទៀតដោយសង្ឃឹមថា A នឹងគោរពតាមពាក្យសន្យា។

ក្នុងករណីនេះ B មិនអាចអះអាងអំពីសិទ្ធិឃាត់ទុកដែលខ្លួនមានចំពោះ A បានទៀតនោះទេ ព្រោះថាលោក B បានយល់ព្រមឱ្យកូនបំណុលខ្លួនបន្តប្រើប្រាស់វត្ថុដែលនឹងអាចជាកម្មវត្ថុនៃសិទ្ធិឃាត់ទុក ជាហេតុនាំឱ្យសិទ្ធិឃាត់ទុករំលត់។

**ខ. ការបាត់បង់ការកាន់កាប់ដោយសារទីតាំងនៃវត្ថុ**

ចំពោះការអនុវត្តសិទ្ធិឃាត់ទុក នៅពេលខ្លះក៏ត្រូវបានរារាំងដោយកត្តាទីតាំងនៃវត្ថុកំពុងស្ថិតនៅផងដែរ ជាហេតុនាំឱ្យម្ចាស់បំណុលអលទ្ធិភាពក្នុងការឃាត់ទុកវត្ថុនោះ ព្រោះថាវត្ថុស្ថិននៅក្នុងដែនអធិបតេយ្យរបស់កូនបំណុលខ្លួន។

ឧទាហរណ៍៖ លោក A ជាម្ចាស់រថយន្ត បានហៅលោក B ជាជាងជួសជុលឱ្យមកជួសជុលរថយន្តនៅឯផ្ទះរបស់ខ្លួន។ ក្រោយពេលជួសជុលរួច លោក A មិនបានបង់ប្រាក់ថ្លៃសេវាជួសជុលឱ្យមកលោក B ទេ ហើយពេលនោះលោក B ប្រាប់ថាបើមិនបង់ប្រាក់ទេ ខ្លួននឹងឃាត់រថយន្តទុក តែលោក A មិនព្រមទេ ក៏បណ្តេញលោក B ចេញពីលំនៅឋាន។ ដោយសារតែលោក B មិនអាចតតាំងនៅក្នុងលំនៅឋានរបស់លោក A បាន នោះខ្លួនក៏ដើរចេញមកក្រៅផ្ទះ ហើយលោក A ក៏បានបិទទ្វារបង។

ក្នុងករណីនេះយើងឃើញថា លោក B បានបំពេញកាតព្វកិច្ចរួច តែលោក A មិនអនុវត្តកាតព្វកិច្ចតបស្នងមកវិញទេ នាំឱ្យលោក B កើតមានសិទ្ធិលើបំណុល ក៏ប៉ុន្តែលោក B ត្រូវបានបណ្តេញចេញពីផ្ទះរបស់ A។ បានន័យថាលោក B មិនអាចអះអាងអំពីសិទ្ធិឃាត់ទុកបាននោះទេ ព្រោះសិទ្ធិឃាត់ទុកក្នុងករណីនេះពុំបង្កើតអានុភាពបានឡើយ ដោយរថយន្តកំពុងស្ថិតនៅផ្ទះរបស់លោក A។ ម៉្យាងវិញទៀត B រឹតតែមិនអាចឃាត់រថយន្តនោះដោយអំពើអនីត្យនុគោលបានផងដែរ។

## កថាខណ្ឌទី២៖ ការទូរទាត់សិទ្ធិលើបំណុល

ការទូទាត់សិទ្ធិលើបំណុល គឺជាមូលហេតុនៃការរំលត់កាតព្វកិច្ចរបស់ភាគី ដូចមានកំណត់ក្នុងក្រមរដ្ឋប្បវេណី គន្ថីទី៤ ជំពូកទី៧ ស្តីពីការរំលត់កាតព្វកិច្ច។[52] ប្រសិនបើកាតព្វកិច្ចសងរបស់កូនបំណុលត្រូវរំលត់ នាំឱ្យសិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិឃាត់ទុកត្រូវបាត់បង់ ហើយសិទ្ធិឃាត់ទុកក៏ត្រូវរំលត់ផងដែរ។ ម៉្យាងវិញទៀត ការសងសិទ្ធិលើបំណុលនេះក៏ត្រូវគោរពទៅតាមគោលការណ៍ទូទៅស្តីពីការសងផងដែរ។[53] ក្នុងនោះច្បាប់បានកំណត់ថា ការសង អាចធ្វើឡើងដោយកូនបំណុលក៏បាន ដោយតតិយជនក៏បាន។[54] បានន័យថា កូនបំណុល ឬតតិយជនអាចមកចរចារជាមួយម្ចាស់សិទ្ធិឃាត់ទុកដោយកំណត់វិធីណាមួយដើម្បីទូទាត់ការសង (រំលត់កាតព្វកិច្ច)។ ហេតុដូច្នេះ ក្នុងករណីបើម្ចាស់សិទ្ធិឃាត់ទុកទទួលបានការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន នោះវានឹងនាំឱ្យអានុភាពនៃសិទ្ធិឃាត់ទុកត្រូវរំលត់ ហើយត្រូវប្រគល់វត្ថុឱ្យទៅម្ចាស់ដើម ឬកូនបំណុលវិញ។ តើការទូរទាត់អាចធ្វើបានដោយមធ្យោបាយណាខ្លះដែលស្របតាមអានុភាពច្បាប់?

### ក. ការសងដោយទូរទាត់ជាប្រាក់

ប្រាក់ គឺជាទ្រព្យសម្បត្តិដែលច្បាប់បានចាត់ទុកថា ជាចលនវត្ថុមួយប្រភេទ។[55] ក្នុងការទូទាត់សិទ្ធិលើបំណុលគូភាគីទាំងពីរអាចជ្រើសយកជម្រើសសងជាប្រាក់ដើម្បីទូទាត់។

ឧទាហរណ៍៖ លោក A បានខ្ចីរថយន្តរបស់លោក C ទៅប្រើប្រាស់។ ថ្ងៃមួយរថយន្តក៏ខូច លោក A ក៏យកទៅឱ្យលោក B ជួសជុល។ បន្ទាប់ពីធ្វើរថយន្តរួចអស់តម្លៃ ៥០០$ តែលោក A មានតែ ២០០$ ក៏យកបង់សិនហើយសន្យាថាស្អែកខ្លួននឹងយកប្រាក់មកសង។ លោក B ក៏ឃាត់ទុករថយន្តដើម្បធានាបំណុល។ ដោយដំណឹងនេះដឹងទៅដល់ម្ចាស់រថយន្តគឺលោក C នោះគាត់ក៏យកប្រាក់ ៣០០$ ទៅសងលោក B ជាបន្ទាន់ដើម្បីយករថយន្តខ្លួនមកវិញ។

[52] មាត្រា ៤៣៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[53] មាត្រា ៤៣៤ ដល់មាត្រា ៤៤៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[54] មាត្រា ៤៣៤ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[55] មាត្រា ១២០ កថាខណ្ឌទី៣ និងទី៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក្នុងករណីនេះសិទ្ធិឃាត់ទុករបស់លោក B ត្រូវរំលត់។

**ខ. ការសងដោយវត្ថុមានតម្លៃ**

ក្រៅពីប្រាក់ដូចដែលបានរៀបរាប់ខាងលើ គូភាគីក៏អាចកំណត់ជ្រើសយកវត្ថុដទៃផ្សេងៗទៀតដែលមានតម្លៃ និងអាចធ្វើអនុប្បទានបាន មកទូទាត់សិទ្ធិលើបំណុល ហើយដើម្បីរំលត់កាតព្វកិច្ចបានផងដែរ។

ឧទាហរណ៍៖ លោក A បានឃាត់ទុកផ្លែធូរេនរបស់លោក B ចំនួន ៥០គីឡូ (ព្រោះ B មិនបង់ថ្លៃសេវាដឹកជញ្ជូន) ហើយលោក B បានយកផ្លែប៉ោមចំនួន ១០គីឡូមកកាត់សិទ្ធិលើបំណុលរបស់លោក A (នាំឱ្យសិទ្ធិឃាត់ទុកត្រូវរំលត់)។

**គ. ការសងដោយការទូរទាត់សិទ្ធិ**

ការសងដោយការទូរទាត់សិទ្ធិ សំដៅលើស្ថានភាពដែលគូភាគីកើតមានសិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមក ហើយភាគីទាំងពីរបានឯកភាពគ្នាកាត់បំណុលដោយការទូទាត់សិទ្ធិនោះ ដើម្បីរំលត់កាតព្វកិច្ចរវាងម្ចាស់សិទ្ធិឃាត់ទុក និងម្ចាស់វត្ថុ។ ក្នុងករណីដែលភាគីម្ខាង ឬទាំងសងខាងមានកាតព្វកិច្ចច្រើនដែលអាចទូទាត់បាន អ្នកសុំទូទាត់អាចជ្រើសរើសកាតព្វកិច្ចណាមួយរបស់ខ្លួន និងកាតព្វកិច្ចណាមួយរបស់ភាគីម្ខាងទៀតដើម្បីរំលត់ដោយការទូទាត់នោះបាន។[56] ហេតុដូច្នេះ បើកាតព្វកិច្ចរបស់ភាគីទាំងពីរត្រូវបានរំលត់ដោយការទូទាត់សិទ្ធិគ្នា នាំឱ្យសិទ្ធិឃាត់ទុកត្រូវរំលត់។

ឧទាហរណ៍៖ លោក A ធ្លាប់ជំពាក់ប្រាក់លោក B ចំនួន ៣០$។ ថ្ងៃមួយលោក B បានយកកំព្យូទ័រមកឱ្យលោក A ជួសជុល។ ដោយតម្លៃជួសជុលអស់ ១០០$ ក៏ប៉ុន្តែលោក B បានបង់តែ ៧០$ ហើយក៏ឯកភាពគ្នាទូទាត់សិទ្ធិលើបំណុលដែលមានចំពោះគ្នាទៅវិញទៅមកចំនួន ៣០$ នោះ។

ក្នុងករណីបែបនេះ សិទ្ធិលើបំណុលដែលមានចំពោះគ្នាត្រូវរំលត់ នាំឱ្យអានុភាពនៃសិទ្ធិឃាត់ទុកក៏គ្មាន ហើយបើទោះបីជាមានសិទ្ធិឃាត់ទុកក៏សិទ្ធិនោះត្រូវរំលត់ដែរ។

**កថាខណ្ឌទី៣៖ ការរំលត់សិទ្ធិឃាត់ទុកដោយកំហុសម្ចាស់បំណុល**

ការទាមទារឱ្យរំលត់សិទ្ធិឃាត់ទុក គឺជាការទាមទាររបស់កូនបំណុល ឬម្ចាស់វត្ថុ ចំពោះម្ចាស់សិទ្ធិឃាត់ទុកឱ្យរំលត់នូវសិទ្ធិឃាត់ទុក ដែលការទាមទារនេះមានអានុភាពដោយពុំចាំបាច់ធ្វើតាមផ្លូវតុលាការទេ។ ប៉ុន្តែក្នុងករណីដែលម្ចាស់សិទ្ធិឃាត់ទុកមិនព្រមប្រគល់វត្ថុឱ្យវិញទេនោះ នោះកូនបំណុល ឬកម្មសិទ្ធិករអាចទាមទារឱ្យប្រគល់វត្ថុឃាត់ទុកតាមផ្លូវតុលាការបាន ដោយផ្អែកលើកម្មសិទ្ធិ។ ម្យ៉ាងវិញទៀត កំហុសដែលអាចកើតមាន

[56] មាត្រា ៤៧២ កថាខណ្ឌទី១ វាក្យខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដោយម្ចាស់សិទ្ធិឃាត់ទុកនោះ អាចមានដូចជា ការប្រើប្រាស់វត្ថុឃាត់ទុកដោយបំពានសិទ្ធិម្ចាស់វត្ថុ និងការមិនបំពេញករណីកិច្ចមើលថែវត្ថុឱ្យបានល្អ។

### ក. ការប្រើប្រាស់វត្ថុឃាត់ទុកដោយបំពាន

ម្ចាស់វត្ថុមានសិទ្ធិទាមទារវត្ថុឃាត់ទុកនោះមកវិញ កាលបើម្ចាស់សិទ្ធិឃាត់ទុកមិនគោរពកាតព្វកិច្ចខ្លួនតាមដែលច្បាប់បានកំណត់។ រាល់ការប្រើប្រាស់វត្ថុឃាត់ទុក គឺត្រូវទទួលបានការអនុញ្ញាតពីម្ចាស់វត្ថុជាមុនសិន។ ម្ចាស់វត្ថុ ឬកូនបំណុលមានសិទ្ធិក្នុងការឱ្យយកទៅប្រើ ឬយក់ទៅដាក់ជួល ឬប្រាតិភោគ[57] បើម្ចាស់វត្ថុមិនអនុញ្ញាតទេគឺម្ចាស់សិទ្ធិឃាត់ទុកគ្មានសិទ្ធិធ្វើនោះទេ។ បើមិនដូច្នេះទេ ម្ចាស់សិទ្ធិឃាត់ទុកត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ លើកលែងតែករណីដែលម្ចាស់សិទ្ធិឃាត់ទុកប្រើប្រាស់ក្នុងកម្រិតដែលចាំបាច់ក្នុងការរក្សានូវវត្ថុឃាត់ទុកនោះតែប៉ុណ្ណោះ។[58]

ឧទាហរណ៍៖ លោក A បានឃាត់ទុករថយន្តរបស់លោក B ហើយលោក A បានយករថយន្តនោះទៅប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួនដោយមិនបានស្នើសុំពីលោក B នោះទេ។ នៅពេលលោក B បានដឹងអំពីរឿងនេះ ខ្លួនក៏បានទាមទារឱ្យលោក A ប្រគល់រថយន្តមកវិញ។

ក្នុងករណីនេះលោក A ត្រូវប្រគល់រថយន្តមកម្ចាស់ដើមវិញ ឬកូនបំណុលខ្លួន (ព្រោះ A មានកំហុស)។ ក៏ប៉ុន្តែបើលោក A នៅតែមិនព្រមប្រគល់រថយន្តមកលោក B ទេ នាំឱ្យលោក B អាចទាមទាររថយន្តតាមផ្លូវតុលាការបានដោយផ្អែកលើកម្មសិទ្ធិ។

### ខ. ការមិនបំពេញករណីកិច្ចមើលថែវត្ថុឱ្យបានល្អ

ក្នុងករណីម្ចាស់សិទ្ធិឃាត់ទុក បានប្រើប្រាស់វត្ថុឃាត់ទុកដោយពុំមានការយល់ព្រមពីកូនបំណុល ឬពុំបានអនុវត្តកាតព្វកិច្ចថែរក្សាវត្ថុដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត កូនបំណុលអាចទាមទារឱ្យរំលត់សិទ្ធិឃាត់ទុកបាន។[59] ម្ចាស់សិទ្ធិឃាតទុក ត្រូវមានករណីកិច្ចមើលថែរក្សាវត្ថុឃាត់ទុកក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត មិនអាចចេះតែឃាត់ហើយមិនខ្វាយខ្វល់ពីការមើលថែនោះឡើយ។ បើករណីដែលម្ចាស់សិទ្ធិឃាត់ទុកមានកំហុសក្នុងការមិនមើលថែរក្សាវត្ថុ ហើយបង្កជាគ្រោះថ្នាក់ដល់វត្ថុ ឬសិទ្ធិភាពនៃវត្ថុនោះ នាំឱ្យម្ចាស់វត្ថុ ឬកូនបំណុលមានសិទ្ធិក្នុងការទាមទាររំលត់សិទ្ធិឃាត់ទុកចំពោះម្ចាស់សិទ្ធិឃាត់ទុក។

ឧទារហណ៍៖ លោក A បានឃាត់ទុកម៉ូតូរបស់លោក B តែខ្លួនមិនបានយកម៉ូតូនោះទៅដាក់ទីកន្លែងសមរម្យ ដោយចេះតែបណ្ដោយទុកចោលនៅទីកន្លែងដែលត្រូវថ្ងៃ និងត្រូវភ្លៀងស្ទើរតែរាល់ថ្ងៃ ហើយម៉្យាងទៀត

[57] មាត្រា ៧៧៦ កថាខណ្ឌទី២ វាក្យខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[58] មាត្រាដដែល កថាខណ្ឌទី២ វាក្យខណ្ឌទី២

[59] មាត្រាដដែល កថាខណ្ឌទី១ និងទី៣

លោក B មិនដែលរវល់បើកដំណើរការម៉ាស៊ីនម៉ូតូម្ដងណាសោះ ជាហេតុនាំឱ្យម៉ូតូមានសភាពច្រេះ ស៊ីកពណ៌ និងគាំងម៉ាស៊ីន។

ក្នុងករណីនេះម្ចាស់វត្ថុ ឬកូនបំណុលមានសិទ្ធិទាមទាររំលត់សិទ្ធិឃាត់ទុករបស់ម្ចាស់សិទ្ធិឃាត់ទុកបាន។

## កថាខណ្ឌទី៤៖ ការរំលត់សិទ្ធិឃាត់ទុកដោយការផ្ដល់ប្រាតិភោគសមរម្យ

ការរំលត់សិទ្ធិឃាត់ទុក្នុងផ្នែកនេះ គឺសំដៅទៅលើការរំលត់ដោយសារការបង្កើតទំនាក់ទំនងគតិយុត្តថ្មី ពោលគឺសំដៅលើការបង្កើតជាកិច្ចសន្យាថ្មីមួយដើម្បីផ្លាស់ប្តូរកម្មវត្ថុនៃសិទ្ធិឃាត់ទុក និងជំនួសដោយវត្ថុមួយទៀត និងការសន្យានានាតាមការកំណត់ដោយគូភាគី។ ទំនាក់ទំនងនេះនឹងធ្វើឱ្យសិទ្ធិឃាត់ទុករបស់ម្ចាស់សិទ្ធិឃាត់ទុកត្រូវរំលត់ដោយមិនចាំបាច់មានបណ្ដឹងទៅតុលាការនោះឡើយ គឺរំលត់ដោយគូភាគីតែម្ដង។

### ក. ការផ្ដល់ប្រាតិភោគសមរម្យ

ការផ្ដល់ប្រាតិភោគសមរម្យ សំដៅទៅលើការដាក់វត្ថុធានាថ្មីមកជំនួសវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុកដែលមានពីមុនមក ឬកំពុងតែមានដើម្បីធានាសិទ្ធិលើបំណុលបន្តទៀត ដែលសកម្មភាពនេះនឹងញ៉ាំងឱ្យមានទំនាក់ទំនងគតិយុត្តមួយទៀតកើតឡើងតាមការចរចារបង្កើតជាទម្រង់កិច្ចសន្យាថ្មីមួយ។ កូនបំណុលអាចស្នើរសុំឱ្យរំលត់សិទ្ធិឃាត់ទុកបានដោយការផ្ដល់ប្រាតិភោគសមរម្យ។[60] ការរំលត់សិទ្ធិឃាត់ទុក ដោយការផ្ដល់ប្រាតិភោគ សំដៅលើការស្នើរសុំឱ្យរំលត់សិទ្ធិឃាត់ទុកដោយការដោះដូរវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុកដោយការដាក់ប្រាតិភោគផ្សេងតាមរយៈការព្រមព្រៀងរវាងម្ចាស់សិទ្ធិឃាត់ទុក និងកូនបំណុល។ ហេតុដូច្នេះ បើទោះបីជាសិទ្ធិលើបំណុលត្រូវបានធានាបន្តក៏ពិតមែន ប៉ុន្តែកម្មវត្ថុនៃសិទ្ធិឃាត់ទុកត្រូវបានបាត់បង់ ហើយជំនួសដោយកម្មវត្ថុនៃកិច្ចស្យាថ្មី នាំឱ្យសិទ្ធិឃាត់ទុកត្រូវរំលត់។

ឧទាហរណ៍៖ A បានយកសត្វឆ្មាជាទីស្រឡាញ់របស់ខ្លួនទៅព្យាបាលនៅពេទ្យរបស់ B។ ក្រោយពី B បានព្យាបាលសត្វឆ្មានោះជាសះស្បើយហើយ B ក៏បានហៅ A មកយកសត្វវិញព្រមទាំងទាមទារថ្លៃពិនិត្យ និងព្យាបាលជំងឺសរុប ៣០០ ដុល្លា។ A មិនមានលទ្ធភាពក្នុងការបង់ថ្លៃព្យាបាលទាំងស្រុងនោះទេ A បានសុំ B បង់ត្រឹម ១០០ ដុល្លាសិន ចាំ ៣ថ្ងៃក្រោយ A នឹងទូរទាត់ថ្លៃព្យាបាលឱ្យ B ទាំងអស់។ B បានយល់ព្រមប៉ុន្តែ B ត្រូវឃាត់ទុកឆ្មានោះសិន។ ៣ថ្ងៃក្រោយមក A នៅតែមិនមានលទ្ធភាពក្នុងការបង់ថ្លៃព្យាបាល ដោយការនឹងរលឹកសត្វឆ្មាំជាទីស្រឡាញ់របស់ខ្លួន A ក៏បានស្នើរសុំដាក់ទូរស័ព្ទដែលមានតម្លៃ ៥០០ ដុល្លា ទៅ B ដើម្បីធានាបំណុលបន្តទៀត និងមានបំណង់ដោះដូរយកសត្វឆ្មាមកមើលថែខ្លួនឯងវិញ ហើយសន្យាថាក្នុងរយៈពេល ១០

[60] មាត្រា ៧៧៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ថ្ងៃបើ ខ្លួនមិនមកលោះទូរស័ព្ទនេះទេ ទូរស័ព្ទនេះ និងក្លាយជាកម្មសិទ្ធិរបស់ B ដោយឃើញវត្ថុដែល A បានដាក់ប្រាតិភោគថ្មីជាវត្ថុមានតម្លៃសមរម្យ B ក៏បានយល់ព្រម។

ក្នុងករណីនេះ សត្វឆ្មាលែងស្ថិតក្រោមការគ្រប់គ្រងរបស់ B ទៀតហើយ ដោយសារតែ A និង B បានបង្កើតទំនាក់ទំនងគតិយុត្តថ្មី ជាហេតុនាំឱ្យសិទ្ធិឃាត់ទុកលើសត្វឆ្មារបស់ B ត្រូវបានរំលត់។

### ខ. ការប្រព្រឹត្តទៅនៃការដាក់ប្រាតិភោគ

ការទាមទារឱ្យរំលត់សិទ្ធិឃាត់ទុក ដោយដាក់ប្រាតិភោគថ្មីមិនមែនជាការទាមទារតាមផ្លូវតុលាការទេ គឺកូនបំណុលទាមទារទៅម្ចាស់សិទ្ធិឃាត់ទុកឱ្យរំលត់សិទ្ធិឃាត់ទុកដោយខ្លួនឯង តាមរយៈការដាក់ប្រាតិភោគថ្មីដ៏សមរម្យសម្រាប់ធានាសិទ្ធិលើបំណុលចំពោះម្ចាស់បំណុល។ ការដាក់ប្រាតិភោគសមរម្យ មិនមែនជាការបង្កើតសិទ្ធិឃាត់ទុកថ្មីនោះទេ ដោយសារតែសិទ្ធិឃាត់ទុកមានទំនាក់ទំនងជាមួយវត្ថុដែលឃាត់ទុក បើសិនជាប្តូរវត្ថុឃាត់ទុកចេញ នោះនាំឱ្យសិទ្ធិឃាត់ទុកត្រូវបានរំលត់ព្រោះកម្មវត្ថុនៃសិទ្ធិឃាត់ទុកលែងស្ថិតក្រោមការកាន់កាប់របស់ម្ចាស់សិទ្ធិឃាត់ទុកទៀតហើយ។ ចំពោះការដាក់ប្រាកតិភោគនេះ គឺអាចធ្វើទៅបាន ឬមិនបានគឺអាស្រ័យលើម្ចាស់សិទ្ធិឃាត់ទុកយល់ព្រម ឬមិនយល់ព្រមតាមការស្នើរសុំរបស់កូនបំណុលដែលបានស្នើរសុំដាក់ប្រាតិភោគថ្មីដើម្បីរំលត់សិទ្ធិឃាត់ទុកនោះ។

ឧទាហរណ៍៖ A ជាកូនបំណុលបានស្នើរសុំដាក់ទូរស័ព្ទក្នុងការធានាបំណុលដើម្បីយកសត្វឆ្មាដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុករបស់ B ត្រឡប់ទៅវិញ ប៉ុន្តែ B មិនចង់បានទូរស័ព្ទរបស់ A នោះទេ B គ្រាន់តែចង់បានសេវាថ្លៃព្យាបាលសត្វឆ្មាតែប៉ុណ្ណោះ។ ដូច្នេះ B មិនយល់ព្រមក្នុងការបង្កើតប្រាតិភោគថ្មីទេ ហើយ B នៅតែបន្តកាន់កាប់សត្វឆ្មានោះរហូតដល់ A បំពេញកាតព្វកិច្ចសង់បំណុលអស់ទើប B ព្រមប្រគល់សត្វឆ្មានេះត្រឡប់ទៅវិញ។ ហេតុនេះ បើទោះបីជា A បានស្នើរសុំដាក់ប្រាតិភោគថ្មីដើម្បីធានាបំណុលក៏ដោយ បើ B មិនយល់ព្រមបង្កើតទេ នោះការរំលត់សទ្ធិឃាត់ទុកមិនអាចធ្វើបាននោះឡើយ។

## ផ្នែកទី២៖ ការរំលត់សិទ្ធិឃាត់ទុកដោយមូលហេតុភាពចាំបាច់

### កថាខណ្ឌទី១៖ ការរំលត់សិទ្ធិឃាត់ទុកដោយការអនុវត្តដោយបង្ខំ

ការរំលត់សិទ្ធិឃាត់ទុកដោយការអនុវត្តដោយបង្ខំ សំដៅទៅលើសិទ្ធិឃាត់ទុកត្រូវបានរំលត់ តាមរយៈការអនុវត្តដោយបង្ខំតាមផ្លូវតុលាការ ដោយការដាក់ពាក្យស្នើរសុំរបស់ម្ចាស់សិទ្ធិឃាត់ទុក។ ការអនុវត្តដោយបង្ខំដោយសិទ្ធិឃាត់ទុកមានគោលបំណងប្តូរកម្មវត្ថុនៃសិទ្ធិឃាត់ទុកជាប្រាក់ ដើម្បីទូរទាត់បំណុលដែលកូនបំណុលជំពាក់។ ហេតុដូចនេះ ក្រោយពេលតុលាការសម្រេចអនុវត្តដោយបង្ខំដោយសិទ្ធិឃាត់ទុកហើយ សិទ្ធិឃាត់ទុកត្រូវបានរំលត់។ ថ្វីបើប្រាក់ដែលបានពីការលក់ដោយបង្ខំលើវត្ថុឃាត់ទុកត្រូវបានប្រគល់ឱ្យទៅម្ចាស់សិទ្ធិឃាត់ទុកក៏ពិតមែន តែម្ចាស់សិទ្ធិឃាត់ទុកពុំមានសិទ្ធិចំពោះប្រាក់ដែលបានពីការលក់ដោយបង្ខំនោះឡើយ ព្រោះថា

ម្ចាស់សិទ្ធិឃាត់ទុកមានសិទ្ធិឃាត់ទុកតែវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុកតែប៉ុណ្ណោះ មិនមានសិទ្ធិលើការកាន់កាប់ប្រាក់ដែលបានមកពីការលក់ដោយបង្ខំនៃវត្ថុឃាត់ទុកនោះទេ។ ម្យ៉ាងទៀត នៅពេលដែលម្ចាស់សិទ្ធិឃាត់ទុកបានអនុវត្តដោយបង្ខំតាមផ្លូវតុលាការរួច ម្ចាស់សិទ្ធិឃាត់ទុកលែងមានការកាន់កាប់ចំពោះវត្ថុឃាត់ទុកទៀតហើយ ពោលគឺវត្ថុឃាត់ទុកនោះត្រូវបានប្តូរជាប្រាក់ តែម្ចាស់សិទ្ធិឃាត់ទុកអាចកាត់សិទ្ធិលើបំណុលដែលខ្លួនមាន រួចចំណែកដែលនៅសល់ទើបប្រគល់ឱ្យកូនបំណុលតាមការស្នើរសុំ។

យើងសង្កេតឃើញថា ការអនុវត្តដោយបង្ខំដោយសិទ្ធិឃាត់ទុក កើតមានឡើងតាមរយៈ ២ករណី នៅពេលដែល កូនបំណុលមិនព្រមបំពេញកាតព្វកិច្ចសងសំណង និងនៅពេលដែលម្ចាស់សិទ្ធិឃាត់មានការពិបាកក្នុងការមើលថែរក្សាវត្ថុឃាត់ទុកនោះ។

### ក. ករណីកូនបំណុលមិនព្រមសង

កាលដែលកូនបំណុលនៃសិទ្ធិឃាត់ទុកមិនព្រមបំពេញកាតព្វកិច្ចសង ហើយម្ចាស់សិទ្ធិឃាត់ទុកយល់ឃើញថា កូនបំណុលមិនមានចេតនាសង ឬគ្មានលទ្ធិភាពសងឱ្យទាន់ពេលវេលា នោះម្ចាស់សិទ្ធិឃាត់ទុកអាចអនុវត្តដោយបង្ខំដោយសិទ្ធិឃាត់ទុកបានតាមនីតិវិធិដូចជាការស្នើរសុំទៅតុលាការ។

ឧទាហរណ៍៖ B ជាម្ចាស់សិទ្ធិឃាត់ទុកលើម៉ូតូរបស់លោក A ដោយសារតែ A មិនព្រមបង់ថ្លៃជួសជុល។ កន្លងផុតច្រើនថ្ងៃ B បានជូនដំណឹងទៅ A ជាច្រើនដងដែរ នៅតែមិនឃើញ A មកសងថ្លៃជួសជុល។

ក្នុងករណីនេះ B អាចស្នើរសុំទៅតុលាការក្នុងការអនុវត្តដោយបង្ខំលើម៉ូតូនោះបានដើម្បីកាត់សិទ្ធិលើបំណុលដែល A ជំពាក់។

### ខ. ករណីពិបាកក្នុងការមើលថែរក្សាវត្ថុឃាត់ទុក

ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកមានការលំបាកក្នុងការមើលថែរក្សាវត្ថុឃាត់ទុក ដូចជាការដែរត្រូវចំណាយកម្លាំងពលកម្ម ឬសោហ៊ុយជាប្រចាំដើម្បីមើលថែរក្សាវត្ថុឃាត់ទុកនោះ ឬវត្ថុនោះមិនអាចឃាត់ទុកបានរយៈពេលយូបាន។ ក្នុងករណីនេះ ទោះបីជាកូនបំណុលសន្យាថាខ្លួននឹងសង ឬមានលទ្ធភាពអាចនឹងសងយ៉ាងណាក៏ដោយ ប្រសិនបើវត្ថុឃាត់ទុកនោះបង្កភាពលំបាក ឬមិនអាចបន្តឃាត់ទុកតទៅទៀតបាន នោះម្ចាស់សិទ្ធិឃាត់ទុកអាចស្នើរសុំអនុវត្តដោយបង្ខំដោយសិទ្ធិឃាត់ទុកបានតាមផ្លូវតុលាការ ហើយសិទ្ធិឃាត់ទុកនឹងត្រូវរំលត់នៅពេលវត្ថុត្រូវបានប្តូរជាប្រាក់។

ឧទាហរណ៍៖ លោក B ជាម្ចាស់សិទ្ធិឃាត់ទុកលើសត្វឆ្កែរបស់លោក A ដោយសារតែ A មិនមានលទ្ធិភាពគ្រប់គ្រាន់ក្នុងការបង់ថ្លៃព្យាបាលសត្វឆ្កែនោះ។ កន្លងផុតច្រើនថ្ងៃហើយ A មិនបានមកបំពេញកាតព្វកិច្ចសងបំណុល ព្រមទាំង B មានការលំបាកក្នុងការថែរក្សាឆ្កែនោះផង ម្យ៉ាងវិញទៀត ឆ្កែមួយក្បាលនោះវាស៊ីរើសចំណីណាស់។

ក្នុងករណីនេះ B អាចអនុវត្តដោយបង្ខំលើសត្វឆ្កែនោះដោយលក់វាទៅឱ្យហាងចិញ្ចឹមសត្វ ដើម្បីកាត់សិទ្ធិលើបំណុលព្រមទាំងសោហ៊ុយចំណាយដែល B បានចេញក្នុងការថែរក្សាសត្វឆ្កែនោះបាន (សិទ្ធិលើបំណុលត្រូវរំលត់)។

## ផ្នែកទី៣៖ ការរំលត់ដោយអាជ្ញាយុកាល

សិទ្ធិឃាត់ទុកកើតមានបានលុះត្រាតែមានសិទ្ធិលើបំណុលកើតឡើង កាលណាសិទ្ធិលើបំណុលត្រូវបានរំលត់ដោយការផុតអាជ្ញាយុកាល នោះនាំឱ្យសិទ្ធិឃាត់ទុកក៏ត្រូវរំលត់ទៅតាមសិទ្ធិលើបំណុលដែរ។ ចំណែកឯការផ្អាក់ និងការបង្អង់អាជ្ញាយុកាលនៃសិទ្ធិឃាត់ទុកនេះក៏ត្រូវអនុវត្តដូចគ្នាទៅនឹងបទបញ្ញត្តិស្តីពីការផ្អាក់ និងការបង្អង់អាជ្ញាយុកាលនៃសិទ្ធិលើបំណុលផងដែរ។ ហេតុដូច្នេះ ដើម្បីកំណត់ការផុតអាជ្ញាយុកាល គឺត្រូវតែបញ្ជាប់អានុភាពនៃលក្ខខណ្ឌផ្អាក់ និងបង្អង់ជាមុនសិនក្នុងករណីបើមាន រួចទើបការផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវចាប់រាប់គិតបន្ត។ តើអ្វីទៅជាការផុតអាជ្ញាយុកាលនៃសិទ្ធិលើបំណុល? ហើយតើការផ្អាក់ និងការបង្អង់នៃអាជ្ញាយុកាលនេះវាខុសគ្នាយ៉ាងដូចម្តេច?

### កថាខណ្ឌទី១៖ ការផុតអាជ្ញាយុកាលនៃសិទ្ធិលើបំណុល

សិទ្ធិឃាត់ទុកត្រូវតែផ្សារភ្ជាប់ជាមួយនឹងសិទ្ធិលើបំណុលជានិច្ច។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល សំដៅទៅលើការរំលត់សិទ្ធិលើបំណុលដោយផ្អែកលើការណ៍ដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិក្នុងអំឡុងពេលដែលត្រូវបានកំណត់។[61] អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺមានអានុភាពប្រតិសកម្ម (អនុភាពនៃលក្ខខណ្ឌគតិយុត្តដែលមានទៅលើសកម្មភាពពីអតីតកាល) ចាប់តាំងពីថ្ងៃដែលចាប់ផ្តើមគិតអាជ្ញាយុកាល មានន័យថា បើអាជ្ញាយុកាលនោះបានកន្លងផុត ដូច្នេះ សិទ្ធិលើបំណុលត្រូវបានរំលត់ដោយប្រតិសកម្មចាប់ពីថ្ងៃដែលចាប់ផ្តើមគិតអាជ្ញាយុកាលមកម្ល៉េះ ហើយនឹងនាំឱ្យកូនបំណុលរួចផុតពីកាតព្វកិច្ច ឬ សំណងនៃការខូចខាតផ្សេងៗទៀតដែលបានកើតឡើងនៅក្នុងអំឡុងពេលចាប់ផ្តើមគិតអាជ្ញាយុកាលនេះ។ អ្នកដែលមានសិទ្ធិអាចលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះ គឺមានដូចជាកូនបំណុល ឬ កូនបំណុលដោយសាមគ្គីភាព អ្នកធានាបំណុល អ្នកធានាបំណុលដោយវត្ថុ តតិយជនដែលបានធ្វើលទ្ធកម្ម និងបុគ្គលដែលមានផលប្រយោជន៍ត្រឹមត្រូវតាមផ្លូវច្បាប់។[62] ចំពោះការអនុវត្តសិទ្ធិឃាត់ទុក គឺមិនរារាំងដំណើរការអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ។[63] បទបញ្ញត្តិនេះចង់បញ្ជាក់ថា ទោះបីជាម្ចាស់សិទ្ធិឃាត់ទុកទើបតែអនុវត្ត

---

[61] មាត្រា ៤៨០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[62] ដក់ស្រង់ចេញពី គេហទំព័ររបស់ ក្រុមហ៊ុនមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ "យល់ដឹងផ្នែកច្បាប់៖ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល" កាលបរិច្ឆេទថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១

[63] មាត្រា ៧៧៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

សិទ្ធិឃាត់ទុក (ជួល ប្រើប្រាស់ ឬប្រាតិភោគ...) ក៏ដោយ ក៏អាជ្ញាយុកាលនៃការរំលត់សិទ្ធិឃាត់ទុកនៅតែគិតរាប់ចាប់ពីពេលដែលកើតមានសិទ្ធិលើបំណុលដដែល។ ហេតុដូច្នេះ ប្រសិនបើសិទ្ធិលើបំណុលត្រូវបានផុតអាជ្ញាយុកាល នោះសិទ្ធិឃាត់ទុករបស់ម្ចាស់បំណុលត្រូវរំលត់ ហើយត្រូវប្រគល់វត្ថុឃាត់ទុកឱ្យទៅម្ចាស់កម្មសិទ្ធិកវិញតាមការទាមទារ។

បើយោងទៅតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុកត្រូវបានបែងចែកជា ៣ ក្នុងនោះរួមមាន អាជ្ញាយុការនៃការរំលត់សិទ្ធិលើបំណុលទូទៅ អាជ្ញាយុការនៃការរំលត់សិទ្ធិលើបំណុលមានអំឡុងពេលខ្លី និងអាជ្ញាយុការនៃការរំលត់សិទ្ធិលើបំណុលដែលចូលជាស្ថាពរ។

**ក. អាជ្ញាយុការនៃការរំលត់សិទ្ធិលើបំណុលទូទៅ**

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅមានអំឡុងពេល ៥ ឆ្នាំ។ ជាទូទៅគ្រប់សិទ្ធិលើបំណុលទាំងអស់សុទ្ធតែមានអំឡុងពេល ៥ ឆ្នាំ ដែលគិតចាប់ពីពេលដែលម្ចាស់បំណុលអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនបាន[64]។ បានន័យថា ប្រសិនបើម្ចាស់បំណុលមិនអនុវត្តសិទ្ធិដែលខ្លួនមានក្នុងអំឡុងពេល ៥ ឆ្នាំ ដែលគិតចាប់ពីពេលសិទ្ធិលើបំណុលកើតមាន នោះនាំឱ្យសិទ្ធិលើបំណុលត្រូវបានរំលត់ដោយផុតអាជ្ញាយកាល។ ដូច្នេះ កាលណាសិទ្ធិលើបំណុលត្រូវបានរំលត់ដោយផុតអាជ្ញាយុកាលហើយ សិទ្ធិឃាត់ទុកក៏ត្រូវបានរំលត់ដូចគ្នា។ លើកលែងតែសិទ្ធិលើបំណុលខ្លះមានបទបញ្ញត្តិ ឬច្បាប់ ឬបទដ្ឋានគតិយុត្តិផ្សេងកំណត់ពី អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះ។[65]

ឧទាហរណ៍៖ B ជាម្ចាស់សិទ្ធិឃាត់ទុកលើរថយន្តរបស់ A ដោយសារតែ A មិនបានបង់ប្រាក់គ្រប់ចំនួនមកឱ្យ B។ B បានឃាត់ទុកឡានរបស់ A នៅថ្ងៃទី ០១ ខែមីនា ឆ្នាំ២០១៨។ B មិនបានអនុវត្តដោយបង្ខំដោយសិទ្ធិឃាត់ទុកទេ ព្រោះ B មិនចង់មានរឿងវែងឆ្ងាយក៏ចេះតែទុកឡាននោះទៅ។ រំលងផុតរយៈពេល ៥ឆ្នាំក្រោយនៅថ្ងៃទី ០១ កក្កដា ២០២៣ ស្រាប់តែ A មកទាមទារយកឡាននោះវិញ ដោយអះអាងពីបញ្ញត្តិនៃការរំលត់សិទ្ធិលើបំណុលដោយការផុតអាជ្ញាយុកាល។

ក្នុងករណីនេះ សិទ្ធិលើកបំណុលរបស់ B ត្រូវបានរំលត់ដោយការផុតអាជ្ញាតុកាល នាំឱ្យសិទ្ធិឃាត់ទុកក៏ត្រូវបាត់បង់។ ដូច្នេះ B ត្រូវប្រគល់ឡាននោះឱ្យ A វិញ។

**ខ. អាជ្ញាយុការនៃការរំលត់សិទ្ធិលើបំណុលមានអំឡុងពេលខ្លី**

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលមានអំឡុងពេលខ្លី វាខុសប្លែកគ្នាពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ ដោយហេតុថាអាជ្ញាយុកាលនេះមានម្ចាស់បំណុលជាពាណិជ្ជករ ឬផលិតករ ហើយ

[64] មាត្រា ៤៨១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[65] មាត្រា ៤៨២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

កូនបំណុលមិនមែនជាពាណិជ្ជករ ឬផលិតករ ។ ចំពោះសិទ្ធិលើបំណុលអំពីថ្លៃទំនិញដែលពាណិជ្ជករលក់ទៅឱ្យអ្នកដែលមិនមែនជាពាណិជ្ជករ និងថ្លៃសេវាដែលផលិតករផ្តល់ឱ្យអ្នកដែលមិនមែនជាផលិតករ អាជ្ញាយុកាលនៃការរំលត់សិទ្ធិនេះមានអំឡុងពេល ២ (ពីរ) ឆ្នាំ។[66]

ឧទាហរណ៍៖ B ជាជាងមាស និងជាម្ចាស់សិទ្ធិឃាត់ទុកលើខ្សែរករមាសរបស់ A ដោយសារតែ A មិនព្រមបង់ថ្លៃសេវាកែឆ្នៃខ្សែរករមាសតាមថ្ងៃកំណត់។ ជាអកុសល A ទទួលមរណៈភាពដោយពុំបានផ្តាំផ្ញើសាច់ញាតិណាឱ្យដឹងអំពីរឿងយកខ្សែរករមាសទៅកែឆ្នៃនៅហាងរបស់ B ឡើយ។ ។ B ចេះតែឃាត់ទុកខ្សែរករនោះរហូតមកដោយពុំបានអនុវត្តសិទ្ធិអ្វីទេ។ កន្លងផុតអស់រយៈពេល ២ ឆ្នាំកន្លះទើបកូនៗរបស់ A បានដឹងអំពីរឿងហេតុនេះ ក៏នាំគ្នាទៅទាមទារយកខ្សែរករមាសមកវិញ។

ក្នុងករណីនេះ B មិនអាចអះអាងអំពីសិទ្ធិលើបំណុលដែលខ្លួនមានបានទៀតឡើយ ព្រោះផុតអាជ្ញាយុកាល (២ឆ្នាំ) និងម៉្យាងវិញទៀតសិទ្ធិឃាត់ទុកខ្សែរករមាសនោះក៏ត្រូវបានរំលត់តាមសិទ្ធិលើបំណុលផងដែរ។ ដូច្នេះ B ត្រូវប្រគល់វត្ថុឱ្យទៅកូនរបស់ A វិញ។

### គ. អាជ្ញាយុការនៃការរំលត់សិទ្ធិលើបំណុលដែលចូលជាស្ថាពរ

សិទ្ធិលើបំណុលដែលបានចូលជាស្ថាពរ ដោយសាលក្រម ឬសាលដីកាស្ថាពរ ឬដោយការផ្សះផ្សាតាមផ្លូវតុលាការ ឬដោយវិធីផ្សេងដែលមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ ទោះបីជាមានការបញ្ញត្តិដែលកំណត់អំឡុងពេលនៃអាជ្ញាយុកាលតិចជាង ៥ ឆ្នាំ គិតចាប់ពីពេលដែលសិទ្ធិលើបំណុលនោះចូលជាស្ថាពរដែរ។[67] អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលចូលជាស្ថាពរ មានលក្ខណៈខុសគ្នាជាមួយនឹងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ ត្រង់ពេលវេលានៃការចាប់ផ្តើមគិតចាប់ពីពេលដែលសាលក្រម ឬសាលដីកាចូលជាស្ថាពរ ឬការផ្សះផ្សា ការលះបង់ការទាមទារ ឬការទទួលស្គាល់ការទាមទារតាមផ្លូវតុលាការ។

## កថាខណ្ឌទី២៖ ការផ្អាក់អាជ្ញាយុកាលនៃសិទ្ធិលើបំណុល

ការផ្អាក់អាជ្ញាយុកាលនៃសិទ្ធិលើបំណុល គឺជាការផ្អាក់ដំណើរការនៃអាជ្ញាយុកាល ក្នុងករណីដែលមានហេតុកំណត់មួយចំនួនដែលបានកំណត់ដោយច្បាប់ នៅក្នុងក្រមរដ្ឋប្បវេណីបានចែងអំពីការផ្អាក់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានដូចជាករណី ការទាមទារតាមផ្លូវតុលាការ ការចូលរួមក្នុងនីតិវិធីធនក្ស័យ ឬការអនុវត្តសិទ្ធិដែលមានលក្ខណៈប្រហាក់ប្រហែល សកម្មភាពអនុវត្តដោយបង្ខំ ឬការចាត់ចែងរក្សាការពារ ឬការទទួលស្គាល់កាតព្វកិច្ច ដោយការសងមួយផ្នែក ការបង់ការប្រាក់ និងការដាក់ប្រាតិភោគ ជាដើម។[68] ចំពោះ

[66] មាត្រា ៤៨៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[67] មាត្រា ៤៨៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[68] មាត្រា ៤៨៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដំណើរការអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក្រោយបានផ្អាក់ នឹងចាប់ផ្តើមគិតជាថ្មីម្តងទៀតក្រោយពីហេតុនៃការផ្អាក់ត្រូវបានចប់ ចំណែកឯអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាមទារតាមផ្លូវតុលាការនឹងចាប់ផ្តើមគិតជាថ្មីម្តងទៀតបន្ទាប់ពីសេចក្តីសម្រេចចូលជាស្ថាពរ។[69]

### ក. ការផ្អាក់អាជ្ញាយុកាលតាមផ្លូវតុលាការ

ជាគោលការណ៍ ម្ចាស់បំណុលអាចធ្វើការទាមទារតាមផ្លូវតុលាការឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច។ ការទាមទារតាមផ្លូវតុលាការនេះធ្វើឡើងតាមរយៈការដាក់ពាក្យបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក ឬការជ្រើសរើសយកនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច ឬតាមរយៈនីតិវិធីដាស់តឿន។ ការទាមទារតាមផ្លូវតុលាការនាំឱ្យមានអានុភាពផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ចាប់តាំងពីថ្ងៃដែលដើមចោទបានដាក់ពាក្យបណ្តឹង ឬពាក្យសុំទៅតុលាការ។ ប៉ុន្តែដើម្បីឱ្យការទាមទារតាមផ្លូវតុលាការមានអានុភាពផ្អាកអាជ្ញាយុកាលបាន លុះត្រាតែពាក្យប្តឹង ឬពាក្យសុំនោះត្រឹមត្រូវតាមច្បាប់ ហើយតុលាការយកមកចាត់ការតាមនីតិវិធី។ ផ្ទុយទៅវិញ ប្រសិនបើពាក្យបណ្តឹង ឬពាក្យសុំនោះ ត្រូវបានតុលាការលើកចោល ឬត្រូវបានដកវិញ នោះវាមិននាំឱ្យមានអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ។[70] អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងត្រូវរាប់គិតចាប់ផ្តើមជាថ្មី នៅពេលដែលនីតិវិធីនៃបណ្តឹងត្រូវបានបញ្ចប់ ពោលគឺការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា ឬដីកាសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយការប្រកាសអនុវត្តជាបណ្តោះអាសន្ន។

ឧទាហរណ៍៖ សិទ្ធិលើបំណុលរបស់ A ចំពោះ B កើតមានពីថ្ងៃទី០២ ខែមករា ឆ្នាំ២០១៥ លុះមកដល់ថ្ងៃទី០២ ខែមករា ឆ្នាំ២០១៦ ក៏កើតមានរឿងក្តីដោយ A និង B បានប្តឹងផ្តល់គ្នាទៅតុលាការលើអង្គហេតុទាក់ទងនឹងសិទ្ធិលើបំណុលខាងលើ។ បន្ទាប់មកតុលាការក៏សម្រេចចេញដីកាទទួលស្គាល់សិទ្ធិលើបំណុលរបស់ A ហើយបានចូលជាស្ថាពរនៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១៧។ ហេតុដូច្នេះ អាជ្ញាយុកាលនៃសិទ្ធិលើបំណុលរបស់ A ត្រូវបានផ្អាក់គិតពីថ្ងៃទី០២ ខែមករា ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ ទើបរាប់គិតជាថ្មីម្តងទៀតពីថ្ងៃទី០២ ខែមករា ឆ្នាំ២០១៧ រហូតដល់ការកំណត់នៃអាជ្ញាយុកាលដែលច្បាប់កំណត់។

### ខ. ការផ្អាក់ដោយសកម្មភាពចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារ គឺជាសកម្មភាពដែលមានលក្ខណៈជាការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលជាបណ្តោះអាសន្ន។ ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលអាចកើតមានបាន ដោយមូលហេតុម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យចាត់ចែងរក្សាការពារទៅតុលាការ។ ចំពោះការផ្អាកអាជ្ញាយុកាលនេះ ត្រូវមានអានុភាពចាប់តាំងពីពេលដែលពាក្យសុំនោះត្រូវបានដាក់ទៅតុលាការ ហើយតុលាការបានចេញដីការ

[69] មាត្រា ៤៩៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[70] មាត្រា ៤៩១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

សម្រេចរក្សាការពារតាមការស្នើរសុំ។ ម៉្យាងវិញទៀត តុលាការត្រូវអនុវត្តដីការហូតដល់ពេលដែលអានុភាពនៃដីការចាត់ចែងរក្សាការពារត្រូវបានបញ្ចប់ ប៉ុន្តែតុលាការក៏អាចចេញដីកាសម្រេចលុបចោលដីការក្សាការពារបានគ្រប់ពេលវេលាផងដែរ។ ក្នុងករណីតុលាការចេញដីការសម្រេចលុបចោលដីកាសម្រេចរក្សាការពារ នោះអានុភាពនៃការផ្អាក់អាជ្ញាយុកាលសិទ្ធិលើបំណុលដោយការចាត់ចែងរក្សាការពារ ត្រូវចាត់ទុកថាមិនបានកើតឡើងឡើយ។[71] មានន័យថា នៅពេលដែលមានដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ នាំឱ្យអំឡុងពេលផ្អាក់ដែលបានរាប់គិតពីថ្ងៃដាក់ពាក្យសុំដីការរក្សាការពារពីមុន ត្រូវចាត់ទុកជាមោឃៈ ហើយត្រូវរាប់អាជ្ញាយុកាលបន្តពីថ្ងៃដែលដាក់ពាក្យសុំនោះឡើងវិញ ពោលគឺមិនទទួលបានអានុភាពផ្អាក់ទេ។

ការលុបចោលដីកាសម្រេចរក្សាការពារមានមូលហេតុ ៣ យ៉ាង៖

1.ម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹង ឬឯកសារបញ្ជាក់ដើម្បីដាក់ពាក្យបណ្តឹងក្នុងអំឡុងពេល ២សប្តាហ៍ ឬពាក្យបណ្តឹងនោះត្រូវបានលើកចោល។[72]

2. ការលុបចោលដីកាសម្រេចរក្សាការពារដោយសារការផ្លាស់ប្តូរនូវសកម្មភាព បើមានការរលត់សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលត្រូវបានរក្សាការពារ ឬភាពចាំបាច់ក្នុងការរក្សាការពារ ឬការផ្លាស់ប្តូរស្ថានភាពផ្សេងទៀត។[73]

3. ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដោយសារស្ថានភាពពិសេស ប្រសិនបើមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន និងកើតឡើងដោយសារដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន តុលាការអាចលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ននោះ ដោយឱ្យដាក់ប្រាតិភោគតាមពាក្យសុំរបស់កូនបំណុល។[74]

ឧទាហរណ៍៖ B បានឃាត់ទុកផ្ទះរបស់ A នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ហើយ A មិនព្រមសងបំណុលខ្លួនឡើយ នោះ B ក៏សម្រេចដាក់ពាក្យសុំអនុវត្តដោយបង្ខំលើផ្ទះរបស់ A ទៅតុលាការ។ ដោយហេតុថា B មានការបារម្ភចំពោះវត្ថុឃាត់ទុកមិនអាចអនុវត្តបាន ឬមានភាពលំបាកក្នុងការអនុវត្តនាំឱ្យ B បានស្នើរសុំដីកាសម្រេចរក្សាការពារពីតុលាការដើម្បីរឹបអូសជាបណ្តោះអាសន្នចំពោះផ្ទះរបស់ A នៅថ្ងៃទី០១ ខែមីនា ឆ្នាំ ២០១៩។

ក្នុងករណីដែលតុលាការសម្រេចចេញដីកាសម្រេចរក្សាការពារតាមការសុំរបស់ B នាំឱ្យអានុភាពអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរបស់ B ត្រូវបានផ្អាក់រាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩។ ប្រសិនបើតុលាការ

[71] មាត្រា ៤៩២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[72] មាត្រា ៥៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[73] មាត្រា ៥៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[74] មាត្រា ៥៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ចេញដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារដោយមូលហេតុណាមួយវិញ នោះនាំឱ្យអានុភាពនៃការផ្អាកអាជ្ញាយុកាលដែលបានរាប់គិតពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩ ត្រូវចាត់ទុកថាមិនបានកើតមានឡើង នាំឱ្យអានុភាពអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរបស់ B ត្រូវរាប់បន្តពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩។

**គ. ការផ្អាក់ដោយការទទួលស្គាល់កាតព្វកិច្ច**

ក្រមរដ្ឋប្បវេណីបានបញ្ញត្តិយ៉ាងច្បាស់លាស់អំពីមូលហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលតាមរយៈការទទួលស្គាល់កាតព្វកិច្ចរបស់កូនបំណុលដោយធ្វើការសងមួយផ្នែក ឬការបង់ការប្រាក់ ការដាក់ប្រាតិភោគ ឬវិធីផ្សេងទៀតដែលអាចធានាបានថា កូនបំណុលមានឆន្ទៈអនុវត្តកាតព្វកិច្ច។[75] ការទទួលស្គាល់កាតព្វកិច្ច គឺជាមូលហេតុមួយក្នុងចំណោមមូលហេតុដទៃទៀតនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។ មិនតែប៉ុណ្ណោះ ការទទួលស្គាល់កាតព្វកិច្ច គឺជាការទទួលស្គាល់នូវអត្ថិភាពនៃកាតព្វកិច្ចដោយកូនបំណុល ពោលគឺកូនបំណុលយល់ព្រមអនុវត្តកាតព្វកិច្ច។ ក្នុងករណី ដែលកូនបំណុលបានទទួលស្គាល់នូវកាតព្វកិច្ចដោយសកម្មភាពរបស់ខ្លួន ច្បាប់ចាំបាច់ត្រូវការពារផលប្រយោជន៍របស់ម្ចាស់បំណុលដែលអាចរងចាំដោយមិនអនុវត្តសិទ្ធិដោយមានជំនឿទៅលើសកម្មភាពនោះ។

ឧទាហរណ៍៖ B ជាម្ចាស់សិទ្ធិឃាត់ទុកលើផ្ទះរបស់ A ដោយសារតែ A មិនព្រមបង់ថ្លៃជួសជុលផ្ទះជួលដែល B បានស្នាក់នៅ។ ក្រោយពី B បានឃាត់ទុកផ្ទះនេះអស់រយៈពេល ៥ថ្ងៃ A មានការខាត់បង់ជាខ្លាំងទើបយល់ព្រមទទួលស្គាល់កាតព្វកិច្ចសងប្រាក់មួយផ្នែកសិន ហើយសន្យាថា នឹងសងបង្គ្រប់នៅខែក្រោយ។

ក្នុងករណីនេះ នៅពេលដែលកូនបំណុលទទួលស្គាល់កាតព្វកិច្ចរបស់ខ្លួន អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរបស់ B ត្រូវផ្អាក់សិនរហូតដល់ពេលដែលហេតុនៃការផ្អាក់បានចប់។ ហេតុដូច្នេះ ប្រសិនបើកូនបំណុលអនុវត្តកាតព្វកិច្ចសងដែរ តែក៏បញ្ឈប់ការសងទៅវិញ នោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរបស់ B នឹងត្រូវគិតជាថ្មីម្តងទៀត។

**កថាខណ្ឌទី៣៖ ការបង្អង់អាជ្ញាយុកាលនៃសិទ្ធិលើបំណុល**

ការបង្អង់អាជ្ញាយុកកាលនៃសិទ្ធិលើបំណុល គឺជាការបញ្ឈប់ដំណើរការនៃការផុតអាជ្ញាយុកាលសិទ្ធិលើបំណុលមួយរយៈពេលសិន ហើយនឹងត្រូវរាប់គិតបន្តទៅមុខទៀតនៅពេលដែលការបញ្ឈប់អាជ្ញាយុកាលនោះត្រូវបានបញ្ចប់តាមការកំណត់ដោយច្បាប់ ពោលគឺវាមិនមានអានុភាពរាប់គិតអាជ្ញាយុកាលសារជាថ្មីដូចករណីនៃការផ្អាក់អាជ្ញាយុកាលខាងលើនោះទេ។ ការបង្អង់អាជ្ញាយុកាលនេះ គឺគ្រាន់តែជាការធ្វើកុំឱ្យអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានសម្រេចតែប៉ុណ្ណោះ។

[75] មាត្រា ៤៨៩ កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ក. ការបន្ទាល់អាជ្ញាយុកាលដោយការដាស់តឿន

ប្រសិនបើអ្នកមានសិទ្ធិ បានដាស់តឿននៅពេលណាមួយក្នុងអំឡុង៦ ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលរំលត់សិទ្ធិលើបំណុលនោះមិនត្រូវបានសម្រេចចំពោះអ្នកនោះក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីការដាស់តឿនឡើយ។[76] ក្នុងករណីនេះបើម្ចាស់សិទ្ធិឃាត់ទុកបានធ្វើការជូនដំណឹងដើម្បីដាស់តឿនដល់កូនបំណុលឱ្យបំពេញកាតព្វកិច្ចក្នុងរយៈពេល ៦ខែចុងក្រោយមុនផុតអាជ្ញាយុកាលនៃសិទ្ធិលើបំណុល នាំឱ្យរយៈពេលនៃការផុតអាជ្ញាយុកាលរបស់ម្ចាស់សិទ្ធិឃាត់ទុកត្រូវបានបង្អង់ចំនួន ៦ខែសិន ទើបរាប់រយៈពេលអាជ្ញាយុកាលរបស់ម្ចាស់សិទ្ធិឃាត់ទុកដែលនៅសះសល់បន្ត។ ប៉ុន្តែទោះបីជាអ្នកមានសិទ្ធិដាស់តឿនម្តងទៀតក៏ដោយ ក៏មិនអាចពន្យឺត ការសម្រេចអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល ដោយការដាស់តឿនម្តងទៀតនោះដែរ។[77] ហេតុដូច្នេះ អានុភាពបង្អង់អាជ្ញាយុកាលដោយការដាស់តឿននេះ គឺអាចធ្វើបានតែម្តងតែប៉ុណ្ណោះ ទោះបីជាម្ចាស់បំណុលនោះមានសិទ្ធិដាស់តឿនជាបន្តបន្ទាប់ក៏ដោយ។

ទោះបីជាការទាមទារតាមផ្លូវតុលាការឱ្យបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាល ដោយសារការលើកចោលបណ្តឹង ឬការដកពាក្យបណ្តឹងក៏ដោយ ក៏ត្រូវចាត់ទុកថាអ្នកប្តឹងបានដាស់តឿនជាបន្តចាប់ពីពេលដែលពាក្យបណ្តឹងត្រូវបានបញ្ជូនទៅភាគីម្ខាងទៀត រហូតដល់ពេលដែលបណ្តឹងនោះត្រូវបានលើកចោល ឬពេលដែលពាក្យបណ្តឹងនោះត្រូវបានដកដែរ។ ក្នុងករណីនេះ អាជ្ញាយុកាលនៃការរំលក់សិទ្ធិលើបំណុលនេះមិនត្រូវបានសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីការ លើកចោលបណ្តឹង ឬ ការដកពាក្យបណ្តឹងឡើយ។[78] ក្នុងករណីដែលម្ចាស់សិទ្ធិឃាត់ទុកបានដាក់ពាក្យប្តឹងទាមទារតាមផ្លូវតុលាការ ហើយត្រូវបានតុលាការលើកពាក្យបណ្តឹងចោល ឬម្ចាស់សិទ្ធិឃាត់ទុកដកពាក្យបណ្តឹងខ្លួនវិញ ក៏ត្រូវចាត់ទុកថាម្ចាស់សិទ្ធិឃាត់ទុកបានដាស់តឿតដល់កូនបំណុលផងដែរ។ ដូច្នេះ អានុភាពបង្អង់អាជ្ញាយុកាលតាមរយៈពេល ៦ខែ ដោយការដាស់តឿនក៏ត្រូវយកមកអនុវត្តដូចគ្នា នៅពេលដែលតុលាការលើចោលបណ្តឹង ឬការដកពាក្យបណ្តឹង។

ប្រសិនបើអ្នកមានសិទ្ធិអះអាងសិទ្ធិរបស់ខ្លួន ក្នុងនាមជាចុងចម្លើយក្នុងបណ្តឹងនោះ ត្រូវចាត់ទុកថា អ្នកនោះដាស់តឿនជាបន្ត ក្នុងពេលដែលបណ្តឹងនោះកំពុងចាត់ការ ចាប់ពីពេលដែលអ្នកនោះ អះអាងពីសិទ្ធិរបស់ខ្លួន។ ក្នុងករណីនេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះ មិនត្រូវបានសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីសាលក្រម ឬ សាលដីកានៃបណ្តឹងនោះចូលជាស្ថាពរ ។[79]

---

[76] មាត្រា ៤៩៥ កថាខណ្ឌទី១ វាក្យខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[77] មាត្រាដដែល កថាខណ្ឌទី១ វាក្យខណ្ឌទី២

[78] មាត្រាដដែល កថាខណ្ឌទី២

[79] មាត្រាដដែល កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ឧទាហរណ៍៖ B ជាម្ចាស់សិទ្ធិឃាត់ទុកលើរថយន្តរបស់ A នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៨ ដោយសារតែ A មិនព្រមបង់ថ្លៃជួសជុលរថយន្ត (រថយន្តមានសភាពខូចខាតខ្លាំងបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍ ចំណែកឯថ្លៃជួសជុលវិញអស់ចំណាយច្រើន)។ B បានបន្តឃាត់ទុករថយន្តនោះរហូតមកដល់ថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០២៣ ដោយមិនឃើញ A មកបំពេញកាតព្វកិច្ចបង់ថ្លៃជួសជុល B ក៏បានធ្វើលិខិតដាស់តឿនទៅឱ្យ A ដើម្បីមកបំពេញកាតព្វកិច្ច។

ក្នុងករណីនេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរបស់ B មានរយៈពេល ៥ឆ្នាំ គាត់បានឃាត់ទុករថយន្តរបស់ A ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៨ រហូតមកដល់ថ្ងៃទី ០១ ខែសីហា ឆ្នាំ២០២៣ ពោលគឺនៅសល់រយៈពេលនៃអាជ្ញាយុកាលតែ ៤ខែទៀតតែប៉ុណ្ណោះ។ ជានីតិវិធី B បានជូនដំណឹងតាមរយៈធ្វើលិខិតដាស់តឿនទៅ A ដែលមានអានុភាពបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរយៈពេល ៦ខែ។ ហេតុដូច្នេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែល B នៅសល់គឺ ៦ខែ បូកបន្ថែម ៤ខែ ដែលនៅសល់ក្នុងការអនុវត្តសិទ្ធិដើម្បីទទួលបានសំណង់ពីកូនបំណុល ។

ប្រសិនបើ B មិនបានធ្វើលិខិតដាស់តឿនអ្វីនោះទេ តែ B បានធ្វើបណ្តឹងទៅតុលាការ តែតុលាការមិនបានទទួលបណ្តឹងនេះទេ ពោលគឺតុលាការលើកចោលបណ្តឹង ក៏ត្រូវចាត់ទុកថា B បានដាស់តឿនទៅ A ដែរ បន្ទាប់ពីពាក្យបណ្តឹងនោះបានជូនទៅ A ។ ហេតុដូច្នេះ អានុភាពនៃការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងកើតមានដូចករណីខាងលើ។

### ខ. ការបង្អង់អាជ្ញាយុកាលដោយសារគ្រោះមហន្តរាយធម្មជាតិ

កាលបើអ្នកមានសិទ្ធិ មិនអាចផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដោយសារការជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិ ឬប្រធានសក្តិផ្សេងៗ នៅពេលណាមួយក្នុង ៦ ខែ មុនផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះមិនត្រូវបានសម្រេច ក្នុងអំឡុងពេលពេល ៦ខែ បន្ទាប់ពីប្រធានសក្តិនោះ បានកន្លងផុតទៅ។[80] ក្នុងករណី ដែលអាជ្ញាយុកាលរបស់ម្ចាស់សិទ្ធិឃាត់ទុកនៅសល់តែ ៦ខែចុងក្រោយ ហើយមិនទាន់បានអនុវត្តសិទ្ធិ ប៉ុន្តែក៏កើតមានគ្រោះមហន្តរាយធម្មជាតិទៅវិញ។ ដូច្នេះ អាជ្ញាយុកាលរបស់ម្ចាស់សិទ្ធិឃាត់ទុកត្រូវបង្អង់រយៈពេល ៦ខែសិន រួចទើបរាប់គិតរយៈពេលអាជ្ញាយុកាលដែលនៅសេះសល់បន្តទៀត។

ឧទាហរណ៍៖ B ជាម្ចាស់សិទ្ធិឃាត់ទុលលើម៉ូតូរបស់ A នៅថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៥ ដោយសារតែ A មិនព្រមបង់ថ្លៃជួសជុល។ B ក៏បានឃាត់ទុកម៉ូតូនោះរហូតមកស្រាប់តែនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០

[80] មាត្រា ៤៩៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

មានគ្រោះទឹកជំនន់កើតឡើងនៅទីតាំងដែល B បានឃាត់ទុកម៉ូតូនោះ ហើយត្រូវបានបញ្ចប់ទទៅវិញនៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០២០។

ក្នុងករណីនេះ B បានឃាត់ទុកម៉ូតូរបស់ A អស់ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៥ រហូតមកដល់ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០២០ ពោលគឺរយៈពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនៅសល់តែ ៣ខែទៀតតែប៉ុណ្ណោះ ដោយថៃដន្យមានគ្រោះទឹកជំនន់បានកើតឡើងដែលបង្កើតអានុភាពនៃការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក្រោយពីគ្រោះទឹកជំនន់នោះត្រូវបានចប់។ ហេតុដូច្នេះហើយ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែល B នៅសល់គឺ ៦ខែក្រោយពីគ្រោះទឹកជំនន់ត្រូវបានបញ្ចប់ បូកនឹងរយៈពេលអាជ្ញាយុកាលដែលនៅសះសល់។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

គ្រប់វិធានច្បាប់ទាំងអស់សុទ្ធសឹងតែមានគោលដៅតែមួយគឺ ដើម្បីរក្សានូវសន្តិភាព និងសណ្តាប់ធ្នាប់នៅក្នុងសង្គម ពោលគឺទាមទារឱ្យយើងទាំងអស់គ្នាយល់ដឹងពីច្បាប់ឱ្យបានច្រើនដើម្បីយកទៅប្រតិបត្តនៅក្នុងសង្គម។ ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទ "សិទ្ធិឃាត់ទុក" ដែលបានបកស្រាយ និងពន្យល់ខាងលើនេះ គឺក្នុងគោលបំណងឱ្យអ្នកអានបានស្វែងយល់បន្ថែមទាក់ទងទៅនឹងការឃាត់ទុកវត្ថុរបស់អ្នកដទៃ ដើម្បីកុំឱ្យមានការបំពាន់សិទ្ធិ និងផលប្រយោជន៍របស់អ្នកដទៃដែលអាចបណ្តាលឱ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរឡើង។ ជាការពិតណាស់ ការបង្ហាញខាងលើនេះនៅមានចន្លោះខ្វះខាត និងមិនបានល្អឥតខ្ចោះនោះទេ ដោយសារតែនៅក្នុងទិដ្ឋភាពជាក់ស្តែងក្នុងសង្គមយើង ករណីដែលអាចកើតមានជាសិទ្ធិឃាត់ទុក គឺមានតិចទួចណាស់ និងម៉្យាងទៀតការអនុវត្តតាមទ្រឹស្តីនៃវិធានខ្លះគឺនៅមានកម្រិត នេះគឺជាចំណុចខ្សោយមួយនៃការសិក្សាស្រាវជ្រាវលើប្រធានបទនេះ។ ទោះបីជាយ៉ាងណាក្តី សមិទ្ធផលមួយដែលបានមកពីការខិតខំប្រឹងប្រែង ព្យាយាមអស់ពីកម្លាំងកាយចិត្ត ក្នុងការសិក្សាស្រាវជ្រាវស្វែងយល់ ហើយបានចងក្រងស្នាដៃមួយនេះឡើង ក៏នៅតែមានតម្លៃយ៉ាងវិសេសវិសាលសម្រាប់យើងខ្ញុំជានិច្ច ពិសេសក្នុងការស្វែងយល់នូវវិធានដែលជាទស្សនគតិយុត្តដែលបានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ នៃព្រះរាជាណាចក្រកម្ពុជាដែល កំពុងមានជាធរមាន។

បើយើងនិយាយពាក្យថា សិទ្ធិឃាត់ទុកតែមួយមាត់ ច្បាស់ណាស់ប្រាកដជាមានមនុស្សមួយចំនួនតូចមានការភាន់ច្រឡំទៅនឹងការហាមឃាត់ ការដកហូតវត្ថុ និងការឃាត់ខ្លួនជាដើម ដែលយើងតែងតែឃើញមាននៅក្នុងសង្គមជាក់ស្តែង។ ផ្ទុយទៅវិញក្រោយពីបានសិក្សាស្វែងយល់ពីប្រធានបទនេះរួច យើងអាចយល់យ៉ាងជាក់ច្បាស់ថា សិទ្ធិឃាត់ទុកដែលយើងខ្ញុំលើកយកមកបង្ហាញខាងលើមានលក្ខណៈខុសគ្នាជាមួយនឹងការហាមឃាត់ ការដក់ហូត និងការឃាត់ខ្លួនដែលកើតចេញពីអំណាចសាលក្រម ឬដីកាតុលាការ រួមមាន ដីការក្សាការពារដែលមានអានុភាពអាចហាមឃាត់មិនឱ្យធ្វើលទ្ធកម្មកម្មសិទ្ធិបាន ព្រមទាំងការឃាត់ទុកវត្ថុផ្សេងៗដែលកើតចេញពីអំពើអនីត្យានុកូល និងការប្រមូលវត្ថុតាងដើម្បីសិក្សាសំណុំរឿងដែលមានអានុភាពអាចដកហូត ឬឃាត់ទុកវត្ថុតាងបណ្តោះអាសន្ន ឬការដកហូតវត្ថុនានាដែលច្បាប់ហាមឃាត់។ ចំណែកឯសិទ្ធិឃាត់ទុកដែលជាប្រធានបទរបស់យើងខ្ញុំវិញ គឺជាសិទ្ធិមួយប្រភេទក្នុងការធានាកាតព្វកិច្ចចំពោះម្ចាស់បំណុល ហើយវាជាសិទ្ធិក្នុងការឃាត់ទុកវត្ថុរបស់កូនបំណុលដែលមិនបានបំពេញកាតព្វកិច្ចសងបំណុលតាមពេលកំណត់ ពោលគឺម្ចាស់សិទ្ធិឃាត់ទុកអាចឃាត់ទុកវត្ថុនោះ ទុករហូតដល់កូនបំណុល ឬតតិយជនបានបំពេញកាតព្វកិច្ចសង។ ប៉ុន្តែម្ចាស់សិទ្ធិលើបំណុលមិនមែនចេះតែឃាត់ទុកវត្ថុរបស់កូនបំណុលតាមតែចិត្តរបស់គាត់នោះទេ គឺត្រូវបំពេញគ្រប់លក្ខខណ្ឌនៃសិទ្ធិឃាត់ទុកទើបអាចឃាត់វត្ថុនោះបាន។ លក្ខខណ្ឌដែលអាចកើតមានសិទ្ធិឃាត់ទុកបាន រួម

មាន ការកើតមានសិទ្ធិលើបំណុលនៅពេលកំណត់សងតែកូនបំណុលមិនបានសង ការកាន់កាប់ដោយចំពោះ ឬដោយប្រយោលនូវវត្ថុឃាត់ទុក រីឯវត្ថុឃាត់ទុកនោះត្រូវតែជារបស់អ្នកដទៃ ហើយវត្ថុឃាត់ទុក និងសិទ្ធិលើបំណុលត្រូវមានទំនាក់ទំនងនឹងគ្នា។ នៅពេលម្ចាស់សិទ្ធិឃាត់ទុកបានឃាត់ទុកវត្ថុរបស់កូនបំណុលរួច មិនមែនមានន័យថា ម្ចាស់សិទ្ធិឃាត់ទុកអាចទុកវត្ថុនោះចោលបានទេ គាត់ត្រូវមានកាតព្វកិច្ចថែរក្សាវត្ថុនោះឱ្យបានល្អ និងមិនត្រូវធ្វើឱ្យខូចខាតវត្ថុនោះឡើយ។ ម្យ៉ាងវិញទៀត ម្ចាស់សិទ្ធិឃាត់ទុកមិនអាចយកវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុកទៅប្រើប្រាស់ដោយចិត្តឯងទេ ប្រសិនបើគាត់ចង់ប្រើវត្ថុនោះ គាត់ត្រូវតែទទួលបានការអនុញ្ញាតពីកូនបំណុលទើបអាចប្រើប្រាស់បាន។ ក្នុងករណីដែលម្ចាស់សិទ្ធិឃាត់ទុកបានធ្វើឱ្យខូចខាតវត្ថុឃាត់ទុក ឬយកទៅប្រើប្រាស់ ជួល ឬប្រាតិភោគវត្ថុឃាត់ទុកនោះដោយគ្មានការយលព្រមពីកូនបំណុល បានន័យថាម្ចាស់សិទ្ធិឃាត់ទុកកំពុងតែបំពាន់សិទ្ធិកូនបំណុលខ្លួន នាំឱ្យកូនបំណុលអាចទាមទារឱ្យម្ចាស់សិទ្ធិប្រគល់វត្ថុមកវិញបាន។ មួយវិញទៀត ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកយល់ឃើញថា កូនបំណុលមានចេតនាមិនព្រមសង ឬគ្មានលទ្ធភាពនឹងសងឱ្យទាន់ពេលវេលា ឬវត្ថុឃាត់ទុកនោះមានការលំបាកក្នុងការថែរក្សា នោះម្ចាស់សិទ្ធិឃាត់ទុកអាចអនុវត្តដោយបង្ខំបាន ដោយយកវត្ថុនោះប្តូរជាប្រាក់ដើម្បីកាត់សិទ្ធិលើបំណុលដែលកូនបំណុលជំពាក់ ឯប្រាក់នៅសល់ទើបប្រគល់ជូនកូនបំណុលវិញ។ សិទ្ធិឃាត់ទុកនឹងត្រូវបានបង្កើតឡើងតាមលក្ខខណ្ឌដូចមានរៀបរាប់ខាងលើ ប៉ុន្តែនៅក្នុងអំឡុងពេលអនុវត្តសិទ្ធិ ក៏អាចមានករណីជាច្រើនដែលធ្វើឱ្យសិទ្ធិឃាត់ទុកត្រូវបានរំលត់។ មូលហេតុដែលធ្វើឱ្យសិទ្ធិឃាត់ទុកត្រូវបានរំលត់រួមមាន ការបាត់បង់ការកាន់កាប់លើវត្ថុ ការទូទាត់បំណុល ការទទួលប្រាតិភោគសមរម្យពីសំណាក់កូនបំណុល ការអនុវត្តដោយបង្ខំដោយសិទ្ធិឃាត់ទុក និងការរំលត់សិទ្ធិឃាត់ទុកតាមរយៈការផុតអាជ្ញាយុកាលនៃសិទ្ធិលើបំណុល និងការរំលត់ផ្សេងៗទៀត។

ជាលទ្ធផលក្រោយពីបានសិក្សាស្រាវជ្រាវនូវប្រធានបទ សិទ្ធិឃាត់ទុកនេះរួចមក យើងពិតជាទទួលបានចំណេះដឹងជាច្រើនដែលកើតចេញពីការបកស្រាយ និងពន្យល់ខាងលើ ដូចជានិយមន័យនៃសិទ្ធិឃាត់ទុក ទំនាក់ទំនងរវាងសិទ្ធិឃាត់ទុក និងសិទ្ធិលើបំណុល ការកើតមានអានុភាពនៃសិទ្ធិឃាត់ទុក ការធ្វើលទ្ធកម្មនូវកម្មសិទ្ធិតាមយៈសិទ្ធិឃាត់ទុក ការបន្តអានុភាពនៃសិទ្ធិឃាត់ទុក និងការរំលត់នៃសិទ្ធិឃាត់ទុកជាដើម។ ទន្ទឹមនឹងនេះ យើងសង្កេតឃើញថាមានបញ្ហាដែលជាផលវិបាកមួយកើតមានឡើងនៅពេលអនុវត្តសិទ្ធិឃាត់ទុក។ ដោយផ្អែកតាមសិទ្ធិឃាត់ទុក គឺម្ចាស់សិទ្ធិឃាត់ទុកអាចអនុវត្តដោយបង្ខំលើវត្ថុឃាត់ទុកបាន ក៏ប៉ុន្តែវត្ថុឃាត់ទុកនោះមិនមែនជាកម្មសិទ្ធិរបស់កូនបំណុលទៅវិញ ហើយបើអនុឡោមតាមបញ្ញត្តិស្តីពី សិទ្ធិទាមទារអោយប្រគល់វត្ថុវិញដោយផ្អែកលើកម្មសិទ្ធិ យើងឃើញថា តតិយជន (កម្មសិទ្ធិករ) អាចទាមទារអោយរំលត់សិទ្ធិឃាត់ទុកដើម្បីបញ្ឈប់ការអនុវត្តដោយបង្ខំបាន។ ក្នុងករណីនេះ ម្ចាស់សិទ្ធិឃាត់ទុកមិនគួរអនុវត្តដោយបង្ខំលើវត្ថុនេះឡើយ ព្រោះថា បើម្ចាស់សិទ្ធិឃាត់ទុកបានអនុវត្តដោយបង្ខំលើវត្ថុរបស់តតិយជនដែលមិនមែនជាកូនបំណុលខ្លួន គឺវា

ផ្ទុយពីបញ្ញត្តិស្តីពីសិទ្ធិកម្មសិទ្ធិ ពោលគឺម្ចាស់សិទ្ធិឃាត់ទុកនឹងត្រូវខាតបង់ផលប្រយោជន៍ និងអាចនាំឱ្យសិទ្ធិឃាត់ទុកត្រូវបានរំលត់ថែមទៀតផង។ ជាដំណោះស្រាយ ម្ចាស់សិទ្ធិឃាត់ទុកគួរគប្បីបន្តឃាត់ទុកវត្ថុនោះដើម្បីដាក់សម្ពាធដល់កូនបំណុល ឬកម្មសិទ្ធិករតទៅទៀត ដោយធ្វើការជូនដំណឹងដល់កូនបំណុល និងកម្មសិទ្ធិករនៃវត្ថុក្នុងការគិតថ្លៃឈ្នួលរក្សាវត្ថុប្រចាំថ្ងៃ និងគិតការប្រាក់ចំពោះបំណុល ក្នុងគោលបំណងធ្វើយ៉ាងណាឱ្យកូនបំណុល និងកម្មសិទ្ធិករមកបំពេញកាតព្វកិច្ចសងដើម្បីយកវត្ថុឃាត់ទុកទៅវិញ។ ប្រសិនបើកូនបំណុល ឬកម្មសិទ្ធិករនៅតែមិនព្រមឆ្លើយតបនឹងសេចក្តីជូនដំណឹងរបស់ម្ចាស់សិទ្ធិឃាត់ទុក ហើយនៅតែមិនយកចិត្តទុកដាក់ចំពោះរឿងនេះទេក៏ម្ចាស់សិទ្ធិឃាត់ទុកនៅតែមិនអាចអនុវត្តសិទ្ធិលក់ដោយបង្ខំបានដដែរ។ ក្នុងករណីនេះ បើម្ចាស់សិទ្ធិឃាត់ទុកបន្តកាន់កាប់វត្ថុឃាត់ទុកនោះរហូតដល់ការកំណត់អាជ្ញាយុកាលនៃការធ្វើលទ្ធកម្មនូវកម្មសិទ្ធិ នោះច្បាប់នឹងទទួលស្គាល់ម្ចាស់សិទ្ធិឃាត់ទុកជាម្ចាស់កម្មសិទ្ធិករថ្មីចំពោះវត្ថុឃាត់ទុកនោះតែម្តង។ ហេតុដូច្នេះ ការធ្វើបែបនេះ គឺជាវិធីសាស្ត្រដ៏ល្អបំផុតដើម្បីការពារផលប្រយោជន៍ម្ចាស់សិទ្ធិឃាត់ទុកមិនឱ្យសិទ្ធិនោះត្រូវរំលត់ ហើយក៏មិនឱ្យបាត់បង់វត្ថុផងដែរ។

ទោះបីជាយ៉ាងណាក៏ដោយ គ្មានអ្វីល្អឥតខ្ចោះនោះទេ ដូចគ្នានឹងច្បាប់នីមួយៗផងដែរ គឺតែងតែមានចន្លោះខ្វះខាត ដែលនាំឱ្យមានភាពស្មុគស្មាញដល់តុលាការក្នុងការដោះស្រាយរឿងក្តី ក៏ជាហេតុដែលនាំឱ្យច្បាប់តែងតែមានការធ្វើវិសោធនកម្មដើម្បីកែសម្រួល និងបន្ថែមច្បាប់ដែលមានកង្វះខ្វះខាតទាំងនោះ។ ម៉្យាងវិញទៀតភាពខ្វះខាតធនធានមនុស្សក្នុងវិស័យច្បាប់ក៏ជាមូលហេតុក្នុងការរាំងស្ទះដល់ការអភិវឌ្ឍន៍វិស័យច្បាប់នៅក្នុងប្រទេសកម្ពុជាយើងផងដែរ។

ក្នុងនាមយើងជាសិស្ស និស្សិត ក៏ដូចជាប្រជាពលរដ្ឋ គួរមានការយល់ដឹងអំពីច្បាប់ និងគប្បីសិក្សាយល់ដឹងនូវបញ្ញត្តិច្បាប់ឱ្យបានច្រើន ដែលអាចការពារផលប្រយោជន៍ខ្លួន សាច់ញាតិ ក្រុមគ្រួសារ និងអ្នកដទៃ ក៏ដូចជាសង្គមឱ្យជៀសផុតពីភាពវឹកវរ ដែលកើតពីសកម្មភាពផ្ទុយនឹងច្បាប់ ថែមទាំងអាចចូលរួមចំណែកក្នុងការជួយអភិវឌ្ឍន៍ប្រទេសជាតិឱ្យកាន់តែរុងរឿង សុខសន្តិភាព និងភាពរីកចម្រើនតទៅមុខទៀត។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងធ្វើការបកស្រាយយ៉ាងក្បុះក្បាយខាងលើរួចមក ទាក់ទងនឹងសិទ្ធិឃាត់ទុក ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា យើងសង្កេតឃើញថា ដើម្បីឱ្យការប្រព្រឹត្តទៅនៃសិទ្ធិឃាត់ទុកមានដំណើរការប្រកបដោយសុពលភាព និងសុវត្ថិភាព ហើយដើម្បីជៀសវាងការភាន់ច្រឡំថា ឱ្យតែមានសកម្មភាពឃាត់ទុក គឺសុទ្ធសឹងតែជាសិទ្ធិឃាត់ទុក និងជៀសវៀងការអនុវត្តសិទ្ធិឃាត់ទុលមិនបានត្រឹមត្រូវ បណ្តាលឱ្យកើតជាវិវាទផ្សេងៗ យើងខ្ញុំសូមគាំទ្រឱ្យរាជរដ្ឋាភិបាល និងស្ថាប័នពាក់ពាន់នានា ខិតខំបន្ថែមទៀត ដើម្បីផ្សព្វផ្សាយចំណេះដឹងផ្នែកច្បាប់ដល់ប្រជាពលរដ្ឋ ដូចជា ការបង្កើតសិក្ខាសាលាដែលទាក់ទងនឹងប្រធានបទសិទ្ធិឃាត់ទុក និងបើកឱកាសឱ្យសាធារណជនចូលរួមស្តាប់ និងសិក្សាដោយសេរី។ លើសពីនេះទៅទៀត យើងខ្ញុំក៏សូមគាំទ្រចំពោះការបង្កើតកម្មវិធីផ្សព្វផ្សាយច្បាប់ តាមរយៈទូរទស្សន៍ វិទ្យុ កាសែត និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតដើម្បីបកស្រាយនូវចម្ងល់ដែលសាធារណជនចង់ដឹង ក៏ដូចជាជួយដោះស្រាយចំណោទបញ្ហារបស់ប្រជាពលរដ្ឋផងដែរ។ បន្ថែមពីនេះទៅទៀត ប្រសិនបើមានកម្មវិធីបណ្តុះបណ្តាលដោយមន្ត្រីដែលមានជំនាញឱ្យទៅបង្រៀនដល់មូលដ្ឋានដាច់ស្រយាលដែលពួកគេទាំងនោះមានការយលដឹងផ្នែកច្បាប់នៅមានកម្រិត និងដើម្បីជាជំនួយដល់ប្រជាជនដែលមិនមានឱកាសក្នុងការរៀនសូត្រឱ្យពួកគេបានយល់ដឹងបន្ថែមពីច្បាប់កាន់តែប្រសើរ។

ចំពោះប្រជាពលរដ្ឋវិញ គួរគប្បីយកចិត្តទុកដាក់សិក្សាស្វែងយល់ ផ្នែកច្បាប់បន្ថែមឱ្យបានកាន់តែច្រើនសម្រាប់ជាប្រយោជន៍ដល់ខ្លួន និងចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិផង។ យ៉ាងណាមិញ ម្ចាស់សិទ្ធិឃាត់ទុក ត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ដើម្បីជាស់វាងការបំពានដោយប្រការណាមួយដែលនាំឱ្យសិទ្ធិរបស់ខ្លួនត្រូវរំលត់ លើសពីនេះទៅទៀតមិនត្រូវបណ្តែតបណ្តោយឱ្យផុតអាជ្ញាយុការនៃការរំលត់សិទ្ធិលើបំណុលនោះទេ បើមិនដូច្នេះទេ ម្ចាស់សិទ្ធិឃាត់ទុកនឹងក្លាយជាអ្នកដែលខាត់បង់ផលប្រយោជន៍ជាមិនខាន។

ម៉្យាងវិញទៀត បើប្រជាពលរដ្ឋមិនសូវយល់ដឹងផ្នែកច្បាប់ទេ គួរណាតែទៅពីគ្រោះប្រឹក្សាយោបល់ ជាមួយអ្នកច្បាប់ដើម្បីឱ្យគេជួយរកដំណោះស្រាយដែលស្របនឹងគោលការច្បាប់ដែលបានកំណតជាធរមាន។ កាលបើរឿងក្តីឈានដល់ដំណាក់កាលតុលាការហើយ ម្ចាស់បំណុល និងកូនបំណុលគួរណាតែស្វះស្វែងរកមេធាវីមកតំណាងអាណត្តិឱ្យខ្លួន ដើម្បីធ្វើយ៉ាងណាធានាឱ្យបាននូវផលប្រយោជន៍ ព្រមទាំងជៀសវាង និងបង្ការកុំឱ្យកើតមានកំហុសដោយប្រការណាមួយដែលអាចនាំឱ្យខាត់បង់ផលប្រយោជន៍កាន់តែធ្ងនធ្ងរដល់ភាគីទាំងសងខាង។

# ឯកសារយោង

# ឯកសារយោង


១.ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

២.ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

៣.សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៤ : គន្លឹទី៦

៤.សៀវភៅកម្រងមេរៀន រៀបរាងដោយកម្មវិធីវិភាគទានច្បាប់ ធ្វើនៅឆ្នាំ ២០១៨

៥.សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី រៀបចំដោយគណៈកម្មបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ បោះពុម្ពដោយទិស្តីការគណៈរដ្ឋមន្រ្តី ឆ្នាំ២០០៧

៦.សៀវភៅ វចនានុក្រមច្បាប់ និពន្ធដោយលោក ហ៊ីង ធីឫទ្ធិ បោះពុម្ពលើកទី៣ ឆ្នាំ២០១០

៧.វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត

៨.គេហទំព័ររបស់ ក្រុមហ៊ុនមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ : https://ciclg.com/kh/article/256

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១៖
  - ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧
- ឧបសម្ព័ន្ធទី២៖
  - ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
- ឧបសម្ព័ន្ធទី៣៖
  - កិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំ
  - កិច្ចសន្យាម៉ៅការ
  - កិច្ចសន្យាជួលផ្ទះ
- ឧបសម្ព័ន្ធទី៤៖
  - លិខិតប្រគល់ និងទទួលប្រាក់
  - លិខិតសងប្រាក់
  - លិខិតប្រគល់សិទ្ធិ
- ឧបសម្ព័ន្ធទី៥៖
  - ពាក្យបណ្តឹង
  - ពាក្យសុំដកពាក្យបណ្តឹង
  - ពាក្យសុំដីកាសម្រេចរក្សាការពារ
  - ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត
  - ពាក្យសុំអនុវត្តដោយបណ្តោះអាសន្ន

# ឧបសម្ព័ន្ធទី១

## គន្ថីទី ៣
## សិទ្ធិប្រត្យក្ស

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

#### ផ្នែកទី ១
#### វត្ថុ

**មាត្រា ១១៩.–** និយមន័យនៃវត្ថុ

ក្នុងក្រមនេះ វត្ថុសំដៅទៅលើរបស់ដែលមានរូបរាង ជាសារធាតុឧស្ម័ន ជាសារធាតុរាវ ជាសារធាតុរឹង ។

**មាត្រា ១២០.–** ចលនវត្ថុ និង អចលនវត្ថុ

១-វត្ថុត្រូវបានចែកជាចលនវត្ថុ និង អចលនវត្ថុ ។

២-អចលនវត្ថុសំដៅទៅលើ ដីធ្លី និង វត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍ ។

៣-ចលនវត្ថុសំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ ។

៤-បញ្ញត្តិស្តីពីចលនវត្ថុត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទ្រព្យសម្បត្តិគ្មានរូបរាងដែលអាចគ្រប់គ្រងបាន លើកលែងតែមានបញ្ញត្តិក្នុងច្បាប់ពិសេស ។

#### ផ្នែកទី ៣
#### សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ

**មាត្រា ១៥៥.–** សិទ្ធិទាមទារឱ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ

កម្មសិទ្ធិករអាចទាមទារឱ្យអ្នកកាន់កាប់ប្រគល់វត្ថុរបស់ខ្លួនវិញបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកកាន់កាប់នោះមានមូលហេតុគតិយុត្តនៃសិទ្ធិកាន់កាប់ ចំពោះកម្មសិទ្ធិករ ។

**មាត្រា ១៥៧.–** ការទទួលខុសត្រូវចំពោះការបាត់បង់ ឬ ខូចខាតនៃវត្ថុកាន់កាប់

ក្នុងករណីដែលអ្នកកាន់កាប់មានកំហុសចំពោះការបាត់បង់ ឬ ការខូចខាតវត្ថុកាន់កាប់ ឬ ការមិនអាចប្រគល់វត្ថុនោះវិញបាន អ្នកកាន់កាប់ទុច្ចរិត នៅពេលដែលការបាត់បង់ ការខូចខាតដល់វត្ថុ ឬ ហេតុផ្សេងដែលមិនអាចប្រគល់វត្ថុនោះវិញបាននោះ បានកើតឡើង មានករណីយកិច្ចសងសំណងការខូចខាតទាំងអស់នោះ រីឯអ្នកកាន់កាប់សុចរិតមានករណីយកិច្ចសងសំណងការខូចខាត ត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលខ្លួននៅតែទទួលប៉ុណ្ណោះ ។ ប៉ុន្តែ អ្នកកាន់កាប់ដែលគ្មានឆន្ទៈយកជាកម្មសិទ្ធិ ទោះបីជាក្នុងករណីកាន់កាប់ដោយសុចរិតក៏ដោយ ក៏មានករណីយកិច្ចសងនូវការខូចខាតទាំងអស់ដែរ ។

**មាត្រា ១៥៨.–** សិទ្ធិទាមទារឱ្យបញ្ឈប់ និង បង្ការការរារាំង ដោយផ្អែកលើកម្មសិទ្ធិ

១-ក្នុងករណីដែលការអនុវត្តកម្មសិទ្ធិរបស់ខ្លួនត្រូវបានរារាំង កម្មសិទ្ធិករអាចទាមទារឱ្យបញ្ឈប់ការរារាំង ចំពោះអ្នករារាំងនោះបាន ។

២-ក្នុងករណីដែលមានការបារម្ភជាក់ស្តែងថា ការអនុវត្តកម្មសិទ្ធិរបស់ខ្លួននឹងទទួលការរារាំង នោះកម្មសិទ្ធិករអាចទាមទារឱ្យបង្ការការរារាំងនោះបាន ចំពោះអ្នកដែលអាចនឹងរារាំងនោះ ។

## កថាភាគទី ២

## លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ

**មាត្រា ១៦៣.–** លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ

អ្នកដែលបានទទួលការផ្ទេរការកាន់កាប់នូវចលនវត្ថុ ដោយកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាព ហើយដោយសុចរិត និង គ្មានកំហុស ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះ ទោះបីជាអនុប្បទាយីគ្មានកម្មសិទ្ធិលើចលនវត្ថុនោះក៏ដោយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអនុប្បទាយីនៅតែបន្តការកាន់កាប់ដោយចំពោះ ។

**មាត្រា ១៦៥.–** អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ

១-ជនដែលបានកាន់កាប់ចលនវត្ថុ ដោយសន្តិវិធី និង ពឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ១០ (ដប់) ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើចលនវត្ថុនោះ ។

២-ជនដែលបានកាន់កាប់ចលនវត្ថុ ដោយសន្តិវិធី និង ពឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើចលនវត្ថុនោះ បើជននោះសុចរិត និង គ្មានកំហុស នៅពេលដែលខ្លួនបានចាប់ផ្តើមកាន់កាប់ ។

## ជំពូកទី ៣
## សិទ្ធិកាន់កាប់

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ២២៧.-** និយមន័យនៃការកាន់កាប់

១-ការកាន់កាប់ សំដៅទៅលើការក្តាប់ទុកវត្ថុ ។

២-ការក្តាប់ទុកសំដៅទៅលើការគ្រប់គ្រងលើវត្ថុ តាមការជាក់ស្តែង ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ។

## ជំពូកទី ៧
## ការរលត់កាតព្វកិច្ច

**មាត្រា ៤៣៣.-** មូលហេតុនៃការរលត់កាតព្វកិច្ច

កាតព្វកិច្ចត្រូវរលត់ដោយហេតុដូចខាងក្រោមនេះ :

ក-ការសង ការទូទាត់ ការលើកលែង នវកម្ម ឬ ល្បាកុលភាព ដូចបានកំណត់ពីផ្នែកទី ១ (ការសង) ដល់ផ្នែកទី ៥ (ល្បាកុលភាព) នៃជំពូកទី ៧ នេះ ។

ខ-អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដោយគ្មានកំហុសរបស់កូនបំណុល ដូចបានកំណត់ក្នុងជំពូកទី ៥ (ការទទួលបន្ទុកហានិភ័យ) នៃគន្ថីនេះ ។

គ-ការបំពេញល័ក្ខខ័ណ្ឌនៃការរំលាយដូចបានកំណត់ក្នុងផ្នែកទី ៣ (ល័ក្ខខ័ណ្ឌ កំណត់ពេល និង អំឡុងពេល) នៃជំពូកទី ១ ឬ ការរំលាយកិច្ចសន្យាដូចបានកំណត់ក្នុងផ្នែកទី ៤ (ការរំលាយកិច្ចសន្យា) នៃជំពូកទី ៤ នៃគន្ថីនេះ ។

ឃ-ការផុតអាជ្ញាយុកាលនៃការរលត់ដូចបានកំណត់ក្នុងជំពូកទី ៨ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល) នៃគន្ថីនេះ ។

ង-ការអនុវត្តសិទ្ធិលុបចោលតាមបញ្ញត្តិនៃផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ជំពូកទី ២ នៃគន្ថីនេះ។

# ផ្នែកទី ១
# ការសង

## កថាភាគទី ១
## គោលការណ៍ទូទៅស្ដីពីការសង

**មាត្រា ៤៣៤.–** អ្នកសង

១-ការសងអាចធ្វើឡើងដោយកូនបំណុលក៏បាន ដោយតតិយជនក៏បាន ។

២-ក្នុងករណីដែលគោលបំណងនៃកាតព្វកិច្ចមិនអាចសម្រេចដោយការសងរបស់តតិយជនបានទេ តតិយជននោះមិនអាចសងបានឡើយ លើកលែងតែមានការយល់ព្រមពីម្ចាស់បំណុល ។

៣-ម្ចាស់បំណុល និង កូនបំណុលអាចព្រមព្រៀងគ្នាមិនទទួលស្គាល់ការសងដោយតតិយជនបាន ។

**មាត្រា ៤៣៥.–** សមត្ថភាពចាត់ចែងរបស់អ្នកសង ជាអាទិ៍

១-ប្រសិនបើអ្នកសងមិនមែនជាម្ចាស់កម្មសិទ្ធិ ឬ មិនមានសមត្ថភាពចាត់ចែងចំពោះវត្ថុដែលជាកម្មវត្ថុនៃការសងទេ ការសងរបស់អ្នកសងនោះមិនមានសុពលភាពឡើយ ។

២-ក្នុងករណីដែលអ្នកសងមិនមែនជាម្ចាស់កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការសងទេ អ្នកសងនោះមិនអាចយកវត្ថុនោះមកវិញបានឡើយ លើកលែងតែមានការសងម្ដងទៀតដែលមានសុពលភាព ។ ប៉ុន្តែ អ្នកដែលមានកម្មសិទ្ធិលើវត្ថុនោះ អាចយកវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនពីអ្នកទទួលការសងមកវិញបាន ។

៣-ក្នុងករណីដែលអ្នកសងគ្មានសមត្ថភាពចាត់ចែងកម្មវត្ថុនៃការសងទេ អ្នកសងនោះអាចលុបចោលនូវអំពើសងដែលខ្លួនបានធ្វើ ។ ក្នុងករណីនេះ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការប្រគល់កម្មវត្ថុនៃការសងវិញ ។

**មាត្រា ៤៣៦.–** ការប្រើប្រាស់ ឬ អនុប្បទានរបស់ម្ចាស់បំណុល និង ការទទួលដោយសុចរិត

១-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៤៣៥ (សមត្ថភាពចាត់ចែងរបស់អ្នកសង ជាអាទិ៍) ខាងលើនេះ បើកម្មវត្ថុនៃការសងជាចលនវត្ថុ ហើយម្ចាស់បំណុលបានបរិភោគ ឬ ធ្វើអនុប្បទានដោយសុចរិត នូវវត្ថុដែលបានទទួលពីការសង ការសងនោះត្រូវចាត់ទុកថាមានសុពលភាព ហើយអ្នកសងមិនអាចទាមទារឱ្យប្រគល់កម្មវត្ថុនៃការសងនោះ មកវិញបានទេ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលមានកម្មសិទ្ធិលើកម្មវត្ថុនៃការសង អាចទាមទារនូវសំណងនៃការខូចខាតចំពោះកម្មវត្ថុនៃការសងនោះពីអ្នកទទួលការសងបាន លើកលែងតែអ្នកទទួលការសងនោះបានទទួលកម្មសិទ្ធិលើវត្ថុនៃការសង ដោយស្របទៅតាមបញ្ញត្តិនៃមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ។ ប៉ុន្តែ ម្ចាស់បំណុលដែលបានសងការខូចខាតទៅម្ចាស់កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការសងនោះ អាចទាមទារឱ្យកូនបំណុលសងជាប្រាក់នូវតម្លៃដែលខ្លួនបានសងនោះវិញបាន ។

**មាត្រា ៤៣៧.-** សិទ្ធិទទួលការសង

១-ការសងនឹងមានសុពលភាព លុះត្រាតែធ្វើចំពោះម្ចាស់បំណុល ឬ អ្នកដទៃទៀតដែលមានសិទ្ធិទទួលការសង ។

២-បើកូនបំណុលបានសងដល់អ្នកដែលគ្មានសិទ្ធិទទួលការសង កូនបំណុលនោះត្រូវសងទៅម្ចាស់បំណុលជាថ្មីម្តងទៀត តាមការទាមទារពីម្ចាស់បំណុលនោះ ។ ក្នុងករណីនេះ អ្នកសងអាចទាមទារឱ្យអ្នកគ្មានសិទ្ធិដែលបានទទួលការសងនោះ ប្រគល់កម្មវត្ថុនៃការសងមកវិញបាន ។

**មាត្រា ៤៣៨.-** ការកម្រិតនូវសិទ្ធិទទួលការសងដោយការរឹបអូស

១-ក្នុងករណីដែលសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលត្រូវបានរឹបអូស ដោយដីកាសម្រេចរឹបអូសរបស់តុលាការ ម្ចាស់បំណុលនោះមិនមានសិទ្ធិទទួលការសងពីកូនបំណុលរបស់ខ្លួន ហើយកូនបំណុលនោះមិនអាចសងទៅម្ចាស់បំណុលនោះបានឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤៣៧ (សិទ្ធិទទួលការសង) ខាងលើនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនបំណុលដែលត្រូវបានហាមការសង បានសងទៅម្ចាស់បំណុលរបស់ខ្លួន ។

## ផ្នែកទី ២
## ការទូទាត់

**មាត្រា ៤៧២.-** ការកាត់បំណុលដោយការទូទាត់

ក្នុងករណីដែលភាគីម្ខាង ឬ ទាំងសងខាងមានកាតព្វកិច្ចច្រើនដែលអាចទូទាត់បាន អ្នកសុំទូទាត់អាចជ្រើសរើសកាតព្វកិច្ចណាមួយរបស់ខ្លួន និង កាតព្វកិច្ចណាមួយរបស់ភាគីម្ខាងទៀតដើម្បីរំលត់ដោយការទូទាត់នោះបាន ។ បញ្ញត្តិស្តីពីការកាត់បំណុលដោយការសង ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទូទាត់ដែលគ្មានការជ្រើសរើស ដូចកំណត់ក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះ ។

# ជំពូកទី ៨
# អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

**មាត្រា ៤៨០.–** និយមន័យនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល សំដៅទៅលើការរំលត់សិទ្ធិលើបំណុល ដោយផ្អែកលើការណ៍ដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិ ក្នុងរយៈពេលដែលត្រូវបានកំណត់ ។

**មាត្រា ៤៨១.–** ពេលចាប់ផ្ដើមគិតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលនោះបាន ។

**មាត្រា ៤៨២.–** រយៈពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានរយៈពេល ៥ (ប្រាំ) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬ ច្បាប់ឬបទដ្ឋានគតិយុត្តផ្សេង ។

**មាត្រា ៤៨៣.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិដែលមានរយៈពេលខ្លី

ចំពោះសិទ្ធិលើបំណុលអំពីថ្លៃទំនិញដែលផលិតករ ឬ ពាណិជ្ជករលក់ទៅឱ្យអ្នកដែលមិនមែនជាពាណិជ្ជករ និង ថ្លៃសេវាដែលផលិតករ ឬ ពាណិជ្ជករផ្ដល់ឱ្យអ្នកដែលមិនមែនជាពាណិជ្ជករ អាជ្ញាយុកាលនៃការរំលត់សិទ្ធិនេះ មានរយៈពេល ២ (ពីរ) ឆ្នាំ ។

**មាត្រា ៤៨៤.–** រយៈពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលចូលជាស្ថាពរ

១-ចំពោះសិទ្ធិលើបំណុលដែលចូលជាស្ថាពរ ដោយសាលក្រម ឬ សាលដីកាស្ថាពរ ឬ ដោយការផ្សះផ្សាតាមផ្លូវតុលាការ ឬ ដោយវិធីផ្សេងដែលមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ ទោះបីជាមានបញ្ញត្តិដែលកំណត់រយៈពេលនៃអាជ្ញាយុកាលតិចជាង ៥ (ប្រាំ) ឆ្នាំក៏ដោយ ក៏អាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះ ត្រូវមានរយៈពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលសិទ្ធិលើបំណុលនោះចូលស្ថាពរដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលពេលកំណត់ត្រូវអនុវត្តមិនទាន់ដល់ នៅពេលនៃការចូលជាស្ថាពរ ។

**មាត្រា ៤៨៩.-** ហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវផ្អាកក្នុងករណីដូចតទៅ :

ក-ការទាមទារតាមផ្លូវតុលាការ ការចូលរួមក្នុងនីតិវិធីពនស្យ័យ ឬ ការអនុវត្តសិទ្ធិដែលមានលក្ខណៈប្រហាក់ប្រហែល ។

ខ-សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងការរក្សាការពារ ។

គ-ការទទួលស្គាល់កាតព្វកិច្ច ដោយការសងមួយផ្នែក ការបង់ការប្រាក់ ការដាក់ប្រាតិភោគ ឬវិធីផ្សេង ។

**មាត្រា ៤៩០.-** ការទាមទារតាមផ្លូវតុលាការ

ការទាមទារតាមផ្លូវតុលាការមិនត្រូវបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ក្នុងករណីដែលបណ្ដឹងត្រូវបានលើកចោល ឬ ត្រូវបានដកវិញ ។

**មាត្រា ៤៩១.-** ការលុបចោលនូវការចាត់ចែងអនុវត្តដោយបង្ខំ ឬ ការចាត់ចែងរក្សាការពារ

ក្នុងករណីដែលការចាត់ចែងអនុវត្តដោយបង្ខំ ឬ ការរក្សាការពារ ត្រូវបានលុបចោលតាមពាក្យសុំរបស់ភាគី ឬ ដោយការខ្វះល័ក្ខខ័ណ្ឌតាមផ្លូវច្បាប់ ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដោយសកម្មភាពអនុវត្តដោយបង្ខំ ឬ ដោយសកម្មភាពចាត់ចែងការរក្សាការពារនេះ ត្រូវចាត់ទុកថា មិនបានកើតឡើងឡើយ ។

**មាត្រា ៤៩២.-** សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងការរក្សាការពារដែលធ្វើឡើង ចំពោះបុគ្គល ក្រៅពីកូនបំណុល

សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងការរក្សាការពារដែលធ្វើឡើងចំពោះបុគ្គលក្រៅពីកូនបំណុល ត្រូវបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល លុះត្រាតែសកម្មភាពនោះ ត្រូវបានជូនដំណឹងទៅកូនបំណុល ។

**មាត្រា ៤៩៤.–** ដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ក្រោយការផ្អាក

១-អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលត្រូវបានផ្អាក នឹងចាប់ផ្ដើមគិតជាថ្មីម្ដងទៀត ក្រោយពីហេតុនៃការផ្អាកបានចប់ ។

២-អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលត្រូវបានផ្អាកដោយការទាមទារតាមផ្លូវតុលាការ នឹងចាប់ផ្ដើមគិតជាថ្មីម្ដងទៀត បន្ទាប់ពីសេចក្ដីសម្រេចចូលជាស្ថាពរ ។

**មាត្រា ៤៩៥.–** ការបង្អង់ការសម្រេចអាជ្ញាយុកាលដោយការដាស់តឿន និង ដោយការដាស់តឿនតាមផ្លូវតុលាការ

១-ប្រសិនបើអ្នកមានសិទ្ធិបានដាស់តឿន នៅពេលណាមួយក្នុងអំឡុង៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលរំលត់សិទ្ធិលើបំណុលនោះមិនត្រូវបានសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការដាស់តឿនឡើយ ។ ប៉ុន្តែ ទោះបីជាអ្នកមានសិទ្ធិដាស់តឿនម្ដងទៀតក៏ដោយ ក៏មិនអាចពន្យឺតការសម្រេចអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល ដោយការដាស់តឿនម្ដងទៀតនោះដែរ ។

២-ទោះបីជាការទាមទារតាមផ្លូវតុលាការ មិនបង្កើតអានុភាពនៃការផ្អាកអាជ្ញា-យុកាល ដោយសារការលើកចោលបណ្ដឹង ឬ ការដកពាក្យបណ្ដឹងក៏ដោយ ក៏ត្រូវចាត់ទុកថា អ្នកប្ដឹងបានដាស់តឿនជាបន្ត ចាប់ពីពេលដែលពាក្យបណ្ដឹងត្រូវបានបញ្ជូន ទៅភាគីម្ខាងទៀត រហូតដល់ពេលដែលបណ្ដឹងនោះត្រូវបានលើកចោល ឬ ពេលដែលពាក្យបណ្ដឹងនោះត្រូវបានដកដែរ ។ ក្នុងករណីនេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះមិនត្រូវបានសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការលើកចោលបណ្ដឹង ឬ ការដកពាក្យបណ្ដឹងឡើយ ។

៣-ប្រសិនបើអ្នកមានសិទ្ធិបានអះអាងសិទ្ធិរបស់ខ្លួន ក្នុងនាមជាចុងចម្លើយក្នុងបណ្ដឹងនោះ ត្រូវចាត់ទុកថា អ្នកនោះដាស់តឿនជាបន្ត ក្នុងពេលដែលបណ្ដឹងនោះកំពុងចាត់ការ ចាប់ពីពេលដែលអ្នកនោះ អះអាងសិទ្ធិរបស់ខ្លួន ។ ក្នុងករណីនេះ អាជ្ញាយុកាល

**មាត្រា ៤៩៨.–** ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយសារមហន្តរាយធម្មជាតិ

ប្រសិនបើអ្នកមានសិទ្ធិមិនអាចផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដោយសារការជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិ ឬ ប្រធានសក្តិផ្សេង នៅពេលណាមួយក្នុង ៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះមិនត្រូវបានសម្រេច ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីប្រធានសក្តិនោះ បានកន្លងផុតឡើយ ។

## ជំពូកទី ៩
## អនុប្បទានសិទ្ធិលើបំណុល ការទទួលភារៈកាតព្វកិច្ច

### ផ្នែកទី ១
### អនុប្បទានសិទ្ធិលើបំណុល

**មាត្រា ៥០១.–** ភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល និង ការសន្យាពិសេសហាមមិនឱ្យធ្វើអនុប្បទាន

១-សិទ្ធិលើបំណុល អាចធ្វើអនុប្បទានទៅឱ្យអ្នកផ្សេងបាន លើកលែងតែក្នុងករណីដែលសិទ្ធិនោះមានលក្ខណៈមិនអាចធ្វើអនុប្បទានបាន ។ ក្នុងករណីនេះ អនុប្បទានិកនឹងក្លាយជាម្ចាស់បំណុលថ្មី ។

២-ទោះបីជាសិទ្ធិលើបំណុលមានលក្ខណៈអាចធ្វើអនុប្បទានបានក៏ដោយ ក៏គូភាគីអាចហាមមិនឱ្យធ្វើអនុប្បទាន ដោយការបង្ហាញឆន្ទៈបានដែរ ។

៣-ការបង្ហាញឆន្ទៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ មិនអាចតតាំងចំពោះតតិយជនដែលមិនបានដឹងអំពីការបង្ហាញឆន្ទៈនោះបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះមានកំហុសធ្ងន់ធ្ងរ ។

**មាត្រា ៥០២.–** ការបង្កើតអនុប្បទានសិទ្ធិលើបំណុល

អនុប្បទានសិទ្ធិលើបំណុល ត្រូវមានអានុភាព តែដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុលដែលមានបំណងធ្វើអនុប្បទានសិទ្ធិលើបំណុល និង អនុប្បទានិកប៉ុណ្ណោះ ។ ប៉ុន្តែ ដើម្បីយកអនុប្បទានសិទ្ធិលើបំណុលនេះទៅតតាំង ចំពោះកូនបំណុល និង តតិយជន ត្រូវមានល័ក្ខខ័ណ្ឌតតាំងដែលបានកំណត់នៅក្នុងមាត្រា ៥០៣ (ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) ខាងក្រោមនេះ ។

# គន្ថីទី ៦
# ការធានាកាតព្វកិច្ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៧៦៧.-** ប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្ស

១-ប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្សត្រូវកម្រិតតែប្រភេទដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ឬ ច្បាប់ពិសេសតែប៉ុណ្ណោះ ហើយក្រៅពីនេះមិនអាចបង្កើតបានឡើយ ។

២-សិទ្ធិប្រាតិភោគប្រត្យក្សដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនេះ មាន ៥ (ប្រាំ) ប្រភេទ គឺ សិទ្ធិឃាត់ទុក ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក និង សិទ្ធិប្រាតិភោគដោយអនុប្បទាន ។

**មាត្រា ៧៦៨.-** វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្ស

សិទ្ធិប្រាតិភោគប្រត្យក្សមិនអាចយកវត្ថុ ឬ សិទ្ធិណាដែលមិនអាចធ្វើអនុប្បទានបាន មកធ្វើជាកម្មវត្ថុបានទេ ។ ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងការបង្កើតសិទ្ធិឃាត់ទុកលើវត្ថុដែលមិនអាចធ្វើអនុប្បទានបានឡើយ ។

**មាត្រា ៧៦៩.-** ភាពបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគប្រត្យក្ស

១-សិទ្ធិប្រាតិភោគប្រត្យក្ស ត្រូវបានបង្កើតឡើង ដើម្បីធានាកាតព្វកិច្ចដែលមានអត្ថិភាពហើយ ។ ប៉ុន្តែ ទោះបីជាកាតព្វកិច្ចដែលនឹងកើតឡើងនាពេលអនាគតក៏ដោយ ក្នុងករណីដែលអាចកំណត់កាតព្វកិច្ចបាន ក៏សិទ្ធិប្រាតិភោគប្រត្យក្សអាចបង្កើតបានដែរ ដោយយកកាតព្វកិច្ចនោះមកធ្វើជាកាតព្វកិច្ចដែលត្រូវបានធានា ។

២-ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាមិនត្រូវបានបង្កើតឡើង ដោយសារខ្វះល័ក្ខខ័ណ្ឌ សិទ្ធិប្រាតិភោគប្រត្យក្សក៏មិនត្រូវបានបង្កើតឡើងដែរ ។

៣-ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវបានចាត់ទុកជាមោឃៈ ដោយសារមានវិការៈក្នុងការបង្ហាញឆន្ទៈ ឬ ដោយសារហេតុផ្សេងទៀត ឬ ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវបានលុបចោល សិទ្ធិប្រាតិភោគប្រត្យក្សក៏មិនត្រូវមានអានុភាពឡើយ ។

៤-ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាបានរលត់ ដោយសារការសង ឬ អាជ្ញាយុកាលនៃការរំលត់សិទ្ធិ ឬ ហេតុផ្សេងទៀត សិទ្ធិប្រាតិភោគប្រត្យក្សក៏ត្រូវរលត់ដែរ ។

៥-បញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ ទី ៣ និង កថាខណ្ឌទី ៤ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលត្រូវបានបង្កើតឡើងដើម្បីធានាសិទ្ធិលើបំណុលច្រើនដែលកើតឡើងដោយកិច្ចសន្យាបន្តបន្ទាប់ ។

**មាត្រា ៧៧៣.–** ការអនុវត្តសិទ្ធិប្រាតិភោគប្រស្យក្ស

ប្រសិនបើម្ចាស់សិទ្ធិប្រាតិភោគមិនបានទទួលសំណងនៃសិទ្ធិលើបំណុលទេ អ្នកនោះអាចអនុវត្តសិទ្ធិប្រាតិភោគប្រស្យក្សនេះ តាមនីតិវិធីដែលច្បាប់បានកំណត់ បាន ។

## ជំពូកទី ២
## សិទ្ធិឃាត់ទុក

**មាត្រា ៧៧៤.–** អត្ថន័យនៃសិទ្ធិឃាត់ទុក

១-ប្រសិនបើអ្នកកាន់កាប់វត្ថុរបស់អ្នកដទៃ មានសិទ្ធិលើបំណុលដែលបានកើតឡើង ដោយទាក់ទងនឹងវត្ថុនោះ អ្នកនោះអាចឃាត់ទុកនូវវត្ថុនោះបាន រហូតដល់ពេលដែលខ្លួនទទួលការសងចំពោះសិទ្ធិលើបំណុលនោះ ។ ប៉ុន្តែ សិទ្ធិឃាត់ទុកមិនត្រូវកើតមានឡើយ ប្រសិនបើសិទ្ធិលើបំណុលនោះមិនទាន់ដល់ពេលកំណត់ត្រូវសង ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការកាន់កាប់ត្រូវបានចាប់ផ្ដើម ដោយអំពើអនីត្យានុកូល ។

**មាត្រា ៧៧៥.–** សិទ្ធិទទួលសំណងពីផលដោយមានអាទិភាព

១-ម្ចាស់សិទ្ធិឃាត់ទុក អាចទទួលផលពីវត្ថុដែលឃាត់ទុក និង អាចយកផលនោះមកកាត់សិទ្ធិលើបំណុល ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតបាន ។

២-ផលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ហើយប្រសិនបើមានសំណល់ ត្រូវយកមកកាត់ប្រាក់ដើម ។

**មាត្រា ៧៧៦.–** ករណីយកិច្ចរបស់ម្ចាស់សិទ្ធិឃាត់ទុកក្នុងការរក្សាគ្រប់គ្រងវត្ថុដែលឃាត់ទុក

១-ម្ចាស់សិទ្ធិឃាត់ទុក ត្រូវកាន់កាប់វត្ថុដែលឃាត់ទុកនោះ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-ម្ចាស់សិទ្ធិឃាត់ទុក មិនអាចយកវត្ថុដែលឃាត់ទុកនោះ ទៅប្រើប្រាស់ ឬ ជួល ឬ ដាក់ជាប្រាតិភោគបានទេ បើគ្មានការយល់ព្រមពីសំណាក់កូនបំណុលទេ ។ ប៉ុន្តែ ម្ចាស់សិទ្ធិឃាត់ទុកអាចប្រើប្រាស់វត្ថុដែលឃាត់ទុកបាន ត្រឹមកម្រិតដែលចាំបាច់ក្នុងការរក្សានូវវត្ថុឃាត់ទុកនោះ ។

៣-ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ កូនបំណុលអាចទាមទារឱ្យរំលត់នូវសិទ្ធិឃាត់ទុកនោះបាន ។

**មាត្រា ៧៧៧.-** សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិឃាត់ទុក

១-ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ចំពោះវត្ថុដែលឃាត់ទុក ម្ចាស់សិទ្ធិឃាត់ទុកនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងចំណាយវិញបាន ។

២-ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកបានចេញចំណាយបង្កើនតម្លៃ ចំពោះវត្ថុដែលឃាត់ទុក ម្ចាស់សិទ្ធិឃាត់ទុកនោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងចំណាយទាំងអស់ដែលខ្លួនបានចេញ ឬ តម្លៃប្រាក់កំណើនដែលមានអត្ថិភាព តាមការជ្រើសរើសរបស់កម្មសិទ្ធិករបាន ក្នុងករណីដែលកំណើនតម្លៃនោះនៅតែមាន ។ ប៉ុន្តែ តុលាការអាចកំណត់ពេលសមរម្យដើម្បីសង តាមការទាមទាររបស់កម្មសិទ្ធិករបាន ។

**មាត្រា ៧៧៨.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការអនុវត្តសិទ្ធិឃាត់ទុក មិនរារាំងដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ។

**មាត្រា ៧៧៩.-** ការរំលត់សិទ្ធិឃាត់ទុក ដោយការផ្តល់នូវប្រាតិភោគ

កូនបំណុលអាចទាមទារឱ្យរំលត់នូវសិទ្ធិឃាត់ទុកបាន ដោយផ្តល់នូវប្រាតិភោគដ៏សមរម្យ ។

**មាត្រា ៧៨០.-** ការរំលត់សិទ្ធិឃាត់ទុក ដោយការបាត់បង់នូវការកាន់កាប់

១-សិទ្ធិឃាត់ទុកត្រូវរលត់ ពេលណាម្ចាស់សិទ្ធិឃាត់ទុកបានបាត់បង់នូវការកាន់កាប់វត្ថុឃាត់ទុកនោះ ។ ប៉ុន្តែ ក្នុងករណី ដែលម្ចាស់សិទ្ធិឃាត់ទុកបានយកវត្ថុនោះ ទៅជួល ឬ ដាក់បញ្ចាំ ដោយទទួលការយល់ព្រមពីកូនបំណុល តាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៧៧៦ (ករណីយកិច្ចរបស់ម្ចាស់សិទ្ធិឃាត់ទុកក្នុងការរក្សាគ្រប់គ្រងវត្ថុដែលឃាត់ទុក) នៃក្រមនេះ សិទ្ធិឃាត់ទុកនេះមិនត្រូវរលត់ឡើយ ។

២-ទោះបីជាម្ចាស់សិទ្ធិឃាត់ទុកបានបាត់បង់នូវការកាន់កាប់វត្ថុឃាត់ទុកក៏ដោយ ប្រសិនបើម្ចាស់សិទ្ធិឃាត់ទុកនោះ បានការកាន់កាប់នោះមកវិញ តាមបញ្ញត្តិនៃមាត្រា ២៣៧ (សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ) នៃក្រមនេះ ការកាន់កាប់នោះ ត្រូវបានចាត់ទុកថា បានបន្តរហូតមក ។

# គន្ថីទី ៨
# សន្តតិកម្ម
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ
### ផ្នែកទី ១
### ការចាប់ផ្តើមធ្វើសន្តតិកម្ម

**មាត្រា ១១៤៥.–** មូលហេតុនៃការចាប់ផ្តើមធ្វើសន្តតិកម្ម

១-សន្តតិកម្ម ត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន ។

២-សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬ ដោយផ្អែកតាមឆន្ទៈរបស់មតកជន ។ សន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថា សន្តតិកម្មតាមច្បាប់ សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា សន្តតិកម្មមានបណ្តាំ ។

### ផ្នែកទី ២
### អានុភាពនៃសន្តតិកម្ម

**មាត្រា ១១៤៧.–** ការទទួលបន្តនូវមត៌ក

១-សន្តតិជន ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចទាំងអស់ ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិ និង ករណីយកិច្ចផ្តាច់មុខមាំងស្រុងរបស់មតកជន ។

២-ចំពោះកម្មសិទ្ធិលើវត្ថុសម្រាប់ជំនឿសាសនា និង ចេតិយ ឬ ចលនវត្ថុដែលជារតនសម្បត្តិត្រកូលនៃបុព្វជន បើមានជនដែលត្រូវទទួលបន្តកម្មសិទ្ធិទាំងនោះ ដូចជាជន

### ផ្នែកទី ៣
### ភាពគ្រប់លក្ខណសម្បត្តិជាសន្តតិជន

**មាត្រា ១១៤៩.–** បុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន ជាអាទិ៍

១-មានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម ក្រៅពីបុគ្គលដែលបញ្ញត្តចាប់ពីមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) រហូតដល់មាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាងក្រោមនេះទេ ទើបអាចទទួលសន្តតិកម្មបាន ។

២-ទោះមានបញ្ញត្តិដូចកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៩ (ទារកនៅក្នុងគភ៌) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះទារកដែលនៅក្នុងគភ៌ ។

# ឧបសម្ព័ន្ធទី២

## ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

### ជំពូកទី ៣
### បទប្បញ្ញត្តិពិសេសស្តីពីការអនុវត្តសិទ្ធិប្រាតិភោគ

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៩៩.–** ការលក់ដោយបង្ខំដោយសិទ្ធិឃាត់ទុក និង ការលក់ដោយបង្ខំដើម្បីប្តូរជាប្រាក់

ការលក់ដោយបង្ខំដោយសិទ្ធិឃាត់ទុក និង ការលក់ដោយបង្ខំដើម្បីប្តូរជាប្រាក់ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត ត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមនីតិ-វិធីរដ្ឋប្បវេណីនេះ ដែលកំណត់អំពីការលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ។

### ផ្នែកទី ៥
### ការលុបចោលដីកាសម្រេចរក្សាការពារ

**មាត្រា ៥៥៧.–** ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ជាអាទិ៍

១-តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹងអង្គសេចក្តី ហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវមានរយៈពេលមិនតិចជាង២ (ពីរ) សប្តាហ៍ ។

៣-បើម្ចាស់បំណុលមិនដាក់ឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងអំឡុងពេលដែលត្រូវបានកំណត់ តាមបញ្ញត្តិនៃកថាខណ្ឌដដែលនោះ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល ។

៤-ក្នុងករណីដែលពាក្យបណ្តឹងអង្គសេចក្តីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានដកវិញ ឬ ត្រូវបានលើកចោល នៅក្រោយពេលដែលឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនោះ ត្រូវបានដាក់ ត្រូវចាត់ទុកថា ឯកសារនោះមិនបានដាក់ឡើយ ។

៥-ចំពោះការអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ៣ ខាងលើនេះ បើមានកិច្ចសន្យាមជ្ឈត្តកម្មអំពីអង្គសេចក្តី ការចាប់ផ្តើមនីតិវិធីមជ្ឈត្តកម្ម ត្រូវចាត់ទុកជាការដាក់ពាក្យបណ្តឹងអង្គសេចក្តី ។

៦-បើនីតិវិធីមជ្ឈត្តកម្មដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះ បានចប់មិនមែនដោយសេចក្តីសម្រេចមជ្ឈត្តករ ម្ចាស់បំណុលត្រូវដាក់ពាក្យបណ្តឹងអង្គសេចក្តី ក្នុងអំឡុងពេលដូចគ្នានឹងអំឡុងពេលដែលបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ចាប់ពីថ្ងៃដែលនីតិវិធីមជ្ឈត្តកម្មនោះបានចប់ ។

៧-បញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹងអង្គសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ៦ ហើយបញ្ញត្តិនៃកថាខណ្ឌទី ៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបណ្តឹងអង្គសេចក្តីត្រូវបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ៦ តែក្រោយមកត្រូវបានដកវិញ ឬ ត្រូវបានលើកចោល ។

៨-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចតាមកថាខណ្ឌទី ៣ និង ទី ៧ ។

**មាត្រា ៥៥៨.-** ការលុបចោលដីកាសម្រេចរក្សាការពារ ដោយសារការផ្លាស់ប្តូរស្ថានភាព

១-បើមានការរលត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាព តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ឬ តុលាការនៃបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុលបាន ។

២-ចំពោះការផ្លាស់ប្តូរស្ថានភាពដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) និង កថាខណ្ឌទី ២ នៃមាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៥៩.–** ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារស្ថានភាពពិសេស

១-ប្រសិនបើមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ មានស្ថានភាពពិសេសផ្សេងទៀត តុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ តុលាការនៃបណ្ដឹងអង្គសេចក្ដីអាចលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននោះបាន ដោយមានល័ក្ខខ័ណ្ឌតម្រូវឱ្យដាក់ប្រាតិភោគ តាមពាក្យសុំរបស់កូនបំណុល ។

២-ចំពោះស្ថានភាពពិសេសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ កូនបំណុលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

# ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>កិច្ចសន្យាខ្ចីប្រាក់_ដាក់បញ្ចាំ</u>

រវាងខ្ញុំបាទ-នាងខ្ញុំឈ្មោះ..........................អាយុ.........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............ ចុះថ្ងៃទី.........ខែ.........ឆ្នាំ......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ.....................ខេត្ត/ក្រុង...................... ហៅកាត់ថា **ភាគី "ក" ម្ចាស់ប្រាក់** ។

**និង**

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ..............................អាយុ...........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............ ចុះថ្ងៃទី..........ខែ.........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ....................ខេត្ត/ក្រុង...................... ហៅកាត់ថា **ភាគី "ខ" ជាអ្នកខ្ចីប្រាក់** ។

***ភាគី "ក" និងភាគី "ខ" បានព្រមព្រៀង តាមប្រការដូចខាងក្រោមៈ***

**<u>ប្រការ១:</u>** ភាគី "ក" យល់ព្រមឱ្យភាគី "ខ" ខ្ចីប្រាក់ចំនួន......................ដុល្លារ (...............................................)

ភាគី "ខ" បានទទួលចំនួនទឹកប្រាក់នេះ នៅពេលចុះកិច្ចសន្យាចំពោះមុខសាក្សី និងមេធាវី ។

**<u>ប្រការ២:</u>** ភាគី "ខ" យល់ព្រមបង់ការប្រាក់ឱ្យភាគី "ក" ហើយភាគី "ក" យល់ព្រមទទួលការប្រាក់ពី ភាគី "ខ" ក្នុងអត្រាព្រមព្រៀង.............ភាគរយ ក្នុង១ខែ ស្មើនឹង....................(...............................................) នៃប្រាក់ដែលបានខ្ចី ។ រយៈពេល..................................នៃការខ្ចីប្រាក់ គិតចាប់ពីថ្ងៃទី...........ខែ............ ឆ្នាំ.......... រហូតដល់ថ្ងៃទី..........ខែ...........ឆ្នាំ........... ។

**<u>ប្រការ៣:</u>** ភាគី "ខ" យល់ព្រមបង់ការប្រាក់ឱ្យ ភាគី "ក" នៅថ្ងៃទី............ដើមខែនិមួយៗ ។ ភាគី "ក" យល់ព្រមឱ្យភាគី "ខ" បង់សងនូវចំនួនទឹកប្រាក់ខ្ចីទាំងអស់ ឬមួយផ្នែកណានោះ នៃកិច្ចសន្យានៅពេលណាក៏បានក្នុងពេលអនុវត្តកិច្ចសន្យានេះ បើកាលណាភាគី "ខ" មានបំណងចង់ចេញសងរួមទាំងប្រាក់ដើមនិងការប្រាក់ផង ។ ក្នុងករណីភាគី "ខ" ពុំបានបង់ការក្នុងរយៈពេល**<u>០៣ខែជាប់ៗគ្នានោះ</u>** ភាគី "ខ" យល់ព្រមឱ្យភាគី "ក" ប្រើសិទ្ធិរបស់ខ្លួនក្នុងការបញ្ឈប់ ឬបញ្ចប់កិច្ចសន្យានេះបានដោយឯកតោភាគី ។

ភាគី "ខ" បានយល់ព្រមថា ករណីបង់ការប្រាក់យឺតយ៉ាវរហូតដល់ ០៣ខែ អនុញ្ញាតឱ្យភាគី "ខ" រឹបអូសយកផ្ទះ និងដីដែលបានដាក់បញ្ចាំឱ្យភាគី "ខ" រួចចុះចេញពីផ្ទះ និងដី ដោយគ្មានលក្ខខណ្ឌអ្វីទាំងអស់ ។

**ប្រការ៤:** យោងកិច្ចសន្យានេះ ដើម្បីធានាដល់ការបំពេញកាតព្វកិច្ចភាគី "ខ" បានដាក់អចលនទ្រព្យធានាមានដូចជា:

| ល.រ | រាយមុខទ្រព្យសម្បត្តិដាក់បញ្ចាំ | ចំនួនច្បាប់ | ផ្សេងៗ |
|---|---|---|---|
| ១ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យ:.......................................... ចុះថ្ងៃទី......ខែ.........ឆ្នាំ........( ក្រុម/ភូមិ..........ឃុំ/សង្កាត់............) ស្រុក/ខណ្ឌ.......................ខេត្ត/ក្រុង.................................. ។ | | |
| ២ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យ:.......................................... ចុះថ្ងៃទី......ខែ.........ឆ្នាំ........( ក្រុម/ភូមិ..........ឃុំ/សង្កាត់............) ស្រុក/ខណ្ឌ.......................ខេត្ត/ក្រុង.................................. ។ | | |
| ៣ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យ:.......................................... ចុះថ្ងៃទី......ខែ.........ឆ្នាំ........( ក្រុម/ភូមិ..........ឃុំ/សង្កាត់............) ស្រុក/ខណ្ឌ.......................ខេត្ត/ក្រុង.................................. ។ | | |

**ប្រការ៥:** កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរចំនួន ០៣ច្បាប់ សម្រាប់ភាគី "ក" និងភាគី "ខ" រក្សាទុកចំនួន ០១ច្បាប់ម្នាក់ មេធាវី ០១ច្បាប់ ។

**ប្រការ៦:** កិច្ចសន្យានេះធ្វើឡើងរវាងភាគី "ក" និងភាគី "ខ" ដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ ហើយកិច្ចសន្យានេះមានសុពលភាពនៅពេលដែលចុះហត្ថលេខា និងផ្ដិតស្នាមមេដៃស្ដាំ ជាភស្តុតាង ។

ធ្វើនៅ................ ថ្ងៃទី..........ខែ...........ឆ្នាំ............

**ភាគី "ខ"** **សាក្សីភាគី "ខ"** **សាក្សីភាគី "ក"** **ភាគី "ក"**

ឈ្មោះ......................... ឈ្មោះ......................... ឈ្មោះ......................... ឈ្មោះ.........................

បានឃើញ និង បញ្ជាក់ថា

ភាគីទាំងពីរបានផ្ដិតមេដៃស្ដាំ ចំពោះមុខមេធាវី

ប្រាកដមែន ។

ធ្វើនៅ............ថ្ងៃទី.........ខែ..........ឆ្នាំ.........

**មេធាវី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**************

# កិច្ចសន្យាម៉ៅការ

កិច្ចសន្យាម៉ៅការ ("កិច្ចសន្យា") ធ្វើនៅថ្ងៃទី............ខែ............ឆ្នាំ............ដោយ និងរវាង៖ លោក................. ជាពលរដ្ឋខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ.........................មានទីលំ នៅផ្ទះលេខ............ផ្លូវ...................... សង្កាត់.........................ខណ្ឌ....................រាជធានី/ខេត្តក្រុងពីពេលនេះតទៅហៅថា (ម្ចាស់ការ)។

**និង**

លោក...........................ជាពលរដ្ឋខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ.........................មានទីលំ នៅផ្ទះលេខ .........................ផ្លូវ.........................សង្កាត់.........................ខណ្ឌ....................រាជធានី/ខេត្ត/ក្រុង........ ពីពេលនេះតទៅហៅថា (អ្នកម៉ៅការ)។

បន្ទាប់ពីពេលនេះតទៅម្ចាស់ការ និង អ្នកម៉ៅការហៅជារួមថា ("ភាគីទាំងពីរ")។

## កិច្ចព្រមព្រៀង

**ភាគីទាំងពីរព្រមព្រៀងគ្នាដូចតទៅ៖**

**ប្រការ ១ កម្មវត្ថុនៃកិច្ចសន្យា**

១.១ អ្នកម៉ៅការបានសម្រេចប្រគល់ ការសាងសង់ផ្ទះវីឡាមួយ ដែលមានទីតាំងនៅដីឡូត៍លេខ..................... ផ្លូវលេខ.....................ឃុំ/សង្កាត់.....................ស្រុក/ខ័ណ្ឌ................ខេត្ត/ក្រុង.................ដែលជារបស់ ម្ចាស់ការ។

១.២ អ្នកម៉ៅការព្រមទទួលយកការងារសាងសង់ផ្ទះវីឡាពីម្ចាស់ការ។

ប្រការ ២ រយៈពេលនៃការសាងសង់

ភាគីទាំងពីរបានព្រមព្រៀងគ្នាថារយៈពេលនៃការសាងសង់គឺត្រូវចំណាយពេល ....... ឆ្នាំ គិតចាប់ពីថ្ងៃទី.............. ខែ....................ឆ្នាំ................ដល់ថ្ងៃទី.................ខែ............ឆ្នាំ..................។

**ប្រការ ៣ ភារកិច្ចរបស់ម្ចាស់ការ**

៣.១ ទទួលបន្ទុកក្នុងការស្នើសុំលិខិតអនុញ្ញាតសាងសង់ និងលិខិតផ្សេងៗពីអាជ្ញាធរ ពាក់ព័ន្ធ។

៣.២ ផ្តល់ព័ត៌មានសំខាន់ៗដែលមានសារៈសំខាន់ដល់ការសាងសង់។

៣.៣ ត្រូវប្រគល់លុយទៅតាមកាលកំណត់ដែលមានចែងនៅក្នុងកិច្ចសន្យា។

៣.៤ ត្រូវបង្កភាពងាយស្រួល ដល់អ្នកម៉ៅការក្នុងការអនុវត្តការងារ និងមិនមានការ ហាមឃាត់ ឬរំខានដល់ដំណើរការសាងសង់។

៣.៥ ត្រូវទទួលខុសលើតតិយជន ដែលរងគ្រោះដោយសារសំណង់ផ្ទះវីឡាក្នុងកំឡុង ពេលសាងសង់ និងចេញសោហ៊ុយព្យាបាល។

**ប្រការ ៤ ភារកិច្ចរបស់អ្នកម៉ៅការ**

៤.១ ត្រូវអនុវត្តការងារឱ្យតាមបានត្រឹមត្រូវតាមមាត្រដ្ឋានសំណង់ បច្ចេកទេសសំណង់ និងគុណភាពសំណង់។

៤.២ មើលថែរក្សាសំណង់ និងសម្ភារសាងសង់ដោយខ្លួនឯង។

៤.៣ ត្រូវសាងសង់ឱ្យទាន់ពេលវេលាតាមការកំណត់របស់កិច្ចសន្យា។

៤.៤ ត្រូវផ្គត់ផ្គង់សម្ភារនៅក្នុង និងក្រៅផ្ទះវីឡា។

៤.៥ ត្រូវផ្គត់ផ្គង់ប្រព័ន្ធទឹក និងភ្លើងដល់ការសាងសង់។

**ប្រការ ៥ ទឹកប្រាក់នៃការសាងសង់ លក្ខខណ្ឌ និងរយៈពេលនៃការបង់ប្រាក់**

៥.១ ការសាងមានទឹកប្រាក់ចំណាយសរុប ...............................

៥.២ ការបង់ប្រាក់ត្រូវធ្វើជា ៥ ដំណាក់កាល

- ដំណាក់កាលទី១ ៣០% ចាប់ផ្តើមសាងសង់ និងបើកជូន ....................
- ដំណាក់កាលទី២ ២០% ចាក់ជាន់ទីមួយរួច និងបើកជូន ....................
- ដំណាក់កាលទី៣ ២០% ចាក់ជាន់ទីពីររួច និងបើកជូន ....................
- ដំណាក់កាលទី៤ ២០% ការ៉ូ លាបថ្នាំ សម្ភារ និងបើកជូន ....................
- ដំណាក់កាលទី៥ ១០% មួយឆ្នាំក្រោយពេលសាងសង់រួច និងបើកជូន ....................

## ប្រការ ៦ ខសន្យាសើរើតម្លៃ

៦.១ កិច្ចសន្យានេះចំណាយអស់...........ឆ្នាំ និងទឹកប្រាក់ចំនួន .................... ដូច្នេះគូភាគីទាំងពីរព្រមព្រៀងក្នុងការអនុវត្តខសន្យាសើរើតម្លៃ។ ម្ចាស់ការ មានកាតព្វកិច្ចចំពោះអ្នកម៉ៅការ នូវការខាតបង់នៃការសាងសង់ ដែលកើតឡើងដោយ សារការឡើងថ្លៃសម្ភារសំណង់នៅលើទីផ្សារ ដែលបានកើតឡើងក្នុងពេលគិតចាប់ពី ថ្ងៃទី.............. ខែ......................ឆ្នាំ..................។ ការសើរើតម្លៃនឹងពុំអាចធ្វើឡើង ប្រសិនបើ ការខាតបង់ស្ថិតនៅក្រោមរយៈពេល ៦ ខែដំបូងនៃកិច្ចសន្យា។ អ្នកម៉ៅការមានកាតព្វ កិច្ចផ្តល់ព័ត៌មាន គ្រប់ព្រឹត្តិការណ៍ទាំងអស់ដែលនាំឱ្យមានការអនុវត្តការសើរើតម្លៃក្នុង រយៈពេល ១ សប្តាហ៍ គិតពីថ្ងៃសម្ភារឡើងថ្លៃ តាមរយៈលិខិតអនុសិទ្ធ។ ការមិនគោរព កាតព្វកិច្ចនេះ និងត្រូវទទួលទណ្ឌកម្មនៃការថ្លោះសិទ្ធិទទួលបានការសើរើតម្លៃ។

៦.២ ការសើរើនោះនឹងកែប្រែទៅតាមតម្លៃនៃការកើនឡើងសម្ភារ ដោយគិតជាភាគរយ និងតាមការព្រមព្រៀងរបស់ភាគីទាំងពីរ។

៦.៣ បើសិនជាតម្លៃសម្ភារធ្លាក់ចុះនោះការអនុវត្តត្រូវធ្វើដូចជាកថាខណ្ឌ ៦.១ ដែរ គឺរយៈពេលនៃការសើរើត្រូវគិតពីខែទី៧ ទៅរហូតដល់បញ្ចប់កិច្ចសន្យា និងត្រូវមានការជូនដំណឹងពីអ្នកម៉ៅការ។ ការសើរើតម្លៃត្រូវគិតទៅតាមការថយចុះជាភាគរយនៃតម្លៃសម្ភារ និងតាមការព្រមព្រៀងរបស់ភាគីទាំងពីរ។

## ប្រការ ៧ ការធានាទិការៈ និងការទទួលខុសត្រូវកិច្ចសន្យា និងក្រោយពេលបញ្ចប់កិច្ចសន្យា

៧.១ អ្នកម៉ៅការមានកាតព្វកិច្ចធានាថា ត្រូវមានលក្ខណៈដូចគ្នារវាងកិច្ចសន្យា និង សំណង់ បើការងារនោះមិនត្រឹមត្រូវក្នុងការប្រើប្រាស់ជាប្រក្រតីទេ ត្រូវចាត់ទុកជាការងារមានវិការៈ។

៧.២ អ្នកម៉ៅការត្រូវទទួលខុសត្រូវលើការសាងសង់របស់ខ្លួនក្នុងអំឡុងពេលសាងសង់ បើសិនជាខុសពីប្លង់ស្ថាបត្យកម្មនៃផ្ទះវីឡា។ ចំពោះហេតុការណ៍ដែលបានដឹងហើយ តែបែរជាមិនបានរាយការណ៍ប្រាប់ទេនោះ អ្នកម៉ៅការមិនអាចរួចផុតពីការទទួលខុសត្រូវ ឬការកម្រិតការទទួលខុសត្រូវបានឡើយ។

៧.៣ អ្នកម៉ៅការអាចបដិសេធបាន បើការចំណាយសោហ៊ុយលើការជួលជុលច្រើន ហួសហេតុ បើប្រៀបធៀបទៅនឹងការខូចខាតផលប្រយោជន៍ដោយវិការៈនោះ។

៧.៤ អ្នកម៉ៅការយល់ព្រមទទួលខុសត្រូវក្នុងករណីមានការយឺតយ៉ាវដែលបណ្តាលមក ពីការសាងសង់របស់ខ្លួន ដោយមិនទាមទារថ្លៃឈ្នួលបន្ថែម។

៧.៥ បើអ្នកម៉ៅការបានចាប់ផ្តើមធ្វើការងារនោះឡើងវិញ អ្នកម៉ៅការនោះអាចទាមទារ ឱ្យម្ចាស់ការសងការងារដែលមានវិការៈមកវិញបាន។

៧.៦ ម្ចាស់ការអាចទាមទារសំណងនៃការខូចខាតបើការងារមានវិការៈ ក្នុងករណីនេះ អ្នកម៉ៅការអាចជួសជុលវិការៈ ឬអាចធ្វើការងារសារជាថ្មី។

៧.៧ ភាគីទាំងពីរយល់ព្រមកំណត់រយៈពេល ១ ឆ្នាំ ក្នុងការធានាលើវិការៈកំបាំង និងមើលឃើញផ្ទាល់ភ្នែកលើការជួលជុល ឯថ្លៃសម្ភារត្រូវចេញដោយអ្នកម៉ៅការ ប៉ុន្តែ ក្នុងករណីដែលវិការៈកើតឡើងពីការសាងសង់របស់អ្នកម៉ៅការតែប៉ុណ្ណោះ។

## ប្រការ ៨ ការជូនដំណឹងជាមុនចំពោះការខកខានក្នុងការអនុវត្តកិច្ចសន្យា

៨.១ ភាគីទាំងពីរ ព្រមព្រៀងអនុវត្តកិច្ចសន្យានេះទៅនឹងលក្ខខណ្ឌបង្អង់បន្តការសាងសង់របស់អ្នកម៉ៅការ។ ការផ្តល់ដំណឹងនេះត្រូវជូនដំណឹងជាមុន ២ ខែនៃការបង្អង់ការអនុវត្តកិច្ចសន្យា តាមរយៈការជូនដំណឹងផ្ទាល់មាត់ ឬលិខិតជាលាយលក្ខអក្សរទៅអ្នក ម្ចាស់ការ។ ភាគីទាំងពីរព្រមព្រៀងគ្នាថា លក្ខខណ្ឌបង្អង់នេះត្រូវបានចែងក្នុងផលប្រយោជន៍របស់អ្នកម៉ៅការ។

៨.២ ភាគីទាំងពីរព្រមព្រៀងអនុវត្តកិច្ចសន្យានេះ ទៅនឹងលក្ខខណ្ឌបង្អង់ការបង់ប្រាក់ តាមការកំណត់របស់ម្ចាស់ការ។ ការផ្តល់ដំណឹងនេះត្រូវជូនដំណឹងមុន ២ ខែ នៃការបង្អង់ការអនុវត្តកិច្ចសន្យាតាមរយៈការជូនដំណឹងផ្ទាល់មាត់ ឬលិខិតជាលាយលក្ខអក្ស រទៅអ្នកម៉ៅការ។ ភាគីទាំងពីរព្រមព្រៀងគ្នាថា លក្ខខណ្ឌបង្អង់នេះត្រូវបានក្នុងផលប្រយោជន៍របស់ម្ចាស់ការ។

## ប្រការ ៩ ការរំលាយនឹងមូលហេតុ

៩.១ ម្ចាស់ការអាចរំលាយកិច្ចសន្យា នៅពេលណាក៏បាន ដោយសងសំណងនៃការខូចខាតរហូតដល់ពេលដែលអ្នកម៉ៅការបានសម្រេចការងារ។

៩.២ ម្ចាស់ការអាចរំលាយកិច្ចសន្យាដោយយកមូលហេតុវិការៈធ្ងន់ធ្ងរនៃការងារ និង ក្នុងករណីដែលការអនុវត្តការងារឱ្យពេញលេញមិនបានសម្រេច ឬក្នុងករណីដែលការ អនុវត្តការងារឱ្យពេញលេញមិនបានសម្រេច ឬក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារឱ្យពេញលេញដោយអ្នកម៉ៅការ និងធ្វើឱ្យមានការខូតខាតផលប្រយោជន៍ដោយមិនត្រឹមត្រូវ។

៩.៣ អ្នកម៉ៅការអាចបញ្ចប់ការងាររបស់ខ្លួនមុនពេលកំណត់តែភាគីទាំងពីរបានព្រមព្រៀងគ្នាថា អ្នកម៉ៅការចាស់ត្រូវរកអ្នកម៉ៅការថ្មីដែលមកបន្តការងាររបស់ខ្លួននឹងមានសមត្ថភាពដូចខ្លួន។ អ្នកម៉ៅការថ្មីត្រូវបញ្ចប់ការងារតាមការកំណត់។

**ប្រការ ១០ ច្បាប់គ្រប់គ្រងនឹងការដោះស្រាយវិវាទ**

កិច្ចសន្យានេះត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បើសិនជាមានវិវាទ កើតឡើងរវាងបណ្តាភាគីក្នុងការបកស្រាយកិច្ចសន្យានេះ ឬលើសិទ្ធិ កាតព្វកិច្ច ឬ ការទទួលខុសត្រូវរបស់ភាគី ឬលើបញ្ហាណាមួយ ភាគីទាំងពីរត្រូវចរចារគ្នាជាមុនរយៈ  ពេល ១ ខែ បន្ទាប់ពីមានបញ្ហា បើនៅតែមិនអាចដោះស្រាយបាន ភាគីទាំងពីរព្រមព្រៀងគ្នាដោះស្រាយវិវាទតាមផ្លូវតុលាការ។

កិច្ចសន្យានេះត្រូវបានធ្វើឡើងចំនួន ពីរ ច្បាប់ជាភាសាខ្មែរ ដោយមួយច្បាប់រក្សាទុក ដោយម្ចាស់ការ និងមួយច្បាប់ទៀតរក្សាទុកដោយអ្នកម៉ៅការ។

ភាគីទាំងពីរបានយល់ព្រម និងចុះហត្ថលេខាលើកិច្ចសន្យានេះ

| **ម្ចាស់ការ** | **សាក្សី** | **អ្នកម៉ៅការ** |
|---|---|---|
| លោក.................. | លោក................. | លោក................. |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចសន្យាជួលផ្ទះ

១. ភាគី "ក" ឈ្មោះ........................ភេទ.........អាយុ.......ឆ្នាំ សញ្ជាតិ............
មានទីលំនៅសព្វថ្ងៃផ្ទះលេខ..........ផ្លូវ...........ភូមិ...........ឃុំ/សង្កាត់.....................
ស្រុក/ខណ្ឌ....................ខេត្ត/រាជធានី........................ ជាភាគីម្ចាស់ផ្ទះ ។

២. ភាគី "ខ" ឈ្មោះ........................ភេទ.........អាយុ.......ឆ្នាំ សញ្ជាតិ............
អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន លេខ.................................................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ..........ផ្លូវ...........ភូមិ...........ឃុំ/សង្កាត់.....................
ស្រុក/ខណ្ឌ....................ខេត្ត/រាជធានី........................ ជាភាគីជួលផ្ទះ ។

### ភាគីទាំងពីរបានឯកភាពគ្នាតាមលក្ខខណ្ឌដូចខាងក្រោម៖

**ប្រការ ១: រយៈពេលនៃការជួល**

ភាគី "ក" យល់ព្រមជួលផ្ទះលេខ.........ផ្លូវ.........ភូមិ.................សង្កាត់..............
ខណ្ឌ........................ ខេត្ត/រាជធានី........................អោយទៅ ភាគី "ខ"
ក្នុងរយៈពេល..........ខែ គិតចាប់ពីថ្ងៃទី........ខែ...........ឆ្នាំ..............រហូតដល់
ថ្ងៃទី..........ខែ............ឆ្នាំ...............

**ប្រការ ២: តម្លៃនៃការជួល**

ភាគី "ក" និងភាគី "ខ" ឯកភាពជួលក្នុងតម្លៃ.............(......................ដុល្លារអាមេរិក)

**ប្រការ ៣: ប្រាក់កក់**

ភាគី "ខ" បានបង់ប្រាក់កក់ចំនួន...........ខែជាមុន ដែលស្មើនឹង.........................
(.......................ដុល្លារអាមេរិក)

**ប្រការ ៤: ការបង់ប្រាក់**

ភាគី "ខ" ត្រូវបង់ប្រាក់ជួលផ្ទះនៅថ្ងៃទី០១ រៀងរាល់ខែ ។

**ប្រការ ៥: ការមិនបង់ប្រាក់**

“ក” អាចបញ្ចប់កិច្ចសន្យាមុនកាលកំណត់ក្នុងប្រការ១ ប្រសិនបើភាគី “ខ” មិនអនុវត្តតាមប្រការណាមួយនៃកិច្ចសន្យានេះ ។

**ប្រការ ១៣: ការបន្តកិច្ចសន្យា**

ភាគី “ខ” មានសិទ្ធិបន្តកិច្ចសន្យាជាថ្មី ឬបញ្ចប់ ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ ទៅភាគី “ក” រយៈពេល៣០ថ្ងៃមុនការបញ្ចប់កិច្ចសន្យា ។ បើមិនដូច្នេះទេ កិច្ចសន្យានេះនឹងបន្តជាថ្មីរយៈពេលជួលយ៉ាងតិច៣ខែ ក្រោមលក្ខខណ្ឌដូចគ្នា ។

**ប្រការ ១៤: សុពលភាព និងភាសា**

កិច្ចសន្យានេះមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ រហូតដល់ថ្ងៃផុតកំណត់ ដូចមានចែងក្នុងប្រការ១ ។ កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរ ចំនួន២ច្បាប់ ហើយភាគី នីមួយៗ រក្សាទុកម្នាក់មួយច្បាប់សម្រាប់ជាភស្តុតាង ។

ធ្វើនៅ..........................ថ្ងៃទី........ខែ............ឆ្នាំ..............

**ស្នាមមេដៃស្តាំភាគី “ក”** **ស្នាមមេដៃស្តាំភាគី “ខ”**

**ស្នាមមេដៃស្តាំ និង ឈ្មោះសាក្សី**

# ឧបសម្ព័ន្ធទី៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>លិខិតប្រគល់និងទទួលប្រាក់</u>

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ............................អាយុ..........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.................... ចុះថ្ងៃទី.........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង....................... ។

**បានទទួលប្រាក់ចំនួន**.......................ដុល្លារ (.....................................................) នៅថ្ងៃទី............ ខែ............ឆ្នាំ............. ។

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ................................អាយុ...........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............. ចុះថ្ងៃទី..........ខែ.........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ....................ខេត្ត/ក្រុង...................... ។

ក្រែងពុំពិតប្រាកដយើងខ្ញុំទាំងពីរនាក់ សូមផ្តិតមេដៃស្តាំទុកជាភស្តុតាងតាមផ្លូវច្បាប់ ។

**ធ្វើនៅ..............ថ្ងៃទី.........ខែ..........ឆ្នាំ២០.......**

| **ស្នាមមេដៃស្តាំអ្នកទទួលប្រាក់** | **សាក្សីអ្នកទទួលប្រាក់** | **សាក្សីអ្នកប្រគល់ប្រាក់** | **ស្នាមមេដៃស្តាំអ្នកប្រគល់ប្រាក់** |
|---|---|---|---|
| ឈ្មោះ.......................... | ឈ្មោះ.......................... | ឈ្មោះ.......................... | ឈ្មោះ.......................... |

បានឃើញ និង បញ្ជាក់ថា

ភាគីទាំងពីរបានផ្តិតមេដៃស្តាំ ចំពោះមុខមេធាវី

ប្រាកដមែន ។

ធ្វើនៅ.............ថ្ងៃទី..........ខែ...........ឆ្នាំ..........

**មេធាវី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>លិខិតសងប្រាក់</u>

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ...........................អាយុ..........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.................... ចុះថ្ងៃទី.........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ............ ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ.....................ខេត្ត/ក្រុង...................... ។

**បានសងប្រាក់ចំនួន**......................ដុល្លារ (.....................................................) នៅថ្ងៃទី............ ខែ.............ឆ្នាំ............. ។

ទៅឱ្យឈ្មោះ................................អាយុ...........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ........................ ចុះថ្ងៃទី...........ខែ.........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ............ ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ....................ខេត្ត/ក្រុង...................... ។

សងប្រាក់គ្រប់ចំនួន ហើយសូមបញ្ចប់នូវកិច្ចសន្យាទិញ-លក់ដីនិងផ្ទះ ចុះថ្ងៃទី.........ខែ..........ឆ្នាំ........... ចាប់ពីពេលនេះតទៅ ។

**ធ្វើនៅ..............ថ្ងៃទី.........ខែ..........ឆ្នាំ២០.......**

| | | | |
|---|---|---|---|
| **ស្នាមមេដៃស្តាំសងប្រាក់** | **សាក្សីអ្នកសងប្រាក់** | **សាក្សីអ្នកទទួលប្រាក់** | **ស្នាមមេដៃស្តាំអ្នកទទួលប្រាក់** |
| ឈ្មោះ........................... | ឈ្មោះ........................... | ឈ្មោះ........................... | ឈ្មោះ........................... |

# ឧបសម្ព័ន្ធទី៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹង

**ដើមចោទ:** ខ្ញុំបាទឈ្មោះ........................................................មានអាសយដ្ឋានបច្ចុប្បន្ន...................................................
តំណាងដោយលោក .......................តួនាទីជា ............................ ទូរស័ព្ទទំនាក់ទំនង ...................................................។

**ចុងចម្លើយ:** ឈ្មោះ .................. ភេទ............ថ្ងៃខែឆ្នាំកំណើត ............. កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ................ ចុះថ្ងៃទី ............... និង................... ថ្ងៃខែឆ្នាំកំណើត .................... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ............. ចុះថ្ងៃទី ......... មានទីលំនៅបច្ចុប្បន្ននៅភូមិ.........ឃុំ/សង្កាត់......... ស្រុក/ខណ្ឌ.................. ខេត្ត/ក្រុង .........................។

**សូមគោរពជូន**
**លោកប្រធានសាលាដំបូង**...............

**កម្មវត្ថុ:** ប្តឹងសុំឲ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារដូចខាងក្រោម:

១. ........................................................
២. ........................................................

**យោង៖** - ........................................................
- ........................................................

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបអំពីដំណើររឿងដូចតទៅ៖ ................................ មានទីលំនៅបច្ចុប្បន្ននៅភូមិ...............ឃុំ/សង្កាត់......... ស្រុក/ខណ្ឌ......................... ខេត្ត/ក្រុង ................................................................................................................................................................................ ................................................................................................................................................................................

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំបាទ ដូចមានក្នុងកម្មវត្ថុខាង លើដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ធ្វើនៅ..........................ថ្ងៃទី.............. ខែ............ ឆ្នាំ២០......

ស្នាមមេដៃស្តាំ

**ឈ្មោះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំដកពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ.......................... មានអាសយដ្ឋានផ្ទះលេខ........ផ្លូវលេខ......... ភូមិ.................ឃុំ/សង្កាត់......... ..........................................................................................ទូរសព្ទ...................។

**សូមគោរពជូន**
**លោកប្រធានសាលាដំបូង**....................

**កម្មវត្ថុ៖** សំណើសុំដកពាក្យបណ្តឹងរដ្ឋប្បវេណីលេខ ....... ចុះថ្ងៃទី ............ ខែ..... ឆ្នាំ ២០.....
**យោង៖** សំណុំរឿងរដ្ឋប្បវេណីលេខ ......... ចុះថ្ងៃទី ..... ខែ........ ឆ្នាំ ២០........

តបតាមកម្មវត្ថុ និងយោងខាងលើ សូម**លោកប្រធាន**ជ្រាបថា៖ កាលពីថ្ងៃទី....................ខ្ញុំបាទបានដាក់ពាក្យប្តឹង ឈ្មោះ ................. ភេទ..... អាយុ........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ .............. មានទីលំនៅបច្ចុប្បន្ននៅភូមិ....... ឃុំ/សង្កាត់............. ស្រុក/ខណ្ឌ.......... ខេត្ត/ក្រុង............។ បន្ទាប់ពីតុលាការចេញដីកាកោះក្នុងនីតិវិធីត្រៀម កូនបំណុលក៏យល់ព្រមសង្គ្រោះតាកព្វកិច្ចតាមកិច្ចសន្យាខ្ចីបរិភោគឡើងវិញបន្ទាប់ពីបានពីឯកភាពគ្នាទាំងស្រុង ហេតុដូច្នេះទើបខ្ញុំបាទ សម្រេចចិត្តសុំដកពាក្យបណ្តឹងដើម្បីបញ្ចប់នីតិវិធី។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **លោកប្រធាន** មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំបាទដូចមានក្នុងកម្មវត្ថុខាងលើ ដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅ........... ថ្ងៃទី...........ខែ........ ឆ្នាំ ២០.....
ស្នាមមេដៃស្តាំ

**ឈ្មោះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំដីកាសម្រេចរក្សាការពារ

**១. អត្តសញ្ញាណរបស់គាត់**

**ម្ចាស់បំណុល** ៖ ឈ្មោះ.................ភេទ.......កើតថ្ងៃទី.........ខែ....... ឆ្នាំ...........ជនជាតិខ្មែរ សញ្ជាតិខ្មែរ
កាន់អត្តសញ្ញាណប័ណ្ណលេខ:...........................ចុះថ្ងៃទី.........ខែ............ឆ្នាំ....................
មានទីលំនៅបច្ចុប្បន្នផ្ទះលេខ........ផ្លូវ...............ភូមិ.......................សង្កាត់/ឃុំ.................
ស្រុក/ខណ្ឌ...........................ខេត្ត/ក្រុង................. មុខរបរ...........................................
ទូរសព្ទទំនាក់ទំនងលេខ៖ ..................................................... ។

**កូនបំណុល** ៖ ឈ្មោះ.................ភេទ....... កើតថ្ងៃទី.........ខែ....... ឆ្នាំ...........ជនជាតិខ្មែរ សញ្ជាតិខ្មែរ
កាន់អត្តសញ្ញាណប័ណ្ណលេខ:...........................ចុះថ្ងៃទី.........ខែ............ឆ្នាំ....................
មានទីលំនៅបច្ចុប្បន្នផ្ទះលេខ........ផ្លូវ...............ភូមិ.......................សង្កាត់/ឃុំ.................
ស្រុក/ខណ្ឌ...........................ខេត្ត/ក្រុង................. មុខរបរ...........................................
ទូរសព្ទទំនាក់ទំនងលេខ៖ ..................................................... ។

**សូមគោរពជូន**
**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**២. ខ្លឹមសារនៃដីកាសម្រេចដែលម្ចាស់បំណុលទាមទារឱ្យតុលាការចេញ**

- ហាមឃាត់ ឈ្មោះ.................ភេទ....... កើតថ្ងៃទី.........ខែ....... ឆ្នាំ...........ជនជាតិខ្មែរ សញ្ជាតិខ្មែរ
កាន់អត្តសញ្ញាណប័ណ្ណលេខ:....................................ចុះថ្ងៃទី.........ខែ............ឆ្នាំ....................
មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.........ផ្លូវ...............ភូមិ.......................សង្កាត់/ឃុំ...............................
ស្រុក/ខណ្ឌ...........................ខេត្ត/ក្រុង............................ មុខរបរ...........................................
មិនឱ្យធ្វើសកម្មភាពចាត់ចែងតាមគ្រប់រូបភាព ក្នុងការលក់ និងចុះបញ្ជីផ្ទេរសិទ្ធិនូវ ...............................
.......................................................................... ទៅអោយតតិយជន ។

- ហាមឃាត់ ឈ្មោះ.................ភេទ....... កើតថ្ងៃទី.........ខែ....... ឆ្នាំ...........ជនជាតិខ្មែរ សញ្ជាតិខ្មែរ
កាន់អត្តសញ្ញាណប័ណ្ណលេខ:....................................ចុះថ្ងៃទី.........ខែ............ឆ្នាំ....................
មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.........ផ្លូវ...............ភូមិ.......................សង្កាត់/ឃុំ...............................
ស្រុក/ខណ្ឌ...........................ខេត្ត/ក្រុង............................ មុខរបរ...........................................
មិនឱ្យធ្វើសកម្មភាពចាត់ចែងតាមគ្រប់រូបភាព ក្នុងការលក់ ដូរ ជួល បញ្ចាំ អនុប្បទាន
លើ.............................................................................................................................. ។

**៣. <u>សិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ</u>**

*(អង្គហេតុ)*..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

**៤. <u>ភាពចាំបាច់នៃការរក្សាការពារ</u>**

*នាងខ្ញុំ/ខ្ញុំបាទទទួលបានដំណឹងថាឈ្មោះ(កូនបំណុល)......................................មានបំណង..........
........................ទៅអោយតតិយជនហើយនាងខ្ញុំមានការព្រួយបារម្ភខ្លាចថា ប្រសិនបើមិនមានដីកាសម្រេចរក្សាការពារទេ កូនបំណុលអាចនឹងធ្វើការចាត់ចែង លក់ ដូរ ជួល ឬ អនុប្បទាន និងចុះបញ្ជីផ្ទេរសិទ្ធិនូវ(កម្មវត្ថុ).................................................ទៅអោយតតិយជន ដែលធ្វើឱ្យការអនុវត្ត ដោយបង្ខំនឹងមិនអាចធ្វើទៅបាន ឬនឹងមានការលំបាកយ៉ាងខ្លាំង ក្នុងការអនុវត្ត ដោយបង្ខំនៅពេល អនាគត ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ នាងខ្ញុំ/ខ្ញុំបាទ ។*

*ឈ្មោះ(កូនបំណុល).........................បានគេសវេស និងបដិសេធក្នុងការសងប្រាក់មកអោយនាងខ្ញុំ/ខ្ញុំបាទ ហើយនាងខ្ញុំ/ខ្ញុំបាទ មានការព្រួយបារម្ភខ្លាច ប្រសិនបើមិនដីកាសម្រេចរក្សាការពារទេ កូនបំណុលអាច នឹងចាត់ចែង លក់ ដូរ ជួល ឬ អនុប្បទាន លើ(កម្មវត្ថុ)..................................................ទៅអោយតតិយជន ហើយនៅតែមិនសងប្រាក់ នាងខ្ញុំ/ខ្ញុំបាទ ដដែល ជាពិសេសការអនុវត្តដោយបង្ខំ នឹងមិនអាចធ្វើទៅបាន ឬនឹងមានការលំបាកយ៉ាងខ្លាំង ក្នុងការអនុវត្តដោយបង្ខំ នៅពេលអនាគតដែលជាហេតុធ្វើឱ្យ ប៉ះពាល់ដល់ផលប្រយោជន៍របស់ នាងខ្ញុំ/ខ្ញុំបាទ ។*

*ដូច្នេះ ដើម្បីជៀសវាងដល់ការខូចខាតធ្ងន់ធ្ងរដល់ប្រយោជន៍រូបនាងខ្ញុំ/ខ្ញុំបាទ នាងខ្ញុំ/ខ្ញុំបាទសូមស្នើសុំឱ្យ* **ឯកឧត្តមប្រធាន** *មេត្តាចេញដីកាសម្រេចតាមពាក្យសុំខាងលើ ដោយក្ដីអនុគ្រោះ ដើម្បីរង់ចាំតុលាការសម្រេចចំពោះបណ្ដឹងអង្គសេចក្ដី។*

*សូម* **ឯកឧត្តមប្រធាន** *មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។*

*រាជធានីភ្នំពេញ ថ្ងៃទី....... ខែ.......... ឆ្នាំ............*

**ស្នាមមេដៃស្ដាំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំឲ្យផ្ដល់រូបមន្តអនុវត្ត**
**សូមគោរពជូន**
**លោក ........................ ចៅក្រមសាលាដំបូង....................**

ម្ចាស់បំណុលនៃការអនុវត្តៈ ឈ្មោះ................ តំណាងស្របច្បាប់ដោយលោក .......... តួនាទីជា........................ មានអាសយដ្ឋាន ភូមិ.......................................................................................។

កូនបំណុលនៃការអនុវត្តៈ ឈ្មោះ ........... ភេទ......... អាយុ........................ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋាននៅ ភូមិ ..............................................................................................................................................។

សញ្ញាណនៃលិខិតអនុវត្តៈ សាលក្រមរដ្ឋប្បវេណីលេខៈ ....... ចុះថ្ងៃទី..... ខែ..... ឆ្នាំ២០........... របស់សាលាដំបូងខេត្ត/ក្រុង........................។

ហេតុការណ៍ និងមូលហេតុនៃការសុំឲ្យផ្ដល់រូបមន្តនៃការអនុវត្តន៍បណ្ដោះអាសន្ន ដោយហេតុថាៈ យោងសេចក្ដីសម្រេចបញ្ចប់ក្នុងសាលក្រមលេខ ......... ចុះថ្ងៃទី...... ខែ........ ឆ្នាំ២០...... របស់សាលាដំបូងខេត្ត/ក្រុង........... ត្រង់ចំណុចទី ........ នៃសេចក្ដីសម្រេចបានចែងថាៈ សាលក្រមនេះមានអានុភាពអនុវត្តជាបណ្ដោះអាសន្ន ត្រង់ចំណុចទី ...............នៃសេចក្ដីសម្រេចបញ្ចប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកចៅក្រម** មេត្តាពិនិត្យ និងសម្រេចតាមនីតិវិធីដោយក្ដីអនុគ្រោះ។
សូម **លោកចៅក្រម** មេត្តាទទួលនូវការគោរពអំពីខ្ញុំបាទ។

ធ្វើនៅ.................. ថ្ងៃទី....... ខែ....... ឆ្នាំ២០.....
ស្នាមមេដៃស្ដាំ

**ឈ្មោះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំអនុវត្តដោយបណ្តោះអាសន្ន

**ម្ចាស់បំណុលអនុវត្ត៖** ឈ្មោះ................. តំណាងស្របច្បាប់ដោយលោក ..................... តួនាទី............... អាសយដ្ឋាននៅ ភូមិ..........................................................................................................................។

**កូនបំណុលអនុវត្ត៖** ឈ្មោះ .......... ភេទ................កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ..................... អាសយដ្ឋាននៅ ភូមិ...............................................................................................................................។

### សូមគោរពចូលមក
### លោកប្រធានសាលាដំបូងខេត្ត/ក្រុង.....................

**កម្មវត្ថុ៖** សុំអនុវត្តបណ្តោះអាសន្ន ត្រង់សេចក្តីសម្រេចបញ្ចប់ ចំណុចទី .....នៃសាលក្រមរដ្ឋប្បវេណីលេខ ........ ចុះថ្ងៃទី ....... ខែ..........ឆ្នាំ២០................. របស់សាលាដំបូងខេត្ត/ក្រុង.......... លើអចលនវត្ថុដែលជា........................ មានផ្ទៃក្រឡា .............. ម៉ែត្រការ៉េ ជាដីលំនៅដ្ឋាន មានទីតាំងស្ថិតនៅភូមិ................................................... ដើម្បីលក់ឡាយឡុងសងបំណុលមកឲ្យ.............................................................................។

**យោង៖**
-សាលក្រមរដ្ឋប្បវេណីលេខ ......... ចុះថ្ងៃទី ....... ខែ........ ឆ្នាំ ២០....... របស់សាលាដំបូងខេត្ត/ក្រុង.............
-រូបមន្តអនុវត្តសាលក្រមលេខ ................ ចុះថ្ងៃទី ........ ខែ ............... ឆ្នាំ២០...........
-វិញ្ញាបនប័ត្រសំគាល់ម្ចាស់ អចលនវត្ថុលេខ .................. ចុះថ្ងៃទី................. ខែ............. ឆ្នាំ ២០......

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី ..... ខែ..... ឆ្នាំ ២០.... សាលាដំបូងខេត្ត/ក្រុង....... បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ លើសំណុំរឿងរដ្ឋប្បវេណីលេខ ..... ចុះថ្ងៃទី..... ខែ......... ឆ្នាំ២០...... ដោយបានសម្រេចសេចក្តី តាមសាលក្រមរដ្ឋប្បវេណីលេខ ........ ចុះថ្ងៃទី ..... ខែ ........ ឆ្នាំ២០..... របស់សាលាដំបូងខេត្ត/ក្រុង........ ត្រង់ចំណុចទី........ នៃវិនិច្ឆ័យសេចក្តីសម្រេចបញ្ចប់ ដែលមានខ្លឹមសារថា: សាលក្រមនេះមានអានុភាពអនុវត្តបណ្តោះអាសន្នបានត្រង់វិនិច្ឆ័យទី..... មានខ្លឹមសារថា: បង្គាប់ឲ្យចុងចម្លើយ ឈ្មោះ ...... សងប្រាក់ដើមចំនួន ................ ឲ្យមកដើមចោទ ................................ ។

ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុលអនុវត្ត ស្របតាមខ្លឹមសារ នៃ សាលក្រមរដ្ឋប្បវេណីលេខ .......... ចុះថ្ងៃទី ...... ខែ .............. ឆ្នាំ២០.............របស់សាលាដំបូងខេត្ត/ក្រុង....... ខ្ញុំបាទស្នើសុំអនុវត្តជាបណ្តោះអាសន្ននូវចំណុចខាងលើ ដោយអនុវត្តដោយបង្ខំលើអចនវត្ថុដូចបានបញ្ជាក់ក្នុងកម្មវត្ថុខាងលើ ដើម្បីលក់ឡាយឡុងសងបំណុលមកម្ចាស់បំណុលអនុវត្ត។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំបាទ ដូចបានបញ្ជាក់ក្នុងកម្មវត្ថុខាងលើដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** ទទូលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ធ្វើនៅ.......... ថ្ងៃទី.....ខែ............. ឆ្នាំ២០....
**ស្នាមមេដៃស្តាំ**